# សៀវភៅហ្វឹកហាត់

# សរសេរតាមអាន និង តែងសេចក្តី



៦

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

www.elibraryofcambodia.org

# សៀវភៅហ្វឹកហាត់

# សរសេរតាមអាន និង តែងសេចក្ដី

## ថ្នាក់ទី ៦

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

www.elibraryofcambodia.org

| | | |
|---|---|---|
| **អ្នកនិពន្ធនិងរៀបរៀង** | លោក | យ៉ង់ កំសាន |
| **អ្នកវាយអត្ថបទ** | លោកស្រី | ហាក់ ផាន្នី |
| **អ្នកពិនិត្យអក្ខរាវិរុទ្ធ** | លោកស្រី | ឈឹម សក្តិវ៉ែឡ្យត |
| | លោក | អ៊ុំ បុប្ផា |
| **វចិត្រករ** | លោក | ហ៊ុយ វណ្ណថេន |
| **អ្នករចនាទំព័រ** | លោក | គង់ ចិត្រា |
| **គណៈកម្មការពិនិត្យ** | បណ្ឌិត | នៅ ស៊ិន |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១៤១៥ អយក.ប្រក. ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១៤ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ2016

ISBN 9-789-995-002-183

www.elibraryofcambodia.org

# អារម្ភកថា

សួស្តី ! លោកគ្រូ អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និងប្រិយមិត្តអ្នកសិក្សាទាំងអស់ជាទីមេត្រី ! សៀវភៅសរសេរតាមអាន និងតែងសេចក្តីថ្នាក់ទី៦នេះ បានរៀបចំឡើងស្របតាមសៀវភៅសិក្សាថ្មីមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៦ របស់ ក្រសួងអប់រំ យុវជន និងកីឡា។

សៀវភៅនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជាជំនួយដល់ការបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រិយមិត្តអ្នកសិក្សាទាំងអស់លើផ្នែកសរសេរតាមអាន និងតែងសេចក្តីដើម្បីឱ្យទទួលបានលទ្ធផលល្អ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងសៀវភៅសរសេរតាមអាន និងតែងសេចក្តីថ្នាក់ទី៦នេះ មានអត្ថបទខ្លីៗសម្រាប់សរសេរតាមអាន ការពន្យល់ពាក្យ បដិសព្ទ វេវចនសព្ទ សទិសសព្ទ សំណួរចម្លើយ គម្រោងតែងសេចក្តី និងមានតែងសេចក្តីពណ៌នាសំខាន់ៗមួយចំនួនថែមទៀត។ ចំណុចទាំងអស់នេះ ជាការចូលរួមលើកកម្ពស់ឱ្យការរៀន និងបង្រៀន សរសេរតាមអាន និងតែងសេចក្តីទទួលបានលទ្ធផលល្អថែមទៀត។

យើងខ្ញុំសង្ឃឹមថា សៀវភៅសរសេរតាមអាន និងតែងសេចក្តីថ្នាក់ទី៦នេះនឹងក្លាយជាជំនួយដ៏ល្អសម្រាប់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រិយមិត្តអ្នកសិក្សាទាំងអស់ពុំខាន។

យើងខ្ញុំរង់ចាំទទួលមតិស្ថាបនាពីប្រិយមិត្តអ្នកអាន អ្នកសិក្សាគ្រប់ពេលវេលាដើម្បីធ្វើឱ្យសៀវភៅនេះកាន់តែល្អថែមទៀត។

**អ្នកនិពន្ធ**

**យ៉ង់ គំសិាន**

www.elibraryofcambodia.org

# មាតិកា

## វិញ្ញាសា សរសេរតាមអាន


ទំព័រ

១. កតញ្ញូប្រាំប្រការ ........ ០២
២. សិទ្ធិកុមារ ........ ០៧
៣. ធនធានធម្មជាតិក្នុងដី ........ ១២
៤. អ៊ំប្រេងកាត ........ ១៧
៥. អ៊ំមាស ........ ២២
៦. ទស្សនាបឹងទន្លេសាប ........ ២៧
៧. ពិធីបំបួសនាគ ........ ៣៣
៨. របាំក្ងោក ........ ៣៨
៩. របាំត្រុដិ ........ ៤២
១០. ព្រះពុទ្ធសាសនា ........ ៤៧
១១. អន្ទង់ព្រីង ........ ៥២
១២. បឹងយក្សឡោម ........ ៥៦
១៣. បុត្រល្អ ........ ៦១
១៤. សេចក្តីថ្លៃថ្នូររបស់មនុស្ស ........ ៦៥
១៥. ទឹកចិត្តមេមាន់ ........ ៧០


## វិញ្ញាសា តែងសេចក្តីបែបពិពណ៌នា


១. អំពីមនុស្ស ........ ៧៥
២. អំពីសត្វ ........ ៨១
៣. អំពីរុក្ខជាតិ ........ ៨៧
៤. អំពីវត្ថុ ........ ៩១
៥. អំពីទឹកខ្មៅ ........ ៩៦
៦. អំពីទេសភាព ........ ៩៧
៧. អំពីបាតុភូតធម្មជាតិ ........ ១០០
៨. អំពីឧបទ្ទវហេតុ ........ ១០៤
៩. អំពីពិធីផ្សេងៗ ........ ១០៨
១០. អំពីសកម្មភាព ........ ១១២
១១. អំពីការខិតខំរៀន ........ ១១៧
១២. អំពីការសរសេរសំបុត្រ ........ ១២១


www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ១៥ ______ អយក-សណន

**សេចក្តីណែនាំ**
**ស្តីពី**
**ការពង្រឹងការបង្រៀនមុខវិជ្ជាសរសេរអក្សរផ្ចង់ សរសេរតាមអាន និងតែងសេចក្តី**
**នៃមុខវិជ្ជាភាសាខ្មែរនៅតាមសាលារៀនចំណេះទូទៅកម្រិតអប់រំមូលដ្ឋាន**

យោង : - ប្រកាសលេខ ១៦៣៣ អយក.ប្រក. ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០០៦ ស្តីពីការអនុវត្តការណែនាំ គោលការណ៍ កម្មវិធីសិក្សាភាសាខ្មែរ សម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ
- អនុសាសន៍របស់ឯកឧត្តមរដ្ឋមន្ត្រីដែលបានលើកឡើងក្នុងសន្និសីទបូកសរុបការងារប្រចាំខែ ឧសភា ឆ្នាំ ២០១១ របស់ថ្នាក់ដឹកនាំក្រសួងជាមួយមន្ទីរនានា នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់ការអនុវត្តកម្មវិធីសិក្សា ជាពិសេសការសរសេរតាមអាន និងតែងសេចក្តី ដើម្បីពង្រឹងការសរសេរ និងការសរសេរអក្សរផ្ចង់

កន្លងមក ក្រសួងអប់រំ យុវជន និងកីឡាសង្កេតឃើញថា នៅតាមសាលារៀនចំណេះទូទៅកម្រិតអប់រំមូលដ្ឋានមួយចំនួន មិនបានអនុវត្តកម្មវិធីសិក្សាភាសាខ្មែរបានគ្រប់គ្រាន់នៅឡើយទេ ជាពិសេសវិញ្ញាសារសរសេរអក្សរផ្ចង់ សរសេរតាមអាន និងតែងសេចក្តី។

ដើម្បីពង្រឹងការអនុវត្តកម្មវិធីសិក្សាភាសាខ្មែរ ផ្នែកអក្សរផ្ចង់ សរសេរតាមអាន និងតែងសេចក្តីបានល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ៖

១. បឋមសិក្សា : គ្រប់សាលារៀនត្រូវអនុវត្តតាមប្រព័ន្ធការបង្រៀនអក្សរផ្ចង់ សរសេរតាមអាន និងតែងសេចក្តីដោយប្រើប្រាស់ម៉ោងសិក្សាដែលបានកំណត់ក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរតាមចំណែកម៉ោងនៅក្នុងកាលវិភាគប្រចាំសប្តាហ៍ដូចខាងក្រោម ៖

| | |
|---|---|
| - អំណានអក្សរផ្ចង់សម្រាប់ថ្នាក់ទី១ដល់ទី៦ | ចំនួន ១ម៉ោងក្នុង ១សប្តាហ៍ |
| - ការសរសេរតាមអានសម្រាប់ថ្នាក់ទី១ដល់ទី៦ | ចំនួន ១ម៉ោងក្នុង ១សប្តាហ៍ |
| - អំណានតែងសេចក្តីពីរបៀបសរសេរសម្រាប់ថ្នាក់ទី៣ដល់ទី៦ | ចំនួន ២ម៉ោងក្នុង ១សប្តាហ៍ |

២. មធ្យមសិក្សាបឋមភូមិ : គ្រប់សាលារៀនត្រូវអនុវត្តការបង្រៀនការសរសេរតាមអាន ដោយប្រើប្រាស់ម៉ោងសិក្សាដែលបានកំណត់ក្នុងកម្មវិធីសិក្សាភាសាខ្មែរតាមចំណែកម៉ោងនៅក្នុងកាលវិភាគដូចខាងក្រោម៖

| | |
|---|---|
| - ការសរសេរតាមអានសម្រាប់ថ្នាក់ទី៧ដល់ទី៩ | ចំនួន ១ម៉ោងក្នុង ១សប្តាហ៍ |

សំគាល់ : ម៉ោងអនុវត្តសរសេរអក្សរផ្ចង់ សរសេរតាមអាន និងតែងសេចក្តី ត្រូវកំណត់ឲ្យច្បាស់លាស់នៅក្នុងកាលវិភាគប្រចាំសប្តាហ៍នៃមុខវិជ្ជាភាសាខ្មែរ ដូចមានជូនភ្ជាប់។

សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ពាក់ព័ន្ធ ដែលមានភារកិច្ចទទួលបន្ទុក ចាត់ចែងអនុវត្តសេចក្តីណែនាំនេះ ឱ្យមានលទ្ធផលល្អ និងប្រកបដោយប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

អ៊ឹម សេធី

អាសយដ្ឋាន ... E-mail: crameys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

www.elibraryofcambodia.org

វិញ្ញាសាទី ១

# កតញ្ញូប្រាំប្រការ



មាតាបិតា មានគុណធ្ងន់នឹងរកអ្វីមកប្រៀបផ្ទឹមគ្មាន។ ចូរបុត្រាបុត្រីគ្រប់រូបតបស្នងសងគុណលោកទាំងពីរឱ្យបានគាប់ប្រសើរបំផុត។

កូនត្រូវមានធម៌កតញ្ញូប្រាំប្រការ ចំពោះអ្នកមានគុណ។ កូនត្រូវផ្គត់ផ្គង់គ្រឿងហូបចុក សម្លៀកបំពាក់ ថ្នាំសង្កូវពេលគាត់មានជំងឺតម្កាត់ក្តៅរងា។ ជាពិសេស កូនត្រូវជួយធុរៈម្តាយឪពុក រកពុន ទោះបីនឿយហត់ក្តៅត្រជាក់យ៉ាងណាក៏ស៊ូទ្រាំ ដើម្បីឱ្យលោកបានស្រាន្ត។ ដើម្បីរក្សាសន្តិសុខក្នុងគ្រួសារ កូនត្រូវជៀសវាងការទាស់ទែងគ្នា រក្សាកេរ្តិ៍ឈ្មោះពូជពង្សវង្សត្រកូលញាតិផៅសន្តានឱ្យបានល្អផូរផង់ ត្រូវចេះវន្ទា បម្រើអ្នកមានគុណដោយកាយ វាចា ចិត្តទន់ភ្លន់ ព្រោះលោកជាព្រះរស់នៃបុត្រា។ កាលបើមាតា ឬបិតាអស់សង្ខារលាលោកនេះ កូនត្រូវធ្វើបុណ្យតាមប្រពៃណី។



www.elibraryofcambodia.org

កុលបុត្រកុលធីតាគ្រប់រូប ដែលបំពេញបាននូវកតញ្ញូទាំងប្រាំប្រការនេះ ហៅជាបុត្រល្អ។

## សិក្សាស្វែងយល់ពីអត្ថបទ ១

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖ " កតញ្ញូ វន្ទា សង្ខារ ព្រះរស់ " ។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " កតញ្ញូ គុណ ទន់ភ្លន់ " ។
៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " មាតា បិតា បុត្រ " ។
៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " គុណ ក៏ " ។

### ខ. សំណួរ

១. តើកូនត្រូវមានធម៌កតញ្ញូប៉ុន្មានប្រការចំពោះឪពុកម្ដាយ ? អ្វីខ្លះ ?
២. តើកតញ្ញូនីមួយៗមានអត្ថន័យដូចម្ដេច ?
៣. តើអត្ថបទនេះ មានគំនិតអប់រំដូចម្ដេចខ្លះ ?
៤. តើអ្នកបានបំពេញ " កតញ្ញូ " ដូចម្ដេចខ្លះហើយចំពោះឪពុកម្ដាយអ្នក ?

## អំណែងវិញ្ញាសាទី ១

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កតញ្ញូ (ក:-ត័ញ-ញូ) (ន.ឬ គុ.)៖ អ្នកដឹងឧបការគុណដែលអ្នកដទៃទៀតគេបានធ្វើហើយដល់ខ្លួន គឺអ្នកដែលមិនភ្លេចគុណគេ មិនមើលគុណគេ។
  ឧ. បុរសកតញ្ញូ ស្ត្រីកតញ្ញូ។


www.elibraryofcambodia.org

- វន្ទា (វ័ន-ទា) (កិ.) ៖ ថ្វាយបង្គំ សំពះ គំនាប់។
- សង្ខារ (សង់-ខា) (ន.) ៖ ជីវិត សព៌ាង្គកាយ គំនិត អ្វីៗទាំងពួងក្នុងលោក។
- ព្រះរស់ (ន.) ៖ ម្ដាយឪពុក។

២.បដិសព្ទ

- កតញ្ញូ ≠ អកតញ្ញូ
- គុណ ≠ ទោស
- ទន់ភ្លន់ ≠ ច្រងេងច្រងាង

៣.វេវចនសព្ទ

- មាតា ម្ដាយ ម៉ែ ព្រះមាតា ញោមស្រី ម៉ាក់
- បិតា ឪពុក ពុក ព្រះបិតា ញោមប្រុស ប៉ា
- បុត្រ កូន ព្រះរាជបុត្រ ។

៤. សមិសសព្ទ

- គុណ (ន.) ៖ សេចក្ដីចម្រើន សេចក្ដីល្អសភាវធម៌ដែលចម្រើនឡើងដោយលក្ខណៈរបស់ខ្លួន។ *ឧ.* គុណមាតាបិតា។
- គុន (ន.) ៖ សិល្បៈខាងគ្រឿងអាវុធ សម្រាប់ចូលប្រឡូកលោតហក់តយុទ្ធផ្ទាល់ខ្លួន ជាចំណេះប្រាំងរបស់អ្នកចម្បាំងរាល់ប្រទេស។ *ឧ.* ក្បាច់គុន។
- ក៏ (និ.) ៖ ពាក្យជាសន្ធានមានសំឡេងបញ្ជាក់ខ្លីសម្រាប់និយាយ តប្រយោគដោយឡែក។
- ក (ន.) ៖ ព្យញ្ជនៈទី១ ក្នុងអក្សរក្រមខ្មែរ។


www.elibraryofcambodia.org

- ក (ន.) ៖ អវយវៈតពីក្បាលទៅស្មា ឬទៅខ្លួន ក កដៃ...។ ទងខាងដើម កន្លែងដែលជាប់ពីមាត់ទៅទល់នឹងខ្លួន។ ឧ. ក ជប។
- ករ (ន.) ៖ ដៃ។ ឧ. លើកករប្រណម្យ។

## ខ. ចម្លើយ

១. កូនត្រូវមានធម៌កតញ្ញូប្រាំប្រការចំពោះឪពុកម្ដាយគឺ ៖
- កូនត្រូវចិញ្ចឹមឪពុកម្ដាយ
- កូនត្រូវជួយធុរៈឪពុកម្ដាយ
- កូនមិនត្រូវឈ្លោះទាស់ទែងគ្នា ត្រូវរក្សាវង្សត្រកូល
- កូនត្រូវបម្រើឪពុកម្ដាយ
- ត្រូវធ្វើបុណ្យជូនឪពុកម្ដាយ ពេលគាត់លាលោកយើងនេះទៅ។

២. កតញ្ញូអត្ថន័យដូចខាងក្រោម ៖
- កូនត្រូវចិញ្ចឹមឪពុកម្ដាយ ៖ កូនត្រូវជូនម្ហូបបាយ ផ្ដត់ផ្គង់គ្រឿងសម្ភារៈប្រើប្រាស់ផ្សេងៗ សម្លៀកបំពាក់ ថែទាំសុខភាព ជូនថ្នាំសង្កូវព្យាបាលជំងឺឪពុកម្ដាយ។
- កូនត្រូវជួយធុរៈឪពុកម្ដាយ ៖ កូនត្រូវជួយធ្វើការងារឪពុកម្ដាយ ទោះបីការងារធ្ងន់ស្រាលដូចជា កាប់គាស់ លីសែង រែកពុន ទាំងនៅក្នុងផ្ទះ ទាំងនៅក្រៅផ្ទះ មិនត្រូវធុញទ្រាន់ ប្រកែករារែក ខ្ជិលច្រអូស ត្រូវជួយធ្វើការងារមិនថាយប់ថ្ងៃ ដើម្បីកុំឱ្យអ្នកមានគុណនឿយហត់។
- កូនមិនត្រូវឈ្លោះទាស់ទែងគ្នា ៖ កូនមិនត្រូវឈ្លោះទាស់ទែងគ្នាជាមួយបងប្អូន ជាមួយមនុស្សនៅក្នុងគ្រួសារ រួមទាំងមនុស្សនៅក្រៅគ្រួសារ។ កូនត្រូវរក្សាកេរ្តិ៍ឈ្មោះខ្លួនឯង ឪពុកម្ដាយគ្រួសារ ពូជពង្សត្រកូលញាតិផៅសន្តានឱ្យបានល្អប្រពៃ។


www.elibraryofcambodia.org

- កូនត្រូវបម្រើឪពុកម្ដាយ ៖ កូនត្រូវយកចិត្តទុកដាក់បម្រើឪពុកម្ដាយដោយទឹកចិត្តរីករាយ ជូនទឹកក្ដៅទឹកត្រជាក់ ច្របាច់ដៃជើងជាដើម មិនជិនណាយ មិនថាយប់ ឬថ្ងៃតាមសេចក្ដីត្រូវការរបស់លោកអ្នកមានគុណ។ កូនត្រូវមានឥរិយាបថល្អប្រពៃ ចេះឱនលំទោន មានសម្ដីទន់ភ្លន់ ចេះគោរព សំពះវន្ទា ធ្វើយ៉ាងណាឱ្យលោកមានភាពកក់ក្ដៅ។
- កូនត្រូវធ្វើបុណ្យជូនឪពុកម្ដាយ ៖ កូនត្រូវចេះលើកទឹកចិត្តឪពុកម្ដាយ ធ្វើបុណ្យជូនគាត់ដូចជា បុណ្យកតញ្ញូ បុណ្យចម្រើនព្រះជន្មជាដើម។ ជាពិសេស នៅពេលមាតាបិតាទទួលអនិច្ចកម្មទៅកាន់លោកខាងមុខ ត្រូវធ្វើបុណ្យឧទ្ទិសកុសលជូនដល់វិញ្ញាណខន្ធរបស់លោក។

៣. អត្ថបទនេះ មានគំនិតអប់រំដល់កូនប្រុសស្រីឱ្យមានធម៌កតញ្ញូចំពោះមាតាបិតាដែលជាអ្នកមានគុណដ៏សែនធ្ងន់រកអ្វីមកប្រៀបផ្ទឹមពុំបាន សម្រាប់កុលបុត្រកុលធីតាគ្រប់រូប។

៤. អាស្រ័យលើសិស្សម្នាក់ៗ។


www.elibraryofcambodia.org

វិញ្ញាសាទី ២

# សិទ្ធិកុមារ



កុមារមានភារកិច្ចសំខាន់ក្នុងការទ្រទ្រង់ប្រទេសជាតិឱ្យមានការរីកចម្រើន។ ដើម្បីឱ្យកុមារសម្រេចភារកិច្ចនេះបានល្អ លុះត្រាតែមាតាបិតាអាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងសហគមន៍ផ្ដល់សិទ្ធិពេញលេញដល់កុមារ។ កុមារមានសិទ្ធិបួនយ៉ាងគឺ សិទ្ធិក្នុងការរស់រានមានជីវិតមានន័យថា កុមារត្រូវទទួលបាននូវការចិញ្ចឹមបីបាច់ ការថែទាំសុខភាព ការផ្គត់ផ្គង់សម្ភារៈ និងការស្នាក់នៅបានសមរម្យ។ល។ សិទ្ធិក្នុងការការពារមានន័យថា ត្រូវជៀសវាងការប្រើកម្លាំងពលកម្ម ការប្រើអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានមកលើកុមារ។ សិទ្ធិក្នុងការចូលរួមមានន័យថា កុមារមានសិទ្ធិបញ្ចេញមតិយោបល់ ចូលរួមក្នុងពិធីផ្សេងៗ និងទទួលយកគំនិតរបស់កុមារ។ សិទ្ធិក្នុងការទទួលការអប់រំមានន័យថា កុមារមានសិទ្ធិចូលរៀន ទទួលបានចំណេះដឹងផ្សេងៗជាដើម។


www.elibraryofcambodia.org

ផ្ទេះ        យើងទាំងអស់គ្នាត្រូវចូលរួមលើកកម្ពស់ការគោរពសិទ្ធិកុមារ។

## សិក្សាលើវិញ្ញាសាទី ២

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖
" ភារកិច្ច សិទ្ធិ កេងប្រវ័ញ្ច អាណាព្យាបាល រំលោភ " ។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " ហិង្សា រីកចម្រើន រស់ " ។
៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ភារកិច្ច ប្រទេស ផ្គត់ផ្គង់ " ។
៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ការ ជា " ។

### ខ. សំណួរ

១. តើកុមារមានភារកិច្ចសំខាន់អ្វីខ្លះ ?
២. ដើម្បីឱ្យកុមារសម្រេចភារកិច្ចនោះបាន តើត្រូវធ្វើដូចម្ដេច ?
៣. តើកុមារមានសិទ្ធិប៉ុន្មានយ៉ាង ? អ្វីខ្លះ ?
៤. តើសិទ្ធិនីមួយៗមានអត្ថន័យដូចម្ដេច ?


www.elibraryofcambodia.org

# អំណានវិញ្ញាសាទី ២

## ក. រៀនពាក្យ

### ១. ពន្យល់ពាក្យ

- ភារកិច្ច (ភា-រៈ-កិច) (ន.) ៖ កិច្ចការទទួលបន្ទុក កិច្ចធុរៈជាប់រវល់។
- សិទ្ធិ(សិត-ធិ ឬ សិត) (ន.) ៖ អំណាច សេចក្ដីសម្រេច សេចក្ដីសម្រេចតាមអំណាចច្បាប់ ការសម្រេចប្រយោជន៍ មុខការដែលត្រូវសម្រេចលើខ្លួន។
- កេងប្រវ័ញ្ច(កេង-ប្រ-វ៉ាញ់)(កិ.) ៖ បញ្ឆោត បោកប្រាស់ឆបោក។ ឧ.កេងប្រវ័ញ្ចទ្រព្យគេ។
- អាណាព្យាបាល (ន.) ៖ អ្នកគ្រប់គ្រងថែរក្សា។
- រំលោភ (រំ-លោប) (កិ.) ៖ បំពានដោយសេចក្ដីលោភ បំពានបំពារទាំងអំណាច បង្រ្កបលើ ប្រព្រឹត្តល្មើសលើ។ ឧ. រំលោភយកដីគេ រំលោភលើច្បាប់។

### ២.បដិសព្ទ

- ហិង្សា ≠ អហិង្សា
- រីកចម្រើន ≠ អន់ថយ
- រស់ ≠ ស្លាប់


www.elibraryofcambodia.org

៣.ផវចនសព្ទ

- ភារកិច្ច កាតព្វកិច្ច ករណីយកិច្ច
- ប្រទេស នគរ បុរី
- ផ្គត់ផ្គង់ ឧបត្ថម្ភ ផ្ដល់ គាំទ្រ ទំនុកបម្រុង។

៤.សទិសសព្ទ

- ការ (កិ.) ៖ មូរសរសៃសូត្រ ឬសរសៃអំពោះ។ ឧ.ការសូត្រ។
- ការ (កិ.) ៖ រៀបអាពាហ៍ពិពាហ៍។ ឧ. ការកូន ការក្មួយ។
- ការ (ន.) ៖ កិច្ចដែលត្រូវធ្វើ។ ឧ. ការងារ កិច្ចការ។
- ការណ៍ (ន.) ៖ ហេតុ ដំណើរ។ ឧ. របាយការណ៍ ហេតុការណ៍។
- កាណ៌ (ន.) ៖ ត្រចៀក (រាជសព្ទ សង្ឃសព្ទ )។ ឧ. ព្រះកាណ៌។
- កា (ន.) ៖ បំពង់សម្រាប់ដាក់ទឹក។ ឧ. កាទឹក។
- កា (ន.) ៖ សរសេរឈ្មោះ អាសយដ្ឋានលើខ្នងសំបុត្រ។ ឧ. កាខ្នងសំបុត្រ។
- ជា (ន.) ៖ ឈ្មោះពស់មួយប្រភេទមានពិសខ្លាំង កាល នៅតូចហៅពស់ជា លុះធំទ្រើសបន្តិចឡើង ហៅពស់ក្រាយ ដល់ធំអស់ទំហំហៅពស់ វែក។
- ជា (គុ.) ៖ ស្រួល ល្អ សប្បាយ សុខ រួចពីឈឺ ដើបពី ឈឺ។


www.elibraryofcambodia.org

- ជា (ន. ឬគុ.) ៖ ដែលទីទៃពីនៅកំដរទ្រព្យគេ។
ន. មនុស្សអ្នកជា។

## ក. ចម្លើយ

១. កុមារមានភារកិច្ចសំខាន់ក្នុងការទ្រទ្រង់ប្រទេសជាតិ ឱ្យមានការរីកចម្រើន។

២. ដើម្បីឱ្យកុមារសម្រេចភារកិច្ចនេះបានល្អ លុះត្រាតែមាតាបិតាអាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងសហគមន៍ផ្តល់សិទ្ធិពេញលេញដល់កុមារ។

៣. កុមារមានសិទ្ធិបួនយ៉ាងគឺ សិទ្ធិក្នុងការរស់រានមានជីវិត សិទ្ធិក្នុងការការពារ សិទ្ធិក្នុងការចូលរួម និងសិទ្ធិក្នុងការទទួលការអប់រំ។

៤. អត្ថន័យនៃសិទ្ធិនីមួយៗគឺ ៖

- សិទ្ធិក្នុងការរស់រានមានជីវិតមានន័យថា កុមារត្រូវទទួលបាននូវការចិញ្ចឹមបីបាច់ ការថែទាំសុខភាព ការផ្គត់ផ្គង់សម្ភារៈ និងការស្នាក់នៅបានសមរម្យ។ល។
- សិទ្ធិទទួលបានការការពារមានន័យថា ហាមការប្រើកម្លាំងពលកម្ម ការប្រើអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានមកលើកុមារ។
- សិទ្ធិចូលរួមមានន័យថា កុមារមានសិទ្ធិបញ្ចេញមតិយោបល់ចូលរួមក្នុងពិធីផ្សេងៗ និងទទួលយកគំនិតរបស់កុមារ។
- សិទ្ធិក្នុងការទទួលការអប់រំមានន័យថា កុមារមានសិទ្ធិចូលរៀនទទួលបានចំណេះដឹងផ្សេងៗ។


www.elibraryofcambodia.org

វិញ្ញាសាទី ៣

# ធនធានធម្មជាតក្នុងដី

ប្រទេសកម្ពុជាសម្បូរទៅដោយភោគទ្រព្យរ៉ែ។ រ៉ែដែកមាននៅស្រុករវៀង ខេត្តព្រះវិហារ និងភ្នំដី ស្រុកសណ្តាន់ ខេត្តកំពង់ធំ។ បច្ចុប្បន្នក្រុមហ៊ុនចិន កំពុងសង់រោងចក្រស្លដែក នៅចំណុចប្រសព្វនៃខេត្តស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ។ រ៉ែមាសមាននៅស្រុករវៀង ខេត្តព្រះវិហារ ស្រុកអណ្តូងមាស ស្រុកតាវែងខេត្តរតនគិរី ស្រុកថ្មបាំងខេត្តកោះកុង ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។



ត្បូងទទឹម និងត្បូងកណ្តៀងមាននៅបប៉ៃលិន។ ស្រុកបកែវ កូនមុំ និងលំផាត់ ខេត្តរតនគិរី មានត្បូងធម្មជាតិ។ នៅស្រុកគិរីវង់ ខេត្តតាកែវ មានរ៉ែត្បូងមានគុណភាពអន់ជាងនៅប៉ៃលិន និងរតនគិរី។ ត្បូងសម្រាប់ធ្វើគ្រឿងអលង្ការ និងនាំទៅលក់ឯបរទេស។ នៅបាតសមុទ្រ និងបឹងទន្លេសាប មានរ៉ែប្រេងកាតនិងឧស្ម័នធម្មជាតិ។ សព្វថ្ងៃក្រុមហ៊ុនបរទេសកំពុងធ្វើវិនិយោគលើរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិទាំងនោះ។

ភោគទ្រព្យរ៉ែទាំងនេះ ធ្វើឱ្យប្រជាជនយើងមានមោទនភាពជាតិ និងស្រឡាញ់ទឹកដី។ ដូច្នេះ យើងត្រូវមានការប្រុងប្រយ័ត្ន ក្នុងការទាញយកភោគទ្រព្យធម្មជាតិដ៏មានតម្លៃទាំងនេះ។


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ៣

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖ " រ៉ែ ឧស្ម័ន វិនិយោគ មោទនភាព អលង្ការ ភោគទ្រព្យ ធម្មជាតិ " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " អន់ ប្រយ័ត្ន សម្បូរ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ដី សមុទ្រ បច្ចុប្បន្ន " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ចក្រ វង់ " ។

### ខ. សំណួរ

១. តើប្រទេសកម្ពុជាសម្បូររ៉ែអ្វីខ្លះ ? តើរ៉ែទាំងនោះស្ថិតនៅឯណាខ្លះ ?

២. តើសព្វថ្ងៃប្រទេសកម្ពុជាយើង កំពុងរៀបចំចាត់ចែងរ៉ែទាំងនោះ យ៉ាងដូចម្ដេច ?

៣. តើភោគទ្រព្យរ៉ែធ្វើឱ្យប្រជាជនយើង មានទឹកចិត្តដូចម្ដេចចំពោះ មាតុភូមិយើង ?

៤. ហេតុអ្វីបានជាយើង ត្រូវមានការប្រុងប្រយ័ត្នក្នុងការទាញយក ភោគទ្រព្យរ៉ែ ?


www.elibraryofcambodia.org

## កំណែវិញ្ញាសាទី ៣

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- រ៉ែ (ន.) ៖ លោហធាតុផ្សេងៗកើតនៅក្នុងដី ដែលជីកគាស់យកមករំលាយសម្រាំងយកតែសាច់បានជាលោហជាតិតាមកំណើតដើម។
  ឧ. រ៉ែដែក រ៉ែមាស។
- ឧស្ម័ន (អ៊ុស-ស្មាន់) (ន.) ៖ សារធាតុម្យ៉ាងទីទៃពីសារធាតុរឹងនិងរាវមានសណ្ឋានជាខ្យល់សម្រាប់ប្រើប្រាស់ជាឥន្ធនៈ។
- វិនិយោគ (វី-និ-យោក) (ន.) ៖ ការបណ្ដាក់ទុនរកស៊ី។
- មោទនភាព (មោ-ទៈ-នៈ-ភាប) (ន.) ៖ ភាពរីករាយ សេចក្ដីត្រេកអរ សេចក្ដីអរគុណ។
- អលង្ការ (អៈ-លឹង-កា) (ន.) ៖ គ្រឿងប្រដាប់សម្រាប់តុបតែងខ្លួន ( ចិញ្ចៀន ខ្សែដៃ កងដៃ )។
- ភោគទ្រព្យ (ភោក-ទ្រ័ប) (ន.) ៖ វត្ថុ ធនធាន សម្បត្តិដែលមាន។
- ធម្មជាតិ (ធ័ម-មៈ-ជាតិ) (ន.) ៖ ធម៌ សភាវៈ សភាព អ្វីៗដែលកើតឡើងដោយឯកឯង។

២. បដិសព្ទ

- អន់ ≠ ល្អ
- ប្រយ័ត្ន ≠ ប្រហែស
- សម្បូរ ≠ ខ្សត់


www.elibraryofcambodia.org

### ៣. វេវចនសព្ទ

- ដី ពសុធា ប្រឹថពី ធរណី ផែនដី
- សមុទ្រ សាគរ
- បច្ចុប្បន្ន ឥឡូវ ពេលនេះ។

### ៤. សទិសសព្ទ

- ចក្រ (ន.) ៖ កង់ កង់មានកាំ មណ្ឌល រង្វង់មូល។
- ចក្រ (ន.) ៖ អាវុធសណ្ឋានជាវង់មូលមានធ្មេញជាបន្លាជុំវិញ មានមុខមុត។
- ចក្រ (ន.) ៖ ប្រទេស។
- ចក្រ (ន.) ៖ ពួក ហ្វូង។
- ចក្រ (ន.) ៖ កងទ័ព។
- ចក្រ (ន.) ៖ កណ្ដាប់ព័ទ្ធជុំវិញ។
- ចាក់ (កិ.) ៖ ចុះដោយគ្រឿងប្រហារមានមុខស្រួច។ ឧ. ចាក់កជ្រូក។
- ចាក់ (កិ.) ៖ យកអ្វីៗក្រៅអំពីគ្រឿងប្រហារចុះ ឬរុក។ ឧ. ចាក់ក្រឡេក។
- ចាក់ (កិ.) ៖ រលាក់អ្វីមួយចេញពីក្នុងអ្វីមួយដាក់ទៅក្នុង ទៅលើវត្ថុ ឬទីកន្លែងផ្សេង។ ឧ. ចាក់ទឹក ចាក់សំរាម។
- វង់ (កិ.) ៖ ធ្វើជារង្វង់ ធ្វើឱ្យមានមណ្ឌលមូល គូសវាសឱ្យមូល។ ឧ. ឈរវង់។
- វង់ (ន.) ៖ មណ្ឌលមូល ទីលានមូល។ ឧ. ភាសវង់ វង់ខែ។


www.elibraryofcambodia.org

- វង់ (ន.) ៖ ឈ្មោះល្បែងស៊ីសងមួយប្រភេទក្នុងសម័យ
បុរាណ។
- វង្ស (ន.) ៖ ពូជ ជំបូរ ផូរ ត្រកូល ត្រកូល ។

## . ចម្លើយ

១. ប្រទេសកម្ពុជាសម្បូររ៉ែដែក មាស ត្បូងទទឹម ត្បូងកណ្ដៀង ត្បូងធម្មជាតិ រ៉ែប្រេងកាត ឧស្ម័នធម្មជាតិ។ រ៉ែដែកមាននៅស្រុករវៀង ខេត្តព្រះវិហារ និងភ្នំដីស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ រ៉ែមាសមាននៅស្រុករវៀងខេត្តព្រះវិហារ ស្រុកអណ្ដូងមាស ស្រុកតាវែង ខេត្តរតនគិរី ស្រុកថ្មបាំងខេត្តកោះកុង ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ត្បូងទទឹម និងត្បូងកណ្ដៀងមាន នៅខេត្តប៉ៃលិន។ ត្បូងធម្មជាតិមាននៅស្រុកបកែវ កូនមុំ និងលំផាត់ខេត្តរតនគិរី។ នៅស្រុកគិរីវង់ ខេត្តតាកែវ មានរ៉ែត្បូងមានគុណភាពអន់ជាងនៅខេត្តប៉ៃលិន និង ខេត្តរតនគិរី។ នៅបាតសមុទ្រ និងបឹងទន្លេសាបមានរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិ។

២. សព្វថ្ងៃប្រទេសកម្ពុជាយើងកំពុងសហការជាមួយក្រុមហ៊ុនចិនសង់រោងចក្រស្លដែក នៅចំណុចប្រសព្វនៃខេត្តស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ។ ក្រុមហ៊ុនបរទេសកំពុងធ្វើវិនិយោគលើរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិនៅបាតសមុទ្រ និងបឹងទន្លេសាប។

៣. ភោគទ្រព្យរ៉ែធ្វើឱ្យប្រជាជនយើងមានមោទនភាពជាតិ និង ស្រឡាញ់ទឹកដីមាតុភូមិ។

៤. បានជាយើងត្រូវមានការប្រុងប្រយ័ត្ន ក្នុងការទាញយកភោគទ្រព្យរ៉ែ ព្រោះបើយើងយករ៉ែនៅខ្ជី ឬខុសបច្ចេកទេសធ្វើឱ្យហិនហោចខាតបង់ដល់ប្រទេសជាតិនៅថ្ងៃអនាគត។


www.elibraryofcambodia.org

វិញ្ញាសាទី
៤

# រ៉ែប្រេងកាត

តាមអ្នកស្រាវជ្រាវបានឱ្យដឹងថា ប្រេងកាតនៅប្រទេសកម្ពុជាមានរាប់ពាន់បារ៉ែល។ បច្ចុប្បន្ន ក្រុមហ៊ុនវិនិយោគទុនជាច្រើន កំពុងចរចាជាមួយរដ្ឋាភិបាល ដើម្បីបូមប្រេងក្នុងសមុទ្រខ្មែរ។ គេសង់សំណង់បូមប្រេងក្នុងទឹកសមុទ្រ។ គេបុកទម្លុះដីមិនជ្រាបទឹក ដោយឆ្លងកាត់ស្រទាប់ឧស្ម័ន។ នៅពេលគេបុកបំពង់ដល់ឧស្ម័ន គេដឹងថាជិតដល់ស្រទាប់ប្រេងហើយ ដូច្នេះគេមានការប្រុងប្រយ័ត្ន មិនឱ្យការបុកនេះជ្រុលហួសនាំឱ្យប្រេងកាតបាញ់ឡើងខ្លាំងហួសបំពង់បង្ហូរ។ ប្រេងដែលគេបូមពីក្នុងដី ត្រូវហូរចូលបំពង់បង្ហូរទៅកាន់រោងចក្រចម្រាញ់ប្រេងកាត។ គេបានវត្ថុច្រើនប្រភេទពីការចម្រាញ់ប្រេងកាតនៅដូចជា ប្រេងកាតសម្រាប់យន្តហោះ ប្រេងសាំង ប្រេងកាត ប្រេងម៉ាស៊ូត ប្រេងរំអិល និងកាកសំណល់សម្រាប់ក្រាលផ្លូវថ្នល់។




ប្រេងកាតនៅ ឬ " មាសខ្មៅ " មានប្រយោជន៍ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រទេស។ ដូច្នេះ កូនខ្មែរគ្រប់រូបត្រូវចូលរួមថែរក្សាសម្បត្តិធម្មជាតិ ទាំងក្នុងដី ទាំងក្នុងទឹកឱ្យបានគង់វង្សជារៀងរហូត។


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ៤

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖

" រដ្ឋាភិបាល ក្រុមហ៊ុនវិនិយោគទុន ចរចា សេដ្ឋកិច្ច សង្គម " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ឆៅ អភិវឌ្ឍ គង់វង្ស " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ផ្លូវ ខ្មែរ ជិត " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " សង់ គង់ " ។

### ខ. សំណួរ

១. តើក្រុមហ៊ុនវិនិយោគទុនកំពុងចរចាជាមួយរដ្ឋាភិបាលអំពីរឿងអ្វី ?

២. តើគេបូមប្រេងកាតពីក្រោមបាតសមុទ្រយ៉ាងដូចម្តេច ?

៣. តើប្រេងកាតឆៅចម្រាញ់បានជាវត្ថុអ្វីខ្លះ ?

៤. ហេតុអ្វីបានជាយើង ត្រូវថែរក្សាសម្បត្តិធម្មជាតិ ទាំងក្នុងដី ទាំងក្នុងទឹកឱ្យបានគង់វង្ស ?



www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ៤

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- រដ្ឋាភិបាល (រ័ត-ឋា-ភិ-បាល) (ន.) ៖ អ្នកគ្រប់គ្រងរដ្ឋ អ្នកត្រួតត្រាដែន។
- ក្រុមហ៊ុនវិនិយោគទុន (ក្រុម-ហ៊ុន-វិ-និ-យោគ-ទុន) (ន.) ៖ ក្រុមហ៊ុនបណ្ដាក់ទុនរកស៊ី។
- ចរចា (ច-ចា-) (កិ.) ៖ និយាយប្រស្រ័យសំណោះសំណាលរកគ្នា។ ការប្រស្រ័យជាផ្លូវការជាមួយនរណាម្នាក់ដើម្បីទទួលការព្រមព្រៀងអ្វីមួយ។ *ឧ.* គេកំពុងចរចាគ្នា។
- សេដ្ឋកិច្ច (សេត-ឋៈ-កិច) (ន.) ៖ កិច្ចការប្រសើរបំផុត មុខរបរដ៏ឧត្ដម មុខការរបរដែលមានប្រយោជន៍ក្នុងប្រទេសនីមួយៗ។ ប្រព័ន្ធពាណិជ្ជកម្ម និងឧស្សាហកម្មដែលតាមរយៈនោះ គេផលិត ឬប្រើប្រាស់ភោគទ្រព្យរបស់ប្រទេសណាមួយ។ *ឧ.* អភិវឌ្ឍសេដ្ឋកិច្ចជាតិ។


www.elibraryofcambodia.org

- សង្គម (សង់-គំ ឬ សង់-គៈ-មៈ) (ន.) ៖ ការជួបជុំគ្នា ការប្រជុំគ្នា ការរាប់រកគ្នា ការប្រមូលប្របមផ្តុំមនុស្ស ឬសត្វ។ ក្រុមមនុស្សយ៉ាងធំមួយដែលមនុស្សទាំងនោះរស់ជាមួយគ្នាដោយមានអង្គការរៀបចំមួយ ដើម្បីធ្វើការសម្រេចចិត្តក្នុងការធ្វើការងារអ្វីមួយ និងក្នុងការបែងចែកការងារ និងបំពេញការងារនោះឱ្យបានសម្រេច។

  ឧ. សង្គមមនុស្ស សង្គមសត្វ។

២.បដិសព្ទ

- ឆៅ ≠ ឆ្អិន
- អភិវឌ្ឍ ≠ ធ្លាក់ចុះ
- គង់វង្ស ≠ សាបសូន្យ បាត់បង់

៣.ពហុវចនសព្ទ

- ផ្លូវ ថ្នល់ មាគ៌ា វិថី
- ខ្មែរ ខេមរៈ ខេមរា
- ជិត ក្បែរ ហៀប រៀប។

៤.សទិសសព្ទ

- សង់ (កិ.) ៖ ប្រជុំគ្រឿងទព្វសម្ភារៈធ្វើឱ្យកើតបានជាលំនៅ។

  ឧ. សង់ផ្ទះ។


www.elibraryofcambodia.org

- សង្ឃ (ន.) ៖ ពួក ប្រជុំ បន ហ្វូង។ តាមលទ្ធិពុទ្ធសាសនា សំដៅចំពោះពួកភិក្ខុតាំងពី ៤អង្គឡើងទៅ។ ឧ. ជំនុំសង្ឃ។
- គង់ (គុ.) ៖ សល់នៅ។ ឧ. ទ្រព្យគង់។
- គង់ (កិ.) ៖ អង្គុយ។ ឧ. ស្ដេចគង់ក្នុងព្រះពន្លា ព្រះសង្ឃគង់ក្នុងកុដិ។

## ខ. ចម្លើយ

១. ក្រុមហ៊ុនវិនិយោគទុនកំពុងចរចាជាមួយរដ្ឋាភិបាល អំពីរឿងបូមប្រេងកាតក្នុងសមុទ្រខ្មែរ។

២. គេបូមប្រេងកាតពីក្រោមបាតសមុទ្រ ដោយគេសង់សំណង់បូមប្រេងក្នុងទឹកសមុទ្រ។ គេបុកទម្លុះដីមិនជ្រាបទឹក ដោយឆ្លងកាត់ស្រទាប់ឧស្ម័ន។ នៅពេលគេបុកបំពង់ដល់ឧស្ម័ន គេដឹងថាជិតដល់ស្រទាប់ប្រេងហើយ ដូច្នេះគេត្រូវតែមានការប្រុងប្រយ័ត្នដើម្បីកុំឱ្យការបុកនេះជ្រុលហួសនាំឱ្យប្រេងកាតបាញ់ឡើងខ្លាំងហួសបំពង់បង្ហូរ។ ប្រេងដែលគេបូមពីក្នុងដីត្រូវហូរចូលបំពង់បង្ហូរទៅកាន់រោងចក្រចម្រាញ់ប្រេងកាត។

៣. ប្រេងកាតនៅចម្រាញ់បានជាវត្ថុច្រើនប្រភេទដូចជា ប្រេងសម្រាប់យន្តហោះ ប្រេងសាំង ប្រេងកាត ប្រេងម៉ាស៊ូត ប្រេងរំអិល និងកាកសំណល់សម្រាប់ក្រាលផ្លូវថ្នល់។

៤. បានជាយើងត្រូវថែរក្សាសម្បត្តិធម្មជាតិ ទាំងក្នុងដី ទាំងក្នុងទឹកឱ្យបានគង់វង្ស ព្រោះវាមានប្រយោជន៍ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រទេស។


www.elibraryofcambodia.org

វិញ្ញាសាទី

៥

# រ៉ែមាស



អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីបានផ្តល់ព័ត៌មានថា គេបានរកឃើញរ៉ែមាសជាងប្រាំបីលានតោននៅកាទី និងមេម៉ង់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ផ្នែកខ្លះនៃរ៉ែមាសក្នុងស្រុកនេះ បានត្រូវក្រុមហ៊ុនចិនធ្វើវិនិយោគរួចទៅហើយ។ នៅស្រុករវៀង ខេត្តព្រះវិហារក៏មានរ៉ែមាសដែរ។ ប្រជាជននៅទីនោះ យកការរែងមាសជារបរចិញ្ចឹមជីវិត។ គេអាចយករ៉ែមាសបានដោយការលុងដី រហូតដល់គេប្រទះឃើញស្រទាប់ដីជាខ្សែៗ។ គេយកដីទាំងនោះទៅរែង រួចយកទៅធ្វើអគ្គិសនីវិភាគ ដើម្បីបានមាស។ គេត្រូវប្រែក្លាយវាឱ្យទៅជាមាសទឹកដប់សុទ្ធ។ មាសជារូបិយប័ណ្ណសំខាន់ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។


www.elibraryofcambodia.org

ក្នុងនាមកុលបុត្រកុលធីតាខ្មែរ ត្រូវជួយថែរក្សាសម្បត្តិធម្មជាតិទាំងនេះឱ្យគង់វង្សបានយូរអង្វែង ដើម្បីឱ្យប្រទេសជាតិបានរីកចម្រើនឿនលឿនដូចប្រទេសនានា។

## សិក្សាលើមិញ្ញាសាទី ៥

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖

" ពីតិមាន អគ្គិសនីវិភាគ រូបិយប័ណ្ណ កុលបុត្រ កុលធីតា " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " មាសសុទ្ធ រីកចម្រើន ឿនលឿន " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ប្រជាជន ធ្វើ គិរី " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ទេស នាម " ។

### ខ. សំណួរ

១. តើរ៉ែមាសមាននៅខេត្តណាច្រើនជាងគេ ?

២. តើគេធ្វើដូចម្តេច ដើម្បីយកមាសបាន ?

៣. តើគេធ្វើដូចម្តេច ដើម្បីបន្សុទ្ធមាស ?

៤. ចូរស្រង់គុណនាមចង្អុលពីក្នុងអត្ថបទខាងលើ។


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ៥

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ព័ត៌មាន (ព័រ-ត៌-មាន (ន.) ៖ ដំណឹងផ្សេងៗ។
  *ឧ.* ស្តាប់ព័ត៌មានប្រចាំថ្ងៃតាមវិទ្យុ។
- អគ្គិសនីវិភាគ (អ័ក-គិ-សៈ-នី-វិ-ភាគ) (ន.) ៖ ការប្រើចរន្តអគ្គិសនី ដើម្បីញែកសារធាតុសុទ្ធចេញពីសារធាតុផ្សេងៗ។
- រូបិយប័ណ្ណ (រូ-ប៊ិ-យៈ-ប័ន) (ន.) ៖ ប្រាក់ មាស ឬលោហជាតិ ដែលប្រទេសនីមួយៗបញ្ញត្តិឱ្យ ប្រើប្រាស់ជារបស់សម្រាប់ចាយវាយ។
- កុលបុត្រ (កុល់ៈ-បុត) (ន.) ៖ កូនប្រុស។
- កុលធីតា (កុល់ៈ-ធីតា) (ន.) ៖ កូនស្រី។

២.បដិសព្ទ

- មាសសុទ្ធ ≠ មាសក្លែងក្លាយ
- រីកចម្រើន ≠ អន់ថយ
- ជឿនលឿន ≠ អន់ថយ


www.elibraryofcambodia.org

៣.វេវចនសព្ទ

- ប្រជាជន ប្រជាពលរដ្ឋ ប្រជារាស្ត្រ ពលរដ្ឋ រាស្ត្រ ប្រជានិករ
- ធ្វើ អនុវត្ត ប្រតិបត្តិ ប្រព្រឹត្ត
- គិរី ភ្នំ បព្វតា បរពត។

៤.សទិសសព្ទ

- ទេស (ន.) ៖ ភូមិ ទឹកដី ប្រទេស។ ឧ. ស្រុកទេស ។
- ទេស (កិ.) ៖ និយាយ សម្តែង ពន្យល់។ ឧ.លោកទេសគ្រែបី។
- ទេស (កិ.វិ.) ៖ ដែលដើរសាត់អណ្តែត ដើរសាត់ព្រាត់។ ឧ. ដើរទេស ។
- ទេស (ន.) ៖ ឈ្មោះសំពត់សាច់ម៉ដ្ឋច្រើនបែប។ ឧ.ទេសឯកស ។
- ទេស (គុ.) ៖ ដែលធំខ្ពស់មាំ ជំបង។ ឧ. សេះទេស ចំប៉ីទេស។
- ទេស (ន.) ៖ ឈ្មោះគ្រឿងសម្លវិសេសដែលមានក្លិនក្រអូប ប្រហើរ។ ឧ. គ្រឿងទេស ។
- នាម (និ.) ៖ ឈ្មោះថា ហៅថា។ ឧ. ឱអ្នកអើយ ខ្ញុំនាមតែថា " ជង្ហៅ " ទេ សព្វថ្ងៃ ល្បីតែឈ្មោះប៉ុណ្ណោះ រីឯទ្រព្យសម្បត្តិវិនាសអស់ហើយ។
- នាម (ន.) ៖ ឈ្មោះ។ ឧ. នាមខ្លួន នាមត្រកូល ព្រះនាម ទ្រង់ព្រះនាម។


www.elibraryofcambodia.org

- នាម (ន.) ៖ ប្រដាប់នេសាទមច្ឆជាតិ ធ្វើដោយខ្សែថ្មៃ មានក្រឡាបួនជ្រុងស្មើ មានខ្សែដៃពីរ មានថ្មសណ្ដូនជើង មានក្រវិលរួតមាត់ សម្រាប់មនុស្សពីរនាក់ជិះលើ ទូកក្បាលកន្សែកាន់ចុងប្រដាប់នោះម្ខាងម្នាក់ អុំវាតទូកបញ្ចៀងទទឹងខ្សែទឹកបណ្ដោតសំរៀមតាមខ្សែទឹក កាលបើមានត្រីជាប់ ក៏អាចដឹងភ្លាម។ ឧ. នាំគ្នាទៅវាតនាម។

## ខ. ចម្លើយ

១. ខេត្តដែលមានរ៉ែមាសច្រើនជាងគេគឺខេត្តមណ្ឌលគិរី។

២. ដើម្បីយកមាសបានគេត្រូវលុងដី រហូតដល់គេប្រទះឃើញស្រទាប់ដីជាខ្សែៗ។ គេយកដីនោះទៅរែង រួចយកទៅធ្វើអគ្គិសនីវិភាគដើម្បីបានមាស។ គេត្រូវប្រែក្លាយវាឱ្យទៅជាមាសទឹកដប់។

៣. ដើម្បីឱ្យបានមាសសុទ្ធ គេធ្វើអគ្គិសនីវិភាគ។

៤. គុណនាមចង្អុលពីក្នុងអត្ថបទខាងលើ ៖ នេះ នោះ ទាំងនោះ ទាំងនេះ។


www.elibraryofcambodia.org

វិញ្ញាសាទី ៦

# វាសនាបឹងទន្លេសាប



បឹងទន្លេសាបធ្លាប់ល្បីល្បាញថា ជាជង្រុកត្រីនៃប្រទេសកម្ពុជា។ ឥឡូវនេះ អ្នកនេសាទបានត្អូញត្អែរថា ពួកគេនេសាទត្រីមិនបានសោះ។ កត្តាទាំងនេះបណ្ដាលមកពីអំពើអគតិរបស់ជនខ្លះ។ ពួកគេកាប់បំផ្លាញព្រៃលិចទឹកជុំវិញបឹងដែលជាជម្រកត្រីពង និងបន្តពូជដើម្បីយកដីធ្វើ ស្រែចម្ការ។ ម្យ៉ាងទៀត មនុស្សមួយចំនួនបានទៅតាំងលំនៅលើទឹក ដើម្បីប្រកបរបរនេសាទ លក់ដូរ និងធ្វើសិប្បកម្ម។ អ្នកទាំងនោះបានបង្ហូរកាកសំណល់ពីលំនៅស្ថាន និងរោងសិប្បកម្មដែលមានជាតិពុលទៅក្នុងបឹងរាល់ថ្ងៃ ធ្វើឱ្យទឹកបឹងកខ្វក់ ហើយរាក់ទៅៗ។ ពិសេសទៅទៀត អ្នកខ្លះមានមហិច្ឆតាខ្លាំងពេក បានប្រើនេសាទុបករណ៍ដូចជា អួន មង សំណាញ់ដែលមានក្រឡាញឹកដើម្បីចាប់ត្រី ហើយជនល្មើសច្បាប់ខ្លះទៀតបានប្រើ


www.elibraryofcambodia.org

ឧបករណ៍ឆក់ត្រី ធ្វើឱ្យត្រីតូចធំដាប់គ្មានសល់។ កត្តាទាំងនេះហើយ ដែលធ្វើឱ្យធនធានផលផលរបស់យើងចេះតែខ្សត់ទៅៗ។ បើធ្វើយ៉ាងនេះ បច្ឆាជាតិនៅក្នុងបឹងទន្លេសាប មុខជាវិនាសសាបសូន្យមិនខានឡើយ។

## សិក្សាឈើមិញ្ញាសាទី ៦

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖ " ជង្រុក កត្តា អគតិ សិប្បកម្ម មហិច្ឆតា នេសាទុបករណ៍ ផលផល ធនធាន សាបសូន្យ " ។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " ល្មើសច្បាប់ អគតិ សាបសូន្យ " ។
៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " លំនៅស្ថាន ភ្លើង ងាប់ " ។
៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " សាប ផល " ។

### ខ. សំណួរ

១. ចំណុចណាជាភាពល្បីល្បាញរបស់បឹងទន្លេសាប ?
២. តើក្នុងពេលឥឡូវនេះ អ្នកនេសាទត្អូញត្អែរដូចម្ដេច ?
៣. តើអំពើអគតិអ្វីខ្លះ ដែលបង្កសេចក្ដីអន្តរាយដល់បឹងទន្លេសាប ?
៤. បើតាមគំនិតអ្នកផ្ទាល់ តើត្រូវធ្វើដូចម្ដេចដើម្បីឱ្យបឹងទន្លេសាបសម្បូរត្រីឡើងវិញ ?


www.elibraryofcambodia.org

## អំណានទី ៦

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ជង្រុក (ជង់-រុក) (ន.) ៖ កន្លែងដែលគេសង់ឡើងសម្រាប់ទុកដាក់ស្រូវ។ កន្លែងដែលសម្បុរអ្វីមួយ។
- កត្តា (ក័ត-តា) (ន.) ៖ អ្នកធ្វើ អ្នកផ្ដើមធ្វើ ហេតុដែលនាំឱ្យកើតអ្វីមួយ។
- អគតិ (អៈ-គៈ-តិ) (ន.) ៖ ការពុំគួរប្រព្រឹត្ត សេចក្ដីលម្អៀង។
- សិប្បកម្ម (សិប-ប៉ៈ-កាំ) (ន.) ៖ ការជាងផ្សេងៗ ជំនាញហត្ថកម្មគ្រប់យ៉ាង ចំណេះដែលត្រូវសិក្សាមានការជាងឈើ ការឆ្លាក់គូរជាដើម។
- មហិច្ឆតា (ម-ហិច-ឆៈតា) (ន.) ៖ សេចក្ដីប្រាថ្នាធំ ការចង់បានច្រើន សេចក្ដីលោភលន់។
- នេសាទុបករណ៍ (នេ-សាត-ទុប-ប៉ៈ-ក) (ន.) ៖ ឧបករណ៍ ឬសម្ភារៈផ្សេងៗសម្រាប់ធ្វើនេសាទ។ *ឧ.* អូន មងសំណាញ់។
- ផលផល (ផល់-ផល់) (ន.) ផលដែលកើតមាននៅក្នុងទឹក។
- ធនធាន (ធន់-ធាន) (ន.) ៖ ទ្រព្យរបស់ផ្សេងៗដែលគង់នៅ។ *ឧ.* គេមានធនធានច្រើន។
- សាបសូន្យ (សាប-សូន) (កិ.វិ.) ៖ ដែលលែងមាន ដែលលែងកើតឡើង ។


www.elibraryofcambodia.org

២.បដិសព្ទ

- ល្មើសច្បាប់ ≠ ស្របច្បាប់
- អតីត ≠ អនាគត គតិ
- សាបសូន្យ ≠ គង់វង្ស

៣.វេវចនសព្ទ

- លំនៅស្ថាន ផ្ទះ គេហដ្ឋាន កុដិ រាជដំណាក់
- ភ្លើង អគ្គិ អគ្គី
- ងាប់ ស្លាប់ ក្ស័យ មរណៈ មរណា មរណកាល មរណភាព អនិច្ចកម្ម អនិច្ចធម្ម សុគត ចូលទិវង្គត សោយទិវង្គត។

៤.សទិសសព្ទ

- សាប (កិ.) ៖ បាចគ្រាប់ស្រូវពូជដែលត្រាំហើយ ទៅក្នុងទីថ្នាលដើម្បីឱ្យដុះជាសំណាប។ ឧ. ខ្ញុំសាបបានពីរថ្នាលហើយ។
- សាប (ន.) ៖ នេសាទុបករណ៍មួយប្រភេទ ត្បាញដោយបន្ទោះមូលតូចៗ សម្រាប់ដាក់ឱ្យត្រីមច្ឆជាតិល្អិត។
- សាប (គុ.) ៖ ដែលឥតប្រៃ។ ឧ. ទឹកសាប។
- សាប (គុ.) ៖ ដែលមិនសូវប្រៃ ដែលមានរសប្រៃតិចៗ មិនល្មមដល់ការប្រកប។ ឧ. សម្លសាប។


www.elibraryofcambodia.org

- សាប (គុ.) ៖ ដែលឥតតម្លៃ ដែលអស់អំណាច អស់ពូកែ។
  ឧ.សម្ដីសាប សាបអំណាច មន្តអាគមសាប។
- សាប (គុ.) ៖ ដែលអស់រសជាតិដើមហើយ។ ឧ. ផឹកថ្នាំមិនទាន់សាបមួយឆ្នាំងផង ប្រញាប់តែនឹងលែង។
- សាប (គុ.) ៖ ដែលឥតរសជាតិខ្លាំង។ ឧ. ថ្នាំសាប (សម្រាប់ចុក ឬស៊ីស្លា)។
- ជល (ន.) ៖ ទឹក ប្រើរៀងខាងចុងសព្ទដទៃខ្លះ។
  ឧ. អស្សុជល (ទឹកភ្នែក)។
- ជល (ន.) ៖ ទឹក ប្រើខាងដើមសព្ទដទៃខ្លះ។ ឧ. ជលដ្ឋាន (ទីតម្កល់ទឹក ទីដែលគេទប់ខាំងទឹកទុក ស្រះអណ្ដូង)។
- ជល់ (កិ.) ៖ ទង្គិច ទង្គុក ប៉ះត្រូវ ចំពប់។ ឧ. ជល់ដៃជល់ជើង។
- ជល់ (កិ.) ៖ ប្រយុទ្ធគ្នាដោយស្នែង ដោយក្បាល ដោយចំពុះ។ ឧ. គោជល់គ្នា។
- ជល់ (កិ.) ៖ កប ត្រូវ ទទួល។ ឧ. ដាក់ថ្នាំជល់ ដាក់ថ្នាំមិនជល់។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. បឹងទន្លេសាបធ្លាប់ល្បីល្បាញថា ជាជង្រុកត្រីនៃប្រទេសកម្ពុជា។

២. អ្នកនេសាទបានត្អូញត្អែរថា ពួកគេនេសាទត្រីមិនបានសោះៗ

៣. អំពើអគតិ ដែលបង្កសេចក្ដីអន្តរាយដល់បឹងទន្លេសាបគឺពួកគេកាប់បំផ្លាញព្រៃលិចទឹកជុំវិញបឹង ដែលជាជម្រកត្រីពងនិងបន្តពូជ ដើម្បីយកដីធ្វើស្រែចម្ការ។ ម្យ៉ាងទៀត មនុស្សមួយចំនួនបានទៅតាំងទីលំនៅលើទឹកដើម្បីប្រកបរបរ នេសាទ លក់ដូរ និងធ្វើសិប្បកម្ម។ អ្នកទាំងនោះ បានបង្ហូរកាកសំណល់ពីលំនៅស្ថាន និងរោងសិប្បកម្ម ដែលមានជាតិពុលទៅក្នុងបឹងរាល់ថ្ងៃ ធ្វើឱ្យទឹកបឹងកខ្វក់ហើយរាក់ទៅៗ។ ពិសេសទៅទៀត អ្នកខ្លះមានមហិច្ឆតាខ្លាំងពេកបានប្រើនេសាទុបករណ៍ដូចជា អួន មង សំណាញ់ ដែលមានក្រឡាញឹកដើម្បីចាប់ត្រី ហើយជនល្មើសច្បាប់ខ្លះទៀតបានប្រើឧបករណ៍ឆក់ត្រី ធ្វើឱ្យត្រីតូចធំងាប់គ្មានសល់។

៤. បើតាមគំនិតខ្ញុំផ្ទាល់ ដើម្បីឱ្យបឹងទន្លេសាបសម្បូរត្រីឡើងវិញគឺ កុំកាប់បំផ្លាញព្រៃលិចទឹកជុំវិញបឹង ដែលជាជម្រកត្រីពងនិងបន្តពូជ។ ជៀសវាងការតាំងលំនៅលើទឹក ដើម្បីប្រកបរបរ នេសាទ លក់ដូរ និងធ្វើសិប្បកម្ម។ ជៀសវាងបង្ហូរកាកសំណល់ និងជាតិពុលផ្សេងៗទៅក្នុងបឹង ដែលនាំឱ្យទឹកបឹងកខ្វក់ ហើយរាក់ទៅៗ។ ពិសេសទៅទៀត ហាមឃាត់ការនេសាទដោយនេសាទុបករណ៍ខុសច្បាប់ ដូចជា អួន មង សំណាញ់ ដែលមានក្រឡាញឹក ការប្រើខ្សែភ្លើងឆក់ត្រី ធ្វើឱ្យត្រីតូចធំងាប់គ្មានសល់។



www.elibraryofcambodia.org

វិញ្ញាសាទី ៧

# ពិធីបំបួសនាគ



ពីបុរាណ ខ្មែរយើងនិយមឱ្យកូនចៅបួសជាព្រះសង្ឃ។ មុននឹងបួស គេត្រូវប្រារព្ធធ្វើពិធីមួយហៅថាពិធីបំបួសនាគ។ ក្នុងពិធីនេះ គេធ្វើបាយសីពីដើមចេកហៅថា បាយសីខ្នាន់នាគ ឬបាយសីព្រលឹងនាគ។ ពេលរសៀលមាន ពិធីចម្រើនព្រះ បរិត្តនិងទេសនា ពិធីហៅព្រលឹងនាគ ពិធីធ្វើធ្មេញនាគ ពិធីឱ្យចំណីនាគ និងពិធីបង្វិលពពិល។ ព្រឹកឡើង គេដង្ហែនាគចេញពីផ្ទះទៅកាន់វត្ត។ នាគជិះសេះឬគោ ស្លៀកសំពត់ឆ្នូតពីក្នុងស្លៀកហូលពីក្រៅ មិនពាក់អាវទេ តែពាក់ក្រមាពណ៌សព័ទ្ធឆៀងលើស្មាឆ្វេង។ ក្បួនដង្ហែមានភ្លេងឆៃយ៉ាំ និងភ្លេងពិណពាទ្យហែប្រទក្សិណព្រះវិហារបីជុំ។ នៅចុងបញ្ចប់ នាគថយទៅស្លៀកស្បង់ចីវរ រួចកាន់ទៀនធូបចូលទៅថ្វាយបង្គំព្រះឧបជ្ឈាយ៍ សូត្រសុំត្រៃសរណគមន៍ និងសីលដប់ រួចសូត្រសុំនិស្ស័យ។ គ្រូឧបជ្ឈាយ៍សូត្រប្រៀនប្រដៅ ប្រាប់វិន័យសង្ឃដល់នាគ។


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ៧

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖ " នាគ ខ្ទាន់នាគ ចីវរ ពតិល ព្រះបរិក្ខ ពានា ប្រទក្សិណា ឧបជ្ឈាយ៍ ត្រៃសរណាគមន៍ " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " បុរាណ ចុង មុន " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ធ្មេញ ឯត តោ " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ផូរ ទេ " ។

### ខ. សំណួរ

១. តើគេត្រូវធ្វើអ្វីខ្លះមុននឹងបួស ?

២. តើគេត្រូវរៀបចំសម្ភារៈអ្វី ក្នុងពិធីបំបួសនាគ ?

៣. តើគេធ្វើពិធីអ្វីខ្លះក្នុងដំណើរការបំបួសនាគ ?

៤. តើគេធ្វើដូចម្ដេចខ្លះនៅចុងបញ្ចប់នៃពិធីបំបួសនាគ ?


www.elibraryofcambodia.org

## អំណានទិញ្ញាសាទី ៧

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- នាគ (នាក) (ន.) ៖ ប្រសើរ ចម្បង បរិសុទ្ធ ពស់ដែលមានអានុភាពចម្បង។
- ខ្នាន់នាគ (ខ្នាន់-នាក) (ន.) ៖ ព្រលឹង សិរីមង្គល សេចក្ដីចម្រើន កិច្ចហៅព្រលឹងនាគក្នុងពិធីបួស (តាមក្បួនព្រាហ្មណ៍)។
- ចីវរ (ចី-វ៉) (ន.) ៖ គ្រឿងស្លៀកដណ្ដប់សម្រាប់អ្នកបួសក្នុងព្រះពុទ្ធសាសនា។
- ពពិល (ន.) ៖ ប្រដាប់ដោយលោហជាតិ មានសណ្ឋានស្រដៀងនឹងស្លឹកពោធិ៍សម្រាប់បិទទៀនអុជកាន់ហុចបន្តគ្នាបង្វិល បក់ផ្សែងចូលជុំវិញមនុស្ស ឬរបស់អ្វី ដើម្បីឱ្យកើតស្រីសួស្ដី។ ឧ. បង្វិលពពិល។
- ព្រះបរិត្ត (ព្រះ-ប៉ៈ-រិត) (ន.) ៖ ធម៌សម្រាប់ការពារសេចក្ដីអន្តរាយ។
- ពានា (កិ.) ៖ យកសំពត់គ្របដណ្ដប់ព័ទ្ធឡៀងស្នាម្ខាង។
- ប្រទក្សិណ ( ប្រ-ទ័ក-សិន) (ន.) ៖ ការសម្ដែងសេចក្ដីគោរព ឬសេចក្ដីស្រឡាញ់ដោយដើរជុំវិញ បុគ្គល ឬវត្ថុអ្វីៗ ឱ្យបុគ្គលឬវត្ថុនោះនៅខាងស្ដាំដៃ។


www.elibraryofcambodia.org

- ឧបជ្ឈាយ៍ (អ៊ុ-ប័ច-ឈា) (ន.) ៖ គ្រូបង្រៀនធម៌ គ្រូបង្រៀនច្បាប់។
- ត្រៃសរណគមន៍ (ត្រៃ-ស:-រ៉:-ណា:-គំ) (ន.) ៖ វត្ថុជាទីពឹងរលឹកទាំង៣ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ(ពុទ្ធសាសនា)។

២.បដិសព្ទ

- បុរាណ ≠ ទំនើប
- ចុង ≠ គល់ ដើម
- មុន ≠ ក្រោយ

៣.វេវចនសព្ទ

- ធ្មេញ ទន្ត ព្រះទន្ត
- ងូត ស្រង់
- គោ ឧសភ: ឧសភា។

៤.សទិសសព្ទ

- ជួរ (ន.) ៖ របៀបរៀបរៀងតគ្នា។
- ជូ (គុ.) ៖ ដែលអាក្រក់ ដែលឆ្គងមិនសូវស្គាល់ក្ដីគួរសម។
- ទេ (និ.) ៖ ពាក្យបដិសេធជាទំនាស់ផ្ទុយគ្នានឹងពាក្យ ថា យល់ព្រម។
- ទេរ (គុ.) ៖ ដែលទ្រេត ជ្រេ ជ្រាល។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. មុននឹងបួស គេត្រូវប្រារព្ធធ្វើពិធីមួយហៅថាពិធីបំបួសនាគ។

២. គេត្រូវរៀបចំធ្វើបាយសីពីដើមចេកហៅថា បាយសីខ្វាន់នាគ ឬ បាយសីព្រលឹងនាគ។

៣. ក្នុងដំណើរការបំបួសនាគ នៅពេលរសៀលមានពិធីចម្រើនព្រះបរិត្ត និងទេសនា ពិធីហៅព្រលឹងនាគ ពិធីធ្វើធ្មេញនាគ ពិធីឱ្យចំណីនាគ និងពិធីបង្វិលពពិល។ ព្រឹកឡើង គេដង្ហែនាគចេញពីផ្ទះទៅកាន់វត្ត។ នាគជិះសេះឬគោ ស្លៀកសំពត់ឯតពីក្នុង ស្លៀកហូលពីក្រៅ មិនពាក់អាវទេ តែពាក់ក្រមាពណ៌សព័ទ្ធឆៀងលើស្មាឆ្វេង។ ក្បួនដង្ហែមានភ្លេងឆៃយ៉ាំ និងភ្លេងពិណពាទ្យហែប្រទក្សិណព្រះវិហារបីជុំ។

៤. នៅចុងបញ្ចប់នៃពិធីបំបួសនាគគឺ នាគថយទៅស្លៀកស្បង់ចីវរ រួចកាន់ទៀនធូបចូលទៅថ្វាយបង្គំព្រះឧបជ្ឈាយ៍ សូត្រសុំត្រៃសរណគមន៍ និងសីលដប់ រួចសូត្រសុំនិស្ស័យ។ គ្រូឧបជ្ឈាយ៍សូត្រប្រៀនប្រដៅ ប្រាប់វិន័យសង្ឃដល់នាគ។


www.elibraryofcambodia.org

# របាំក្ងោក



របាំក្ងោក ជារបាំមួយដែលប្រជាជនតំបន់ប៉ៃលិននិយមលេង។ អ្នកសម្ដែងរបាំនេះ មានគ្នាពីរនាក់គឺ ម្នាក់ដើរតួជាក្ងោក និងម្នាក់ទៀតដើរតួជាព្រានព្រៃ។ ក្នុងការសម្ដែង ដំបូងគេវាយស្គរ រួចវង់ភ្លេងទាំងមូលចាប់ប្រគំឡើង។ បន្ទាប់មក អ្នកដើរតួក្ងោកអង្គុយលុតជង្គង់នៅលើតុមួយខ្ពស់ ដៃទាំងពីរប្រណម្យ ទំនងជាកំពុងភាវនាធម៌។ បន្ទាប់មកទៀត ក្ងោកលោតចុះមកដីធ្វើកាយវិការពាំផ្ទៃលរេចុះ រេឡើងតាមចង្វាក់ភ្លេងមានសណ្ឋានដូចក្ងោក។ បន្ទាប់ពីនោះ ព្រានព្រៃដើរលោតៗជាចង្វាក់រាំ ធ្វើកាយវិការភ្ញាក់ៗ រួចទុចង៉ក់ព្រោះឃើញក្ងោក។ ព្រានលើកស្នាបាញ់ក្ងោក តែបាញ់មិនត្រូវ។ ចុងបញ្ចប់ ព្រានឃើញក្ងោកភ្លេចខ្លួន ក៏លបបាញ់ម្ដងទៀត តែ


www.elibraryofcambodia.org

នៅតែបាញ់មិនត្រូវ។ ចំណែកក្មេង ត្រូវផ្លាស់ប្តូរបទតាមឆាកដូចជា ពេលក្រោកពេញពង់ ក្មេងលេងចង្វាក់ឃឹតបង្ហូសៗ ពេលគ្រានចេញ ក្មេងរោទ៍ញាប់គួរឱ្យរន្ធត់។

## សិក្សាលើនិញ្ញាសាទី ៨

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ៖

" ប្រណាម្យ ភាវនាធម៌ ពង់ ឆាក រន្ធត់ "។

២. ចូររកបដិសព្ទនឹងពាក្យ៖ " ដំបូង បញ្ចប់ ខ្ពស់ "។

៣. ចូររកវេវចនសព្ទនឹងពាក្យ៖ " ពីរ ក្មេង ប្រគំ "។

៤. ចូររកសទិសសព្ទនឹងពាក្យ៖ " គួរ បទ "។

### ខ. សំណួរ

១. តើអត្ថបទខាងលើនិយាយអំពីអ្វី ?

២. តើគេសម្តែងរបាំក្រោកដូចម្តេចខ្លះ ?

៣. ចូរស្រង់នាមឱ្យបានប្រាំពាក្យពីក្នុងអត្ថបទខាងលើ ?

៤. ចូរស្រង់កិរិយាឱ្យបានប្រាំពាក្យពីក្នុងអត្ថបទខាងលើ ?


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ៨

## ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ប្រណម្យ (ប្រ-ណំ) (កិ.) ៖ លើកកម្បង់អញ្ជលីសំពះ។
- ភាវនាធម៌ (ភា-វៈ-នា-ធ័រ) (ន.) ៖ ការចម្រើនធម៌ ការនឹកចំពោះត្រង់អារម្មណ៍ល្អតែមួយដដែលៗឱ្យច្រើនៗ គឺនឹកហើយនឹកទៀតរឿយៗជាអនេក ការរំពឹងស្មឹងស្មាធ៌។
- ពង់ (ន.) ៖ ចំកោង ចំអឹត។ *ឧ.* ក្អោកពង់។
- ឆាក (ន.) ៖ ឆាកគឺជាសាច់រឿងដែលជាផ្នែកមួយនៃឈុត។ កាលណាមានការផ្លាស់ប្តូរ បន្ថែម ឬបន្ថយតួអង្គក្នុងការសម្តែងនោះក៏មានការផ្លាស់ប្តូរឆាកថ្មីផងដែរ។
- រន្ធត់ (រន់-ធត់) (ន.) ៖ ភ័យស្លុត។ *ឧ.* ខ្ញុំមិនរន្ធត់ទេ។ គុ. ឬ កិ.វិ. ៖ ដែលភ័យស្លុត។ *ឧ.* ចិត្តរន្ធត់។

២.បដិសព្ទ

- ដំបូង ≠ ចុងក្រោយ
- បញ្ចប់ ≠ ចាប់ផ្តើម
- ខ្ពស់ ≠ ទាប

៣.វេវចនសព្ទ

- ពីរ ទ្វេ ត្វ ទ្វី
- ភ្លេង តន្ត្រី
- ប្រគំ លេង។


www.elibraryofcambodia.org

៤. សទិសសព្ទ

- ត្ងួរ (គុ.) ៖ សម គប្បី ឥតទាស់។ ឧ. ចេះគួរសម។
- ក្ងួរ (ន.) ៖ សំណុំផ្លែ។ ឧ. ក្ងួរស្រូវ។
- បទ (ន.) ៖ ឧបាយ រឿង ហេតុ ទំនង ដំណើរ ដើមទង។
- បទ (ន.) ៖ លំនាំ នៃសំឡេងដែលគេសូត្រឬច្រៀង។
- បទ (និ.) ៖ ចង្អុលប្រាប់ពាក្យ បទ។ ឧ. ឯងខឹងលោភចាក់ដោយចិត្តបទបានស្រា។
- បត់ (កិ.) ៖ ត្រឡប់តាមទំនង តាមផ្លូវដដែលមកវិញ ត្រឡប់ប្រសព្វមុខ។
- បត់ (គុ.) ៖ ដែលបត់ពង់ពេន ដែលវៀចពេនព័ទ្ធជាល្បត់។ ឧ. ផ្លូវបត់បែន។

## ខ. ចម្លើយ

១. អត្ថបទខាងលើនិយាយអំពី របៀបសម្ដែងរបាំក្ងោក។

២. ការសម្ដែងរបាំក្ងោកមានគ្នាពីរនាក់គឺ ម្នាក់ដើរតួជាក្ងោក និងម្នាក់ទៀតជាព្រានព្រៃ។ ក្នុងការសម្ដែង ដំបូងគេវាយស្គរ រួចវង់ភ្លេងទាំងមូលចាប់ប្រគំឡើង។ បន្ទាប់មក អ្នកដើរតួក្ងោកអង្គុយលុតជង្គង់នៅលើតុមួយខ្ពស់ ដៃប្រណាម្យ។ បន្ទាប់មកទៀត ក្ងោកលោតចុះមកដីធ្វើកាយវិការរាំផ្ងើលរេចុះរេឡើងតាមចង្វាក់ភ្លេងមានសណ្ឋានដូចក្ងោក។ បន្ទាប់ពីនោះ ព្រានព្រៃដើរលោតៗជាចង្វាក់រាំ ធ្វើកាយវិការភ្ញាក់ៗ រួចទុចង៉ក់ព្រោះឃើញក្ងោក។ ព្រានលើកស្នាបាញ់ក្ងោកតែបាញ់មិនត្រូវ។ ចុងបញ្ចប់ ព្រានឃើញក្ងោកភ្លេចខ្លួនក៏លបបាញ់ម្ដងទៀត តែនៅតែបាញ់មិនត្រូវ។ ចំណែកភ្លេង ត្រូវផ្លាស់ប្ដូរបទតាមឆាកដូចជា ពេលក្ងោកចេញពង់ ភ្លេងលេងចង្វាក់យឺតបង្ហួសៗ។ ពេលព្រានចេញ ភ្លេងរោទិ៍ញាប់គួរឱ្យរន្ធត់។

៣. ស្រង់នាមពីក្នុងអត្ថបទប្រាំពាក្យ ៖ ព្រានព្រៃ ក្ងោក ស្គរ ភ្លេង ស្នា។

៤. ស្រង់កិរិយាពីក្នុងអត្ថបទប្រាំពាក្យ ៖ ដើរ ប្រគំ លោត វាយ រាំ។


www.elibraryofcambodia.org

វិញ្ញាសាទី ៩

# របាំត្រុដិ



របាំត្រុដិជារបាំប្រពៃណីមួយ ដែលគេឃើញមាននៅក្នុងខេត្តសៀមរាប និងខេត្តខ្លះមានព្រំប្រទល់ជាប់នឹងខេត្តនេះ។ របាំនេះ មានតួសម្តែងច្រើន និងឧបករណ៍ភ្លេងក៏ច្រើន។

ពាក្យ " ត្រុដិ " ជាភាសាសំស្ក្រឹតប្រែថា ផ្តាច់ឬកាត់ផ្តាច់ គឺសំដៅដល់ការផ្តាច់ឆ្នាំ ឬការកាត់ឆ្នាំចាស់ចូលទៅក្នុងឆ្នាំថ្មី។ អាស្រ័យហេតុនេះទើបគេច្រើនលេងរបាំត្រុដិនៅពេលចូលឆ្នាំខ្មែរ ដើម្បីជូនពរសព្ទសាធុការជ័យមង្គលដល់អ្នកស្រុកក្នុងឱកាសចូលឆ្នាំថ្មី។ ប៉ុន្តែពេលខ្លះ គេលេងរបាំនេះសុំទឹកភ្លៀងនៅពេលជួបគ្រោះរាំងស្ងួតផងដែរ។ របាំត្រុដិកើតចេញពីជនជាតិសំរែដែលរស់នៅក្បែរជើងភ្នំគូលែន និងនៅភាគខាងជើងបឹងទន្លេសាប ហើយបានចូលរស់នៅលាយជាមួយខ្មែរនៅម៉ុំអង្គរវត្ត។


www.elibraryofcambodia.org

តាមពាក្យតំណាលសម័យបុរាណ របាំត្រុដិរបស់ជនជាតិសំរែប្រារព្ធឡើងជារៀងរាល់ឆ្នាំដើម្បីថ្វាយព្រះពរសិរីសួស្តីជ័យមង្គលដល់ ព្រះរាជាខ្មែរដែលគង់នៅក្រុងអង្គរ។

## សិក្សាលើវិញ្ញាសាទី ៩

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖
" ឧបករណ៍ សំស្លឹក សំរែ សព្ទសាធុការ ជ័យ " ។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " មង្គល រាំង សួត " ។
៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ប្រារព្ធ ខាងជើង សិរី " ។
៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " នៅ ព្រំ " ។

### ខ. សំណួរ

១. តើរបាំត្រុដិមានប្រភពមកពីជនជាតិអ្វី ? នៅខេត្តណា ?
២. តើពាក្យ " ត្រុដិ " មានអត្ថន័យដូចម្តេច ?
៣. តើគេលេងរបាំត្រុដិនៅពេលណា ? លេងដើម្បីអ្វី ?
៤. ចូរស្រង់រាជសព្ទឱ្យបានបួនពាក្យពីក្នុងអត្ថបទខាងលើ។


www.elibraryofcambodia.org

## អំណានវិជ្ជាសាទី ៩

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ឧបករណ៍ (អ៊ុ-ប:-ក) (ន.) ៖ គ្រឿងប្រើប្រាស់ សេចក្ដីទំនុកបម្រុង ការជួយទប់ទល់គ្នា គ្រឿងប្រកបផ្សំគ្នា។
- សំស្ក្រឹត (ស័ង-ស្ក្រិត ឬ ស័ង-ស:-ក្រិត) (ន.) ៖ ពាក្យសម្រាំង ភាសាសម្រាំង ឈ្មោះភាសាដើមដំបូងបំផុតរបស់ពួកហិណ្ឌូ លុះចំណេរកាលតៗមកដរាបដល់សម័យបច្ចុប្បន្ននេះ សំស្ក្រឹតក្លាយជាមរតកភាសា (ភាសាស្លាប់) ព្រោះមិនមានជនជាតិណាមួយប្រើជាសម្ដីសម្រាប់ជាតិរបស់ខ្លួនដោយគ្រប់គ្រាន់ឡើយ (ប្រើខ្លះបន្តិចបន្តួច) គ្រាន់តែទុកជាមូលភាសា ឬប្រើកត់ត្រាគម្ពីរក្បួនច្បាប់ប៉ុណ្ណោះ។
- សំរែ (កិ.) ៖ ឈ្មោះជនជាតិភាគតិចមួយក្រុម នៅក្នុងប្រទេសកម្ពុជាយើង។
- សព្ទសាធុការ (ស័ប-សា-ធុ-កា) (ន.) ៖ សូរសព្ទថា សាធុ ! សូរស្រែកឱ្យពរ។
- ជ័យ (ជៃ) (ន.) ៖ ជម្នះ ការឈ្នះ។ ឧ. មានជ័យ ហោយកជ័យ។



www.elibraryofcambodia.org

២.បដិសព្ទ

- មង្គល ≠ អពមង្គល
- ភាំង ≠ ភ្លៀង
- ស្ងួត ≠ សើម

៣.ពាក្យចនសព្ទ

- ប្រារព្ធ តាំងផ្ដើម ផ្ដួចផ្ដើម ចាប់ផ្ដើម ប្រុងប្រៀប តិតដល់ ចំពោះ នឹកភ្នកដល់។
- ខាងជើង ឧត្តរ។
- សិរីសួស្ដី ស្រីសួស្ដី មង្គល ជោគ លាភ តេជះ អំណាច បុណ្យ សេចក្ដីសុខ។

៤.សទិសសព្ទ

- នៅ (កិ.) ៖ ឋិត ស្ថិត មាន។ *ឧ.* នៅឯណា ? នៅផ្ទះ នៅក្នុងបន្ទប់។
- នៅ (កិ.វិ.) ៖ ដែលមិនទាន់ ដែលមានទៀត។ *ឧ.* អស់ហើយឬនៅ។
- នូវ (និ.) ៖ នឹង ហើយនឹង។ *ឧ.* ព្រះរាជវង្សានុវង្ស និងមន្ត្រីធំតូច នូវអស់ប្រជាជនទាំងពួង។
- នូវ (អា.និ.) ៖ ពាក្យប្រាប់ដំណើរសម្រេចអំពើដែលគេត្រូវធ្វើ។ *ឧ.* បុគ្គលធ្វើនូវអំពើល្អ ដោយកាយ វាចាចិត្តនឹងបាននូវផលល្អ។
- ព្រំ (កិ.) ៖ បិទភ្ជិតត្រង់កន្លែងក្បាលកណ្ដាបឬក្បឿង។ *ឧ.* ព្រំផ្ទះ ព្រំសាលារៀន។


www.elibraryofcambodia.org

- ព្រំ (ន.) ៖ ចារិកដី ទីបំផុតដែនប្រទល់គ្នា។ *ឧ.* ព្រំដែន ព្រំប្រទល់ ។
- ព្រំ (ន.) ៖ ឈ្មោះកម្រាលពិសេសមួយប្រភេទ មានក្បាច់រចនាមានច្រើនបែប ច្រើនមកពីបរទេសសម្រាប់ក្រាលលម្អ។ *ឧ.*កម្រាលព្រំ។
- ព្រហ្ម (ន.) ៖ ឈ្មោះទេវតាកើតនៅព្រហ្មលោក សេចក្ដីចម្រើន សេចក្ដីប្រសើរ។
  *ឧ.* ព្រះព្រហ្ម ឋានព្រហ្ម ។

## ខ. ចម្លើយ

១. របាំត្រុដិមានប្រភពមកពីជនជាតិសំរែ នៅខេត្តសៀមរាប និងខេត្តខ្លះមានព្រំប្រទល់ជាប់នឹងខេត្តនេះ។
២. ពាក្យ " ត្រុដិ " ជាភាសាសំស្ក្រឹតប្រែថា ផ្ដាច់ ឬកាត់ផ្ដាច់ គឺសំដៅដល់ការផ្ដាច់ឆ្នាំ ឬការកាត់ឆ្នាំចាស់ចូលទៅក្នុងឆ្នាំថ្មី។
៣. គេលេងរបាំត្រុដិនៅពេលចូលឆ្នាំខ្មែរដើម្បីជូនពរសព្ទសាធុការជ័យមង្គលដល់អ្នកស្រុកក្នុងឱកាសចូលឆ្នាំថ្មី។ ប៉ុន្តែពេលខ្លះ គេលេងរបាំនេះ ដើម្បីសុំទឹកភ្លៀង នៅពេលជួបគ្រោះរាំងស្ងួតផងដែរ។ តាមតំណាលសម័យបុរាណ វង់ត្រុដិរបស់ជនជាតិសំរែប្រារព្ធឡើងជារៀងរាល់ឆ្នាំដើម្បីថ្វាយព្រះពរសិរីសួស្ដីជ័យមង្គលដល់ព្រះរាជាខ្មែរដែលគង់នៅក្រុងអង្គរ។
៤. ស្រង់រាជសព្ទចំនួនបួនពាក្យក្នុងអត្ថបទខាងលើ ៖ " ថ្វាយ ព្រះពរ ព្រះរាជា គង់ " ។


www.elibraryofcambodia.org

វិញ្ញាសាទី
**១០**

# ព្រះពុទ្ធសាសនា



**( បទពាក្យ៧ )**

នៅក្នុងលោកមានច្រើនសាសនា ដែលមានសទ្ធាពន់ប្រមាណ
ល្បីល្បាញរន្ទឺគ្រប់ទីឋាន កម្ពុជាយើងបានប្រកាន់យក។
ព្រះពុទ្ធសាសនាធ្វើជាយាន ទុកធ្វើជាស្ពានជាជម្រក
សិរីសួស្តីនឹងតាមមក ព្រោះយើងបានជ្រកគ្រប់ៗប្រាណ។
ព្រះអង្គទ្រង់ទូន្មានប្រៀនប្រដៅ ដល់អស់កូនចៅសព្វទីឋាន
ជៀសវាងសម្លាប់សត្វឱ្យបាន នោះយើងសុខសាន្តមិនមានកម្ម។
ប្រព្រឹត្តអំពើសុចរិតល្អ តាំងចិត្តស្មោះសរជាប្រចាំ
កុហកបោកប្រាស់កើតក្តីក្តាំ កុំមើលបំណាំចាំថ្ងៃយន្ដា។
កុំសេពគ្រឿងញៀនឬសុរា កុំផក់កញ្ឆានាំវេទនា
កុំកាប់សម្លាប់ប្រមាថគ្នា កុំលេងល្បែងបៀនាតធនធាន។


www.elibraryofcambodia.org

## សិក្សាលើមេរៀនទី ១០

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖

" សាសនា សុចរិត យាន សក្កា វេទនា ប្រមាថ " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ល្បីល្បាញ សុចរិត សុខសាន្ត " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ជម្រក សេព សាង " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " កម្ម សរ " ។

### ខ. សំណួរ

១. តើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាប្រកាន់យកសាសនាអ្វីជាសាសនារបស់រដ្ឋ ?

២. តើសាសនាព្រះពុទ្ធប្រដៅមនុស្សឱ្យធ្វើអ្វីខ្លះនិងមិនឱ្យធ្វើអ្វីខ្លះ ?

៣. ចូរស្រង់ពាក្យចួន ៖

- ក្នុងវគ្គទី១
- ពាក្យចួនឆ្លងវគ្គរវាងវគ្គទី១ និងវគ្គទី២។

៤. ចូរគូសគំនូសតាងពងគ្រីចំណាប់ចួន ៖

- ចំណាប់ចួនក្នុងវគ្គ
- ចំណាប់ចួនឆ្លងវគ្គ។



www.elibraryofcambodia.org

# កំណែវិញ្ញាសាទី ១០

## ក. រៀនពាក្យ

### ១. ពន្យល់ពាក្យ

- សាសនា (សា-សៈ-ន៉ា) (ន.) ៖ ពាក្យបណ្ដាំ ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ។
- សុចរិត (សុ-ចៈ-រិុត) (ន.) ៖ ការប្រព្រឹត្តល្អ មានបីយ៉ាងគឺ ការប្រព្រឹត្តល្អដោយ កាយហៅថាកាយសុចរិត ការប្រព្រឹត្តល្អដោយវាចាហៅថាវចីសុចរិត ការប្រព្រឹត្តល្អដោយចិត្តហៅថាមនោសុចរិត។
- យាន (ន.) ៖ គ្រឿងជិះនាំ គ្រឿងនាំបន្ទុកទៅមក។
- សក្ដា (ស័ក-ក្ដា) (គុ.) ៖ ដែលមានអំណាច ដែលខ្លាំងពូកែ ដែលមានកម្លាំង។
- វេទនា (វេ-ទៈ-នា) (ន.) ៖ ការទទួលអារម្មណ៍ ការរងអារម្មណ៍ ការដឹងអារម្មណ៍ជាសុខឬជាទុក្ខ។
- ប្រមាថ (ប្រ-ម៉ាត) (ន.) ៖ ការបៀតបៀនគេ ការញាំញីគេ ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក ការមើលងាយគេ។

### ២.បដិសព្ទ

- ល្បីល្បាញ ≠ អាប់ឱន
- សុចរិត ≠ ទុច្ចរិត
- សុខសាន្ត ≠ ទុក្ខព្រួយ

៣.ពាក្យសព្ទ

- ជម្រក ទ្រនំ លំនៅ
- សេព បរិភោគ ប្រើប្រាស់ រាប់រក គប់ រក ផឹក ប្រព្រឹត្ត រួមបវេណី ប្រតិបត្តិ រួមរ័ក្ស
- សាង ធ្វើ ស្ថាបនា កសាង សាងសង់។

៤.សទិសសព្ទ

- កម្ម (ន.) ៖ អំពើដែលយើងបានធ្វើ ( ទោះអំពើល្អក្ដី អាក្រក់ក្ដី ហៅថា កម្ម )។
- កាំ (ន.) ៖ អ្វីៗដែលរៀបជាជាន់ ជាថ្នាក់ សម្រាប់ទល់ សម្រាប់រង។ *ឧ.* កាំជណ្ដើរ កាំរទេះ។
- សរ (ន.) ៖ ព្រួញ កាំ កាំធ្នូ កាំស្នា។ *ឧ.* ផ្លែងសរ ត្រូវសរ។
- សរ (កិ.) ៖ រឮកឃើញ នឹកឃើញ ដឹងសាឡើងវិញ។
- ស (ន.) ៖ ព្យញ្ជនៈទី៣០ តាមលំដាប់ព្យញ្ជនៈទាំង៣៣តួ ជាព្យញ្ជនៈទី៥ ក្នុងសេសវគ្គ។
- ស (គុ.) ៖ ដែលមានសម្បុរដូចសំឡីកប្បាស។ *ឧ.* ពណ៌ស។
- ស (កិ.) ៖ ចាក់ចុះព្រាវៗ (ស្មានៗ) ដោយស្មុ។ *ឧ.* សត្រី។
- ស (កិ.) ៖ សម្ដែងអាការៈឱ្យឃើញច្បាស់ បញ្ចេញបែបឱ្យឃើញជាក់។ *ឧ.* ស សេចក្ដី សហេតុ។
- ស (កិ.) ៖ ហែកកេរ្ដិ៍។ *ឧ.* សកេរ្ដិ៍ ឬ សកេរ្ដិ៍សគល់។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាប្រកាន់យកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ។

២. សាសនាព្រះពុទ្ធប្រដៅមនុស្សឱ្យប្រព្រឹត្តអំពើសុចរិតល្អ តាំងចិត្តស្មោះសរជាប្រចាំ។ សាសនាព្រះពុទ្ធប្រដៅមនុស្សមិនឱ្យសម្លាប់ និងប្រមាថជីវិតអ្នកដទៃ សត្វ មិនឱ្យកុហកបោកប្រាស់ មិនឱ្យលួចប្លន់ទ្រព្យរបស់អ្នកដទៃ មិនឱ្យប្រព្រឹត្តខុសក្នុងកាមលើប្ដី ប្រពន្ធអ្នកដទៃ មិនឱ្យសេពគ្រឿងញៀនឬសុរា។

៣. ស្រង់ពាក្យចួនក្នុងវគ្គទី១និងពាក្យចួនឆ្លងវគ្គរវាងវគ្គទី១និងវគ្គទី២ ៖

- ពាក្យចួនក្នុងវគ្គទី ១ ៖

  សាសនា ═ សក្កា

  ប្រមាណា ═ ហាន ═ បាន

- ពាក្យចួនឆ្លងវគ្គទី១និងវគ្គទី២ ៖ យក ═ ជម្រក

៤. គូសគំនូសតាងពងព្រៃចំណាប់ចួនក្នុងវគ្គ និងឆ្លងវគ្គ ៖




www.elibraryofcambodia.org

វិញ្ញាសាទី ១១

# អន្លង់ព្រីង



តំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីង ស្ថិតនៅក្នុងឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត។ តំបន់នេះ បង្កើតឡើងនៅឆ្នាំ ២០០៤ លើផ្ទៃដីជាច្រើនហិចតា ណាតសន្ទឹងល្អល្មើសដោយកន្ទុយភ្នែក ហើយសម្បូរទៅដោយសត្វស្លាបជាច្រើនប្រភេទ ជាពិសេសសត្វក្រៀល។ ក្រៀលជាប្រភេទសត្វជិតផុតពូជទៅហើយនៅលើភពផែនដី។ ដូច្នេះហើយ ទើបនៅខែវិច្ឆិកា ឆ្នាំ២០១០ តំបន់នេះត្រូវបានប្រកាសជាផ្លូវការ ជាតំបន់អភិរក្សសត្វក្រៀល។

នៅរដូវប្រាំង តំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីង គឺជាកន្លែងសំខាន់មួយដែលសត្វក្រៀលឆ្លងកាត់ទៅមកពីប្រទេសវៀតណាម មករកចំណីនៅទីនេះ។ បើតាមការឃ្លាំមើលរបស់អង្គការសង្គ្រោះសត្វស្លាបសហការ


www.elibraryofcambodia.org

ជាមួយមន្ត្រីរដ្ឋបាលព្រៃឈើបានឱ្យដឹងថា សត្វក្រៀលមានការកើនឡើង ប្រជាពលរដ្ឋ និងមន្ត្រីទាំងឡាយសង្ឃឹមថា តំបន់អភិរក្សមួយនេះនឹងទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាសត្វក្រៀលកាន់តែច្រើនឡើង។

## សិក្សាលើវិញ្ញាសាទី ១១

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖ " សន្ទឹង ល្មុលល្មេវ កម្រ ឃ្លាំ អង្គការ សង្គ្រោះ សហការ រដ្ឋបាលព្រៃឈើ អភិរក្ស " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ឡើង សម្បូរ អភិរក្ស " ។

៣.ចូររកវេវចនសព្ទនឹងពាក្យ ៖ " ភ្នែក ផ្ទៃ វិច្ឆិកា " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ពី ថ្ងៃ " ។

### ខ. សំណួរ

១. តើតំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីងស្ថិតនៅឯណា ?

២. តើតំបន់នោះ បង្កើតឡើង និងប្រកាសជាផ្លូវការនៅពេលណា ?

៣.តើនៅរដូវប្រាំងតំបន់អភិរក្សសត្វក្រៀលមានលក្ខណៈដូចម្ដេច ?

៤. តើតំបន់អភិរក្សសត្វក្រៀលផ្ដល់ផលប្រយោជន៍អ្វីខ្លះ ?

## កំណែវិញ្ញាសាទី ១១

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- សន្ទឹង (សន់-ធឹង) (កិ.) ៖ ទាញ លាត លា ត្រដាង ឱ្យត្រង់តឹង។ *ឧ.* សន្ទឹងខ្សែ។


www.elibraryofcambodia.org

- ល្អល្មើវ (គុ.) ៖ ដែលមានលំហទូលាយឥតមានអ្វីទើសទែង។ ឧ. វាលល្អល្មើវ។
- កម្រ (កំ-រ៉) (ន.) ៖ ការក្រ ការលំបាក។ ឧ. កម្រនឹងធ្វើបាន។
- ឃ្លាំ (កិ.) ៖ តយតន់រាំងមើលម្តងៗ។
- អង្គការ (អង់-ការ) (ន.) ៖ ស្ថាប័នដែលបង្កើតឡើងដើម្បីប្រព្រឹត្តទៅកាន់សេចក្តីចម្រើន។
- សង្គ្រោះ (សង់-គ្រោះ) (ន.) ៖ ការទំនុកបម្រុង ការជួយឱ្យបានសុខស្រួល។
- សហការ (សៈ-ហៈ-កា) (កិ.) ៖ រួមគ្នា ធ្វើការជាមួយគ្នា ធ្វើការចូលគ្នា។
- រដ្ឋបាលព្រៃឈើ (រ័ត-ឋៈ-បាល-ព្រៃ-ឈើ) (ន.) ៖ ស្ថាប័នរដ្ឋមួយដែលគេបង្កើតឡើងដើម្បីរក្សា ការពារព្រៃឈើ ឱ្យនៅគង់វង្ស។
- អភិរក្ស (អៈ-ភិ-រៈ) (កិ.) ៖ រក្សាដោយប្រុងប្រយ័ត្ន រក្សាឱ្យនៅគង់វង្ស។

២.បដិសព្ទ

- ឡើង ≠ ចុះ
- សម្បូរ ≠ កម្រ
- អភិរក្ស ≠ បំផ្លិចបំផ្លាញ បដិវត្ត


www.elibraryofcambodia.org

៣.វេវចនសព្ទ

- ភ្នែក ចក្ខុ ព្រះនេត្រ នេត្រា
- ផ្ទៃ ឧទរ ពោះ
- វិច្ឆិកា វិច្ឆកៈ ខ្ទួយ។

៤.សទិសសព្ទ

- ពី (និ.អានិ) ៖ អំពី ខាង ឯ។ ឧ. មកពីណា ? បានមកពីណា ? មកពីផ្ទះ រួចពីដៃ។ល។
- ពីរ (ប.សំ.) ៖ មួយគូបន្ទា តឹមួយនិងមួយ (២) ។
- ផ្ទៃ (ន.) ៖ ពោះ។ ឧ. ពោតចុកផ្ទៃ។
- ផ្ទៃ (ន.) ៖ ផ្ទាំង។ ឧ. ផ្ទៃដី ផ្ទៃសំពត់។
- ផ្ទៃ (ន.) ៖ ផ្ទៃពោះ គភ៌ ទម្ងន់។ ឧ. មានគភ៌ ...

## ខ. ចម្លើយ

១. តំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីង ស្ថិតនៅក្នុងឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត។

២. តំបន់នោះ បង្កើតឡើងនៅឆ្នាំ២០០៤ ហើយត្រូវបានគេប្រកាសជាផ្លូវការជាតំបន់អភិរក្សសត្វក្រៀលនៅខែវិច្ឆិកា ឆ្នាំ២០១០។

៣.នៅរដូវប្រាំង តំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីង គឺជាកន្លែងសំខាន់មួយដែលសត្វក្រៀលឆ្លងកាត់ទៅមក ពីប្រទេសវៀតណាមមករកចំណីនៅទីនេះ។

៤. តំបន់អភិរក្សសត្វក្រៀលផ្ដល់ផលប្រយោជន៍សំខាន់គឺ ទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាសត្វក្រៀល កាន់តែច្រើនឡើង។


www.elibraryofcambodia.org

វិញ្ញាសាទី ១២

# បឹងយក្សឡោម



មានស្តេចយក្សមួយអង្គ មានឫទ្ធិអំណាចខ្លាំងពូកែណាស់។ ទ្រង់មានបុត្រីមួយអង្គនាម សក់ក្រអូប។ ពេលព្រះនាងពេញវ័យ មានមនុស្សម្នាក់ខ្លាំងពូកែបានលបលួចស្នេហាជាមួយព្រះនាង។ ដោយភ័យខ្លាចបិតាដឹង អ្នកទាំងពីរបាននាំគ្នារត់ចូលក្នុងព្រៃមួយ។ ស្តេចយក្សដឹង ក៏ផ្ញើលឆោឡោកេណ្ឌពលយក្សទៅតាមរក។ លុះដល់ព្រៃស្តុកមួយ យក្សសង្ស័យក៏បញ្ជាឱ្យបរិវារល្បាត ហ៊ុមព័ទ្ធព្រៃនោះ។ យក្សខ្លះទៀត ដកព្រៃព្រឹក្សាគរវែងចោល ជីកកកាយរកនាង តែនៅតែរកមិនឃើញ។ អាស្រ័យដោយយក្សកកាយរកនាងសក់ក្រអូប ទើបទីនោះក្លាយជាស្រះមួយនៅក្នុងតំបន់ឡាបានសៀក ស្រុកលំផាត់ ខេត្តរតនគិរី ដែលគេហៅថា " ស្រះយក្ស



www.elibraryofcambodia.org

ឡោម " ។ ស្រះនេះ មានរាងជារង្វង់មូល ជម្រៅ៧០ម៉ែត្រ មានរុក្ខជាតិដុះជុំវិញ។ នៅជុំវិញ មានផ្លូវដ៏វិចិត្រ មានរាជដំណាក់ ភោជនីយដ្ឋាន។ល។ បច្ចុប្បន្ន ទីនេះជារមណីយដ្ឋានដ៏ល្អមួយនៅភូមិភាគឦសាន។

## សិក្សាលើអត្ថបទ ១២

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖ " ឫទ្ធិ គេណ្ឌ បរិវារ ល្បាត ពល ព្រៃស្អុក ហ៊ុមព័ទ្ធ វិចិត្រ រាជដំណាក់ ភោជនីយដ្ឋាន ភូមិភាគ " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ក្រអូប ខ្លាំង ខ្លាច " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " បរិវារ បិតា បុត្រី " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " វ៉ៃ ដុះ " ។

### ខ. សំណួរ

១. តើស្រះយក្សឡោមស្ថិតនៅឯណា ?

២. តើស្រះយក្សឡោមជាស្រះធម្មជាតិ ឬជាស្រះដែលកើតឡើងដូចរឿងរ៉ាវខាងលើ ?

៣. តាមដំណើររឿង តើស្រះនេះកើតឡើងដោយសារអ្វី ?

៤. តើស្រះនេះមានទិដ្ឋភាពដូចម្ដេច ?


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ១២

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ឫទ្ធិ (រឹត) (ន.) ៖ អំណាច សេចក្ដីអស្ចារ្យ សម្បើម សេចក្ដីថ្កើងថ្កា រុងរឿង។
- កេណ្ឌ (កែន) (កិ.) ៖ បង្គាប់ ប្រមូលហៅរកដោយអាជ្ញា។ *ឧ.* កែនពល កែនរទេះ។
- បរិវារ (ប-រិ-វ៉ា)(ន.) ៖ អ្នកចោមរោមកំដរ អ្នកហែហមជាកិត្តិយស អ្នកត្រៀមខ្លួនចាំបម្រើ។
- ល្បាត (កិ.) ៖ ចាំរក្សា ឬក្រវែលឃ្លាំមើលដោយការប្រុងប្រយ័ត្នក្នុងពេលមានកំណត់ ។
- ពល (ពល់) (ន.) ៖ កម្លាំង សេនា កងទ័ព ទាហាន។ *ឧ.* ភ្នំពល លើកពល។
- ព្រៃស្លុក (គុ.) ៖ ព្រៃដែលធំ ហើយក្រាស់។
- ហ៊ុមព័ទ្ធ (ហ៊ុំ-ព័ទ្ធ) (កិ.) ៖ ចោមស្ទាក់ជុំវិញមិនឱ្យមានផ្លូវចេញ។ *ឧ.* ហ៊ុមព័ទ្ធចោរ។
- វិចិត្រ (វិ-ចិត) (គុ.) ៖ ដែលលាយចម្រុះ ឬវិសេចពណ៌ ដែលវិសេចឬឆ្លាស់ក្បាច់រចនា ដែលឆ្លុះឆ្លាស់ ល្អប្លែក។ *ឧ.* របស់វិចិត្រ។
- រាជដំណាក់ (ព្រះ-រាច-ដំ-ណាក់) (ន.) ៖ ទីសម្រាប់ស្នាក់លំនៅក្សត្រ។


www.elibraryofcambodia.org

- ភោជនីយដ្ឋាន (ភោ-ជ:-នី-យ៉ត-ឋាន) (ន.) ៖ កន្លែងសម្រាប់បរិភោគអាហារ។
- ភូមិភាគ (ភូម-ភាក) (ន.) ៖ ប៉ែក ទី តំបន់ ។

## ២.បដិសព្ទ

- ក្រអូប ≠ ស្អុយ
- ខ្លាំង ≠ ខ្សោយ
- ខ្លាច ≠ ហ៊ាន

## ៣.វេវចនសព្ទ

- បរិវារ បរិចារ ពល អង្គរក្ស សេនា អ្នកបម្រើ អ្នកហែហម
- បិតា ឪពុក ឪ ព្រះបិតា ញោមប្រុស
- បុត្រី កូនស្រី រាជបុត្រី កុលធីតា។

## ៤.សទិសសព្ទ

- វ័យ (ន.) ៖ អាយុ កំណត់អាយុ : វ័យក្មេង វ័យកំលោះក្រមុំ វ័យចាស់។
- វៃ (គុ.) ៖ឆាប់ រហ័ស ភ្លាម ឈ្លាស ប៉ិន ដែលឆាប់យល់។
  ឧ. ប្រាជ្ញាវៃ។
- ដុះ (កិ.) ៖ ចាប់កើត កកើត មានពន្លក មានដើមដងដុះ។
  ឧ. ស្រូវដុះ ពោតដុះ។
- ដុស (កិ.) ៖ ខាត់ រំលីង ឮត ជម្រះ។
  ឧ. ដុសក្អែល។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ស្រះយក្សឡោមស្ថិតនៅតំបន់ឡាបានសៀក ស្រុកលំផាត់ ខេត្តរតនគិរី។

២. ស្រះយក្សឡោមជាស្រះធម្មជាតិ មិនមែនកើតឡើងដូចរឿងរ៉ាវខាងលើនោះទេ។ វាកើតឡើងតាមលក្ខណៈធម្មជាតិ ដូចជាបន្ទុះភ្នំភ្លើង ឬជាកត្តាបាតុភូតធម្មជាតិផ្សេងៗទៀត។

៣. តាមដំណើររឿង ស្រះនេះកើតឡើងដោយសារស្ដេចយក្សតាមរកបុត្រី គឺនាងសក់ក្រអូបដែលបានស្រឡាញ់ និងពគ្រាត់គ្នាជាមួយបុរសខ្លាំងពូកែម្នាក់ទៅនៅក្នុងព្រៃមួយ។ ស្ដេចយក្សដឹង កំផ្លើលនោឡោកេឡ្ហាពលយក្សទៅតាមរក។ លុះដល់ព្រៃស្អុកមួយ យក្សសង្ស័យក៏បញ្ជាឱ្យបរិវារល្បាត ហ៊ុមព័ទ្ធព្រៃនោះ។ យក្សខ្លះទៀតដកព្រៃព្រឹក្សាគ្រវែងចោល ជីកកកាយរកនាង តែនៅតែរកមិនឃើញ។ អាស្រ័យដោយយក្សកកាយរកនាងសក់ក្រអូប ទើបទីនោះក្លាយជាស្រះមួយនៅក្នុងតំបន់ឡាបានសៀក ស្រុកលំផាត់ ខេត្តរតនគិរីដែលគេហៅថា " ស្រះយក្សឡោម "។

៤. ស្រះនេះមានរាងជារង្វង់មូលជម្រៅ៧០ម៉ែត្រមានរុក្ខជាតិដុះជុំវិញ។ នៅជុំវិញ មានផ្លូវដ៏វិចិត្រមានរាជដំណាក់ ភោជនីយដ្ឋាន។ល។ បច្ចុប្បន្ន ទីនេះជារមណីយដ្ឋានដ៏ល្អមួយនៅភូមិភាគឦសាន។


www.elibraryofcambodia.org

# បុត្រល្អ



## ( បទពំនោល )

កុមារយើងជាបុត្រល្អ ទឹកចិត្តស្មោះសរ គោរពមាតាបិតា។
លោកបីបមថ្នមរក្សា មើលខុសត្រូវណា ណែនាំពន្យល់អប់រំ។
ទន់ភ្លន់គោរពចាស់ទុំ សុភាពរមទម្យ ប្រកាន់ចរិយាប្រពៃ។
ការងាររមោះមុតរាងវៃ រៀនសូត្រជោគជ័យ មាតាបិតាសប្បាយ។
នឿយហាត់លំបាករសាយ លោកឪពុកម្ដាយ សង្ឃឹមអនាគតកូន។
បុត្រល្អទុកដូចជាក្បូន យិតយោងបងប្អូន ញាតិមិត្តប្រជាមាតុភូមិ។



www.elibraryofcambodia.org

# សិក្សាល្បីវិញ្ញាសាទី ១៣

## ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖

" ស្មោះសរ ចរិយា រមទម្យ អនាគត មាតុភូមិ ប្រជា "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " សុភាព ជោគជ័យ លំបាក "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ញាតិ មាតាបិតា បុត្រ "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ទុំ ចិត្ត ទុក្ខ "។

## ខ. សំណួរ

១. តើកូនល្អមានអាកប្បកិរិយាដូចម្តេចខ្លះ ?

២. តើកូនល្អមានគុណសម្បត្តិដូចម្តេចខ្លះ ?

៣. តើកំណាព្យនេះនិយាយពីអ្វី ?

៤. ចូរស្រង់ពាក្យចួនក្នុងវគ្គទី១ និងពាក្យចួនឆ្លងវគ្គរវាងវគ្គទី១ និងវគ្គទី២។

# អំណែវិញ្ញាសាទី ១៣

## ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ស្មោះសរ (ស្មោះ-សរ) (ន.) ៖ សេចក្តីរីករាយរាក់ទាក់ សេចក្តីរួសរាយ សាទរ ។
- ចរិយា (ច-រិ-យ៉ា) (ន.) ៖ ការប្រព្រឹត្ត សណ្តាប់ ព្រេងព្រេងសំណាង។ *ឧ.* អ្នកហ្នឹងមានចរិយាល្អណាស់។



www.elibraryofcambodia.org

- រមទម្យ (រ៍-ទំ) ៖ ទូន្មានឬបង្វឹកបានបទហើយ ស្រគត់ស្រគំ។
- អនាគត (អៈ-នា-គត់ ) (ន.) ៖ កាលឬសម័យខាងមុខ។ ឧ. ប្រយោជន៍ក្នុងអនាគត។
- មាតុភូមិ (មា-តុ-ភូម) (ន.) ៖ ប្រទេសកំណើត ស្រុកកំណើត។
- ប្រជា (ន.) ៖ ពពួកសត្វ ពពួកជន ។ ប្រជាករ ឬប្រជាជន ជនចំណុះប្រទេស ។

## ២.បដិសព្ទ

- សុភាព ≠ ឆ្មើងកន្ត្រើង
- ជោគជ័យ ≠ បរាជ័យ
- លំបាក ≠ ស្រួល

## ៣.វេវចនសព្ទ

- ញាតិ ញាតិមិត្ត ពូជពង្ស ញាតិផៅ ញាតិសន្តាន ផៅសន្តាន។
- មាតាបិតា ម្ដាយឪពុក ញោមស្រីញោមប្រុស ម៉ែឪ។
- បុត្រ កូន រាជបុត្រ។

## ៤.សមិសសព្ទ

- ទុំ (គុ.) ៖ ទីទៃពីខ្ចី ពីចាស់ គឺដែលដល់កំណត់ជិតជ្រុះពីមែក ពីទង។ ឧ. ស្លឹកឈើទុំ ផ្លែឈើទុំ។
- ទុំ (ប.) ៖ ពាក្យសម្រាប់និយាយផ្សំនឹងពាក្យចាស់។ ឧ. ចាស់ទុំ។
- ទំ (កិ.) ៖ បិតលើទ្រនំ។ ឧ. ក្អែកទំលើមែកអម្ពិល ព្រាបទំរហាំងលើដំបូលសាលា។
- ចិត្ត (ន.) ៖ វិញ្ញាណសម្រាប់គិត។ ឧ. ចិត្តល្អរកម្រកបាន។


www.elibraryofcambodia.org

- ចិត (កិ.) ៖ កាត់ជាចំណិតៗ។ ឧ. ចិតបន្លែ ។
- ចិត (ន.) ៖ ចំនួនលេខស្មើនឹងប្រាំពីរដប់ដង គេនិយាយកាត់។ ឧ. ចិតសិប។
- ទុក្ខ (ន.) ៖ សេចក្តីព្រួយ សេចក្តីលំបាក។ ឧ. កើតទុក្ខ មានទុក្ខ។
- ទុក (កិ.) ៖ ដាក់វត្ថុអ្វីនៅទីណាមួយដើម្បីឱ្យគង់នៅ។ ឧ. ទុកទ្រព្យ។

## ខ. ចម្លើយ

១. កូនល្អត្រូវមានអាកប្បកិរិយាទន់ភ្លន់ មានចិត្តស្មោះសរ គោរពមាតាបិតា ទន់ភ្លន់គោរពចាស់ទុំ សុភាពរមទម្យប្រកាន់ចរិយាប្រពៃ។

២. កូនល្អមានគុណសម្បត្តិដូចជា ការរៀនសូត្រជោគជ័យ ឪពុកម្តាយសង្ឃឹមអនាគតកូន បុត្រល្អទុកដូចជាក្សាន យឹតយោងបងប្អូន ញាតិមិត្តប្រជាមាតុភូមិ។

៣. កំណាព្យនេះនិយាយពីបុត្រល្អចេះគោរពមាតាបិតា ចេះគោរពចាស់ទុំ រៀនសូត្របានជោគជ័យ ជាទីពឹងរបស់ឪពុកម្តាយ និងញាតិមិត្តប្រជាមាតុភូមិ។

៤. ស្រង់ពាក្យចួនក្នុងវគ្គទី១ និងពាក្យចួនឆ្លងវគ្គរវាងវគ្គទី១ និងវគ្គទី២

- ពាក្យចួនក្នុងវគ្គទី១ ៖

  ល្អ ═══ ស្មោះសរ

  បិតា ═══ រក្សា ═══ ណា

- ពាក្យចួនឆ្លងវគ្គទី១ និងវគ្គទី២ ៖

  អប់រំ ═══ ចាស់ទុំ


www.elibraryofcambodia.org

វិញ្ញាសាទី ១៤

# សេចក្ដីថ្លៃថ្នូររបស់មនុស្ស



សេចក្ដីថ្លៃថ្នូរកើតឡើងដោយសារការមានវិជ្ជាសម្បត្តិ មានសីលធម៌ និងមានមនសិការវិជ្ជាជីវៈ។ ចំណេះវិជ្ជាធ្វើឱ្យមនុស្សគ្រប់រូបមានជំនាញវិជ្ជាជីវៈសម្រាប់ចិញ្ចឹមជីវិត។ លើសពីនេះ វិជ្ជាធ្វើឱ្យយើងចេះដឹងខុសត្រូវល្អអាក្រក់ជាដើម។ សីលធម៌ជួយឱ្យមនុស្សមានឥរិយាបថល្អ ចេះគោរពច្បាប់ មិនប្រព្រឹត្តអំពើអាក្រក់ មិនពីសរអើង ស្រឡាញ់សន្តិភាព។ សីលធម៌កើតចេញពីការចេះគោរពប្រតិបត្តិដំបូន្មានល្អៗ ទំនៀមទម្លាប់ ប្រពៃណី និងច្បាប់សង្គម។ ការមានមនសិការវិជ្ជាជីវៈ កើតចេញពីទឹកចិត្តស្រឡាញ់ការងារ យកចិត្តទុកដាក់នឹងការងារ និងមានស្មារតីទទួលខុសត្រូវក្នុងការងាររបស់ខ្លួន។ សេចក្ដីថ្លៃថ្នូរធ្វើឱ្យមនុស្សមានកេរ្តិ៍ឈ្មោះក្រអូប និងមានកិត្តិយស។


www.elibraryofcambodia.org

ដូច្នេះ មនុស្សគ្រប់រូបត្រូវប្រកាន់យកសេចក្ដីថ្លៃថ្នូរ ព្រោះវាជាគ្រឿងធ្វើឱ្យការរស់នៅប្រកបដោយសុភមង្គល។

## សិក្សាល្បើវិញ្ញាទី ១៤

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះ ៖ " វិជ្ជាសម្បត្តិ សីលធម៌ មនសិការ វិជ្ជាជីវៈ ស្មារតី ឥរិយាបថ កិត្តិយស " ។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " ថ្លៃថ្នូរ វិជ្ជា សីលធម៌ " ។
៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " វិជ្ជាជីវៈ ប្រតិបត្តិ ជំហ្វូន " ។
៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " សុខ កេរ្តិ៍ " ។

### ខ. សំណួរ

១. តើសេចក្ដីថ្លៃថ្នូរកើតឡើងដោយសារកត្តាអ្វីខ្លះ ?
២. តើចំណេះវិជ្ជាផ្ដល់សារៈសំខាន់ដូចម្ដេចខ្លះ ?
៣. តើសីលធម៌ផ្ដល់សារៈសំខាន់ដូចម្ដេចខ្លះ ?
៤. តើការមានមនសិការវិជ្ជាជីវៈផ្ដល់សារៈសំខាន់ដូចម្ដេចខ្លះ ?
៥. ហេតុអ្វីបានជាមនុស្សត្រូវការសេចក្ដីថ្លៃថ្នូរ ?


www.elibraryofcambodia.org

## អំណានទិញ្ញាសាទី ១៤

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- វិជ្ជាសម្បត្តិ (វិច-ជា-សំ-ប័ត) (ន.) ៖ ការបរិបូណ៌ដោយចំណេះដឹង។
- សីលធម៌ (សិល-ធ័រ) (ន.) ៖ សីលដែលជាធម៌ ឬសីលនិងធម៌ កិរិយាមារយាទ សណ្ដាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យជៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ។
- មនសិការ (ម:-ន:-សិ-កា-រ: ឬ ម:-ន:-សិ-កា) (ន.) ៖ ការធ្វើទុកក្នុងចិត្ត ការកំណត់ទុកក្នុងចិត្ត ដំណើរយកចិត្តទុកដាក់។
- វិជ្ជាជីវ: (វិច-ជា-ជី-វ:) (ន.) ៖ មុខតំណែង មុខការ របរសម្រាប់ចិញ្ចឹមជីវិត។ *ឧ.* វិជ្ជាជីវ:របស់អ្នករាជការ ប្រកបវិជ្ជាជីវ:ខាងកសិកម្ម។
- ស្មារតី (ស្មា-រ-ដី) (ន.) ៖ សេចក្ដីនឹកឃើញ ការរឭកបាន ការរឭកឃើញមិនភ្លេច ការចាំបាន ការប្រុងប្រយ័ត្នមិនឱ្យភ្លេច។ *ឧ.* មានស្មារតី។
- ឥរិយាបថ (អិ-រិ-យ៉ា-បត់) (ន.) ៖ ផ្លូវឬគន្លងនៃឥរិយា គឺការដើរ ដេក ឈរ អង្គុយ។
- កិត្តិយស (កិត-តិ-យស់) (ន.) ៖ យសសក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង។


www.elibraryofcambodia.org

២.បដិសព្ទ

- ថ្លៃថ្នូរ ≠ ថោកទាប
- វិជ្ជា ≠ អវិជ្ជា
- សីលធម៌ ≠ អសីលធម៌

៣.វេវចនសព្ទ

- វិជ្ជាជីវៈ អាជីព មុខរបរ
- ប្រតិបត្តិ ធ្វើ អនុវត្ត ប្រព្រឹត្ត
- ដំបូន្មាន ការទូន្មាន ការអប់រំ ការណែនាំ ការប្រៀនប្រដៅ ការដាស់តឿន ការក្រើនរំឭក ឱវាទ អនុសាសន៍។

៤.សទិសសព្ទ

- សុខ (គុ.) ៖ ដែលសប្បាយ ងាយ ស្រួល ស្រណុក សម្រាន្ត។
- សុខ (ន.) ៖ សេចក្ដីសប្បាយ ដំណើរងាយ ដំណើរស្រួល ដំណើរស្រណុក សេចក្ដីសម្រាន្ត។ ឧ. មានសុខ បានសុខ។
- សុក (ន.) ៖ អាការមួយប្រភេទ ជាស្រោមស្រោបកូនដែលនៅក្នុងផ្ទៃម្ដាយ។
- កេរ (ន.) ៖ ដំណែល ជាសម្បត់របស់ជូនតា ឬមាតាបិតាជាដើម។
- កេរ្តិ៍ (ន.) ៖ សេចក្ដីសរសើរ ការល្បី ខ្ទរខ្ទារ កេរ្តិ៍ឈ្មោះ។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. សេចក្ដីថ្លៃថ្នូរកើតមានដោយសារវិជ្ជាសម្បត្តិ សីលធម៌ និងមនសិការវិជ្ជាជីវៈ។

២. ចំណេះវិជ្ជា ធ្វើឱ្យមនុស្សគ្រប់រូបមានជំនាញវិជ្ជាជីវៈសម្រាប់ចិញ្ចឹមជីវិត។ លើសពីនេះ វិជ្ជាធ្វើឱ្យយើងយល់ដឹងខុសត្រូវ ល្អ អាក្រក់ជាដើម។

៣. សីលធម៌ជួយឱ្យមនុស្សមានឥរិយាបថល្អ ចេះគោរពច្បាប់ មិនប្រព្រឹត្តអំពើអាក្រក់ មិនរើសអើង ស្រឡាញ់សន្តិភាព។ សីលធម៌កើតចេញពីការចេះគោរពប្រតិបត្តិជំនឿល្អៗ ទំនៀមទម្លាប់ប្រពៃណី និងច្បាប់សង្គម។

៤. ការមានមនសិការវិជ្ជាជីវៈផ្ដល់សារៈសំខាន់គឺ ទឹកចិត្តស្រឡាញ់ការយកចិត្តទុកដាក់នឹងការងារ និងមានស្មារតីទទួលខុសត្រូវក្នុងការងាររបស់ខ្លួន។

៥. បានជាមនុស្សត្រូវមានសេចក្ដីថ្លៃថ្នូរ ព្រោះភាពថ្លៃថ្នូរធ្វើឱ្យមនុស្សមានកេរ្តិ៍ឈ្មោះក្រអូប និងមានកិត្តិយស។ ភាពថ្លៃថ្នូរញ៉ាំងឱ្យការរស់នៅប្រកបដោយភាពសមរម្យ និងមានសុភមង្គល។


www.elibraryofcambodia.org

# ទឹកចិត្តមេមាន់



កសិករម្នាក់បានចិញ្ចឹមមេមាន់មួយ និងមេទាមួយ។ ក្រោយមក មេមាន់កើតបានកូនបួន ចំណែកមេទាកើតបានកូនមួយក៏ចាកចោលទុកកូនឱ្យនៅឯកោ។ មេមាន់ឃើញកូនទាកំព្រាយកមកចិញ្ចឹមបីបាច់ដូចកូនបង្កើតដែរ។ រាល់ថ្ងៃមេមាន់បណ្តើរកូនទាំងអស់រកចំណីគ្រប់ទីកន្លែង។

ថ្ងៃមួយ កូនមាន់តូចជាងគេឆ្ងល់នឹងទង្វើរបស់ម្ដាយក៏សួរ ៖ " ម៉ែ ! ហេតុអ្វីបានជាម៉ែមើលថែកូនទា ? "។ មេមាន់ឆ្លើយ ៖ " កូនទាកំព្រាអត់មេ ហើយវានៅតូចណាស់។ វាត្រូវការការថែទាំដូចកូនដែរ។ ម៉ែចិញ្ចឹមវា ព្រោះវាក៏មានសិទ្ធិរស់រានមានជីវិត ដូចក្មេងទូទៅដែរ។ បើម៉ែមិនយកវាមកចិញ្ចឹម តើវារស់ដូចម្ដេច ? "។ កូនមាន់សួរមេវាទៀត ៖ " ម៉ែគិតចិញ្ចឹមកូនទារហូតឬ ? "។ មេមាន់ឆ្លើយ ៖ " ទេ ! ដល់វាគ្រប់អាយុ ម៉ែឱ្យវាទៅរៀនជាមួយកូន ហើយដល់ពេលវាអាចចិញ្ចឹមខ្លួនបាន ម៉ែឈប់ជួយវាហើយ "។ " យី ! ម៉ែខ្ញុំចិត្តល្អណាស់ " កូនៗលាន់មាត់។


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ១៥

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យទាំងនេះឱ្យបានត្រឹមត្រូវ ៖
" កសិករ ឯកោ លាន់មាត់ ទឹកចិត្ត ទង្វើ " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ស្ងួរ ចិត្តល្អ មេ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ទឹក អាយុ កើត " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ទុក " ។

### ខ. សំណួរ

១. តើកសិករចិញ្ចឹមសត្វអ្វីខ្លះ ?

២. ហេតុអ្វីបានជាមេមាន់ចិញ្ចឹមកូនទា ?

៣. តើមេទាមានទឹកចិត្តដូចម្ដេច ?

៤. តើមេមាន់មានទឹកចិត្តដូចម្ដេច ?

## កំណែវិញ្ញាសាទី ១៥

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កសិករ (កៈ សិ-ករ) (ន.) ៖ អ្នកធ្វើកសិកម្ម។
- ឯកោ (អែក-កោ) (គុ.) ៖ អ្នកដែលនៅតែមួយ ឬតែម្នាក់ ឥតមានពីរ។
- លាន់មាត់ (ន.) ៖ ការនិយាយស្ដី។
- ទឹកចិត្ត (ទឹក-ចិត) (ន.) ៖ ទឹករក្សាចិត្ត គឺទឹកដែលមាននៅក្នុងបេះដូង។
- ទង្វើ (ទង់-វើ) (ន.) ៖ ការធ្វើ។


www.elibraryofcambodia.org

២.បដិសព្ទ

- សួរ ≠ ឆ្លើយ
- ចិត្តល្អ ≠ ចិត្តអាក្រក់
- មេ ≠ ឈ្មោល

៣.វេវចនសព្ទ

- ទឹក គង្គា ភរិ
- អាយុ ជន្ម ព្រះជន្ម ជន្មាយុ
- កើត សម្រាល ឆ្លងទន្លេ ប្រសូត។

៤.សទិសសព្ទ

- ទុក (កិ.) ៖ ដាក់វត្ថុអ្វីនៅទីណាមួយដើម្បីឱ្យគង់នៅ។
  ឧ. ទុកទ្រព្យ។
- ទុក្ខ (ន.) ៖ សេចក្ដីព្រួយ សេចក្ដីលំបាក។
  ឧ. កើតទុក្ខ មានទុក្ខ។

## ខ. ចម្លើយ

១. កសិករចិញ្ចឹមមេមាន់មួយ និងមេទាមួយ។
២. បានជាមេមាន់ចិញ្ចឹមកូនទា ព្រោះមេមាន់យល់ឃើញថា កូនទាក៏មានសិទ្ធិរស់រានមានជីវិតដូចក្មេងទូទៅដែរ។
៣.មេទាមិនមានទឹកចិត្តអាណិតអាសូរ ស្រឡាញ់ គ្មានការយកចិត្តទុកដាក់ចំពោះកូន និងមិនមានការទទួលខុសត្រូវក្នុងការចិញ្ចឹមកូន។
៤. មេមាន់មានទឹកចិត្តល្អ ចិត្តទូលាយ មានចិត្តមេត្តា សប្បុរសធម៌ មានទឹកចិត្តអាណិតអាសូរ ស្រឡាញ់កូនទា សុខចិត្តចិញ្ចឹមដោយចាត់ទុកកូនទាដូចជាកូនបង្កើតដែរ។


www.elibraryofcambodia.org

# តែងសេចក្ដី

## លំនាំបង្រៀនតែងសេចក្ដី

### ក.ការបង្ហាញ

១. រំឭកមេរៀន សួរសំណួរទាក់ទងនឹងតែងសេចក្ដីបែបពណ៌នា។

២. អានអត្ថបទតែងសេចក្ដីគំរូ ដោយសង្កេតមើលចំណុចសំខាន់នៃតែងសេចក្ដីបែបពណ៌នា។

៣. សួរសំណួរទាក់ទងខ្លឹមសារលម្អិតនៃអត្ថបទតែងសេចក្ដីគំរូ។

៤. សួរសំណួរបំផុសរកឱ្យឃើញទម្រង់ និងគម្រោងរបស់តែងសេចក្ដីបែបពណ៌នា។

៥. អានគម្រោងតែងសេចក្ដីបែបពណ៌នាគំរូ។

៦. សួរសំណួរទាក់ទងនឹងខ្លឹមសារ គម្រោងតែងសេចក្ដីបែបពណ៌នាគំរូ។

### ខ.ការអនុវត្ត

១. បំផុសសំណួរ ៖ រកឱ្យឃើញគម្រោងតែងសេចក្ដីលម្អិតទាក់ទងនឹងប្រធានតែងសេចក្ដី។

២. ការប្រមូលគំនិត ៖ ប្រមូលគំនិតលម្អិតទាក់ទងនឹងគម្រោងតែងសេចក្ដី។



www.elibraryofcambodia.org

៣.ការសរសេរព្រាង ៖ យកគំនិតដែលប្រមូលបានមកសរសេរព្រាងជាល្បះពេញលេញ ឱ្យបានត្រឹមត្រូវតាមគម្រោងតែងសេចក្ដី។
៤. ការកែលម្អ ៖ គ្រូឱ្យសិស្សប្ដូរកិច្ចការគ្នាកែ ក្នុងការកែមិនត្រូវឱ្យសិស្សគូសវាស ឬសរសេរលើកិច្ចការគេទេ បើពិនិត្យឃើញមានកំហុសត្រូវមកពិភាក្សាកែលម្អជាមួយម្ចាស់ដើមវិញ ពេលកែរួចត្រូវប្រគល់កិច្ចការឱ្យម្ចាស់ដើមវិញ។
៥. ការសរសេរសម្រេច ៖ ឱ្យសិស្សយកកិច្ចការរបស់ខ្លួនមកសរសេរសម្រេចឱ្យបានស្អាតត្រឹមត្រូវ។

## ង.ការវាយតម្លៃ

១. សួរសំណួរទាក់ទងនឹងបញ្ញត្តិតែងសេចក្ដីបែបពណ៌នា។
២. សួរសំណួរពង្រឹងចំណេះដឹងអំពីគម្រោងតែងសេចក្ដីខាងលើ។
៣. ដាក់ប្រធានតែងសេចក្ដីថ្មីឱ្យសិស្សធ្វើនៅផ្ទះដោយផ្អែកលើគម្រោងខាងលើ។


www.elibraryofcambodia.org

វិញ្ញាសាទី ១

# តែងសេចក្ដី
# បែបពិពណ៌នាអំពីមនុស្ស

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

*ប្រធាន ៖* ចូរអ្នកពណ៌នាអំពីមិត្តភក្តិណាម្នាក់ដែលអ្នកពេញចិត្តជាងគេ ឱ្យបានក្បោះក្បាយ។

### សេចក្ដីអធិប្បាយ

ខ្ញុំមានមិត្តម្នាក់ឈ្មោះ សន្តិការិកា ភេទស្រី អាយុ១១ឆ្នាំ។ នាងមានទីលំនៅក្នុងភូមិមួយជិតភូមិរបស់ខ្ញុំ។ សព្វថ្ងៃ នាងរៀននៅថ្នាក់ទី៦ “ ក ” ជាមួយខ្ញុំដែរ ហើយជាមិត្តដ៏ល្អរបស់ខ្ញុំ។



សន្តិការិកា មានរាងស្ដើងខ្ពស់ស្រឡះ សម្បុរសល្អែកបាយ ដៃជើងស្រឡូន សក់ស្លូត វែងប៉ប្រះស្មា ភ្នែកខ្មៅថ្លាយង់ ច្រមុះកោងស្រួច បបូរមាត់ក្រហមស្ដើង ទឹកមុខស្រស់ស្រាយ គួរជាទីរាប់អានពីមិត្តភក្តិ និងមនុស្សទូទៅ។

សន្តិការិកា មានសម្ដីទន់ភ្លន់ សុភាពរាបសាជាមួយមិត្តភក្តិ លោកគ្រូអ្នកគ្រូ និងចាស់ព្រឹទ្ធាចារ្យ។ នាងជាក្មេងឧស្សាហ៍ព្យាយាមក្នុងការសិក្សារៀនសូត្រណាស់។ នៅពេលចេញលេង ឬម៉ោងទំនេរ នាងតែងចូលបណ្ណាល័យអានសៀវភៅ ឬធ្វើលំហាត់ផ្សេងៗ។ ក្នុងការសិក្សា នាងតែងទទួលបានចំណាត់ថ្នាក់ល្អ ជារៀងរាល់ខែ។ លោកគ្រូ


www.elibraryofcambodia.org

អ្នកគ្រូ តែងសរសើរនាងគ្រប់ៗគ្នា។ នាងចូលចិត្តលេងល្បែងណាដែលមានសុវត្ថិភាព។

ចំណែកឯការងារវិញក៏នាងយកចិត្តទុកដាក់ធ្វើដែរ។ មិនថាតែពលកម្មនៅសាលារៀនប៉ុណ្ណោះទេ ការងារផ្ទះក៏នាងឧស្សាហ៍ព្យាយាមដែរ។ ឪពុកម្ដាយ និងអ្នកភូមិតែងសរសើរនាងគ្រប់ៗគ្នា។ សន្តិការិកាជាក្មេងឆ្លាត។ នេះជាសម្ដីលោកគ្រូ អ្នកគ្រូអូតសរសើរនាង ព្រោះនាងឆាប់យល់កិច្ចការទាំងឡាយក្នុងការសិក្សា។ នាងមិនប្រកាន់រើសអើងចំពោះមិត្តណាម្នាក់ឡើយ ហើយតែងជួយពន្យល់កិច្ចការផ្សេងៗ ឬលំហាត់ដែលខ្ញុំ ឬមិត្តភក្តិដទៃទៀតមិនយល់។ សន្តិការិកាតែងជួយដាស់តឿនណែនាំខ្ញុំ នៅពេលខ្ញុំភ្លេចខ្លួនប្រព្រឹត្តអំពើមិនគប្បីណាមួយ។

សន្តិការិកាជាមិត្តដ៏ល្អរបស់ខ្ញុំ និងមិត្តភក្តិដទៃទៀត។ ខ្ញុំគោរពស្រឡាញ់នាងណាស់ ព្រោះគេជាមិត្តដ៏ល្អ ដែលយើងទាំងអស់គ្នាគួរយកគម្រាប់តាម។

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

១.សេចក្ដីផ្ដើម

បង្ហាញពីមនុស្សនោះដោយប្រាប់ ៖

- ឈ្មោះ ...
- ភេទ ...
- អាយុ ...
- ទីលំនៅ ...
- មុខរបរ ...។

២.តួសេចក្ដី

- រូបសម្បត្តិ


www.elibraryofcambodia.org

រូបរាង ៖

- មាឌ (តូច ធំ ស្គម ធាត់ ...)
- កម្ពស់ (ទាប ខ្ពស់ ...)
- សម្បុរ (ស ខ្មៅ ស្រអែម ... )
- មុខមាត់ (ភ្នែក ច្រមុះ មាត់ ត្រចៀក សក់ ទឹកមុខ ...)
- ជើង ដៃ (មាំមួន សមនឹងដងខ្លួន វែងខ្លី ...)
- អាកប្បកិរិយា ៖ សកម្មភាពផ្សេងៗ ការស្លៀកពាក់ ការនិយាយស្ដី ការធ្វើការងារ។ល។

• ចរិយាសម្បត្តិ

គុណសម្បត្តិ ៖

-ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់លើការសិក្សា ឬធ្វើការងារ មានសណ្ដាប់ធ្នាប់ គោរពវិន័យ គោរពច្បាប់ ថ្លិតថ្លង់ ...
- ឆ្លាតវាងវៃ ឆាប់យល់ ចេះចាំ ...
- ក្លាហាន ហ៊ានទទួលខុសត្រូវ ...
- ចិត្តទូលាយ ជួយទុក្ខធុរៈអ្នកដទៃ មិត្តភក្តិ ...
- ស្លូតត្រង់ ស្រឡាញ់យុត្តិធម៌ សុចរិត ...។

គុណវិបត្តិ ៖

- តើមានចំណុចអសកម្មត្រង់ណាខ្លះ ? ឧ. លេងសើចច្រើន មករៀនយឺត ...។

## ៣.សេចក្ដីបញ្ចប់

• វាយតម្លៃ ៖ គេជាមនុស្សល្អ ចេះជួយគ្នាក្នុងគ្រាក្រ ... ។
• ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះមិត្ត គួរគោរព និងយកតម្រាប់តាម ...។


www.elibraryofcambodia.org

## គ.ការអនុវត្ត

*ប្រធាន* ៖ ចូរអ្នកពណ៌នាអំពីមនុស្សល្អណាម្នាក់ ដែលរស់នៅក្នុងសហគមន៍អ្នក តាមគម្រោងខាងលើ ឱ្យបានក្បោះក្បាយ។

### សេចក្តីអធិប្បាយ




លោកអ៊ំ ហ៊ឹម ថន មានអាយុ៦៣ឆ្នាំ។ គាត់រស់នៅក្នុងភូមិជាមួយខ្ញុំដែរ។ សព្វថ្ងៃ គាត់ជាសមាជិកក្រុមប្រឹក្សាឃុំ។ គាត់ជាមនុស្សដែល


www.elibraryofcambodia.org

ប្រជាជនគ្រប់រូបគោរពស្រឡាញ់រាប់អាន។ លោកអ៊ំ ហ៊ឹម ផន មានសុខភាពមាំមួនណាស់។ គាត់មានរាងទាបក្រអាញ សម្បុរខ្មៅស្រអែម ជើងដៃមាំមួន សក់រួញអង្កាដីភ្នែកធំៗ ចិញ្ចើមក្រាស់ បបូរមាត់ក្រាស់ ច្រមុះធំ ប្រកបទៅដោយទឹកមុខស្រស់ស្រាយ គួរជាទីចូលចិត្តរាប់អានពីមនុស្សទូទៅ។

លោកអ៊ំ ហ៊ឹម ផន មានសម្តីទន់ភ្លន់ សុភាពរាបសា ទាំងជាមួយក្មេងៗ ក៏ដូចជាមួយចាស់ទុំដែរ។ គាត់ជាមនុស្សនស្សាហ៍ព្យាយាមណាស់ មិនថាការងាររាជការ ឬការងារផ្ទាល់ខ្លួននោះទេ។ គាត់តែងចុះធ្វើការតាមភូមិដើម្បីប្រជុំផ្សព្វផ្សាយដល់ប្រជាជនអំពីការអប់រំសុខភាព ដូចជាណែនាំស្ត្រីមានផ្ទៃពោះ ឱ្យទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពទៀងទាត់រៀងរាល់ខែ និងយកកុមារទៅចាក់ថ្នាំបង្ការជាដើម។ លើសពីនេះ គាត់បានណែនាំ ប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យគោរពច្បាប់ចរាចរណ៍ ពាក់មួកសុវត្ថិភាពពេលបើកបរម៉ូតូ និងត្រូវមានការយោគយល់អធ្យាស្រ័យគ្នាក្នុងពេលបើកបរ។ ពេលមានផ្លូវថ្នល់ខូចខាត គាត់បានដឹកនាំប្រជាជនជួសជុលចាក់បំពេញជានិច្ច។ យូរៗម្តង គាត់បានអញ្ជើញអ្នកជំនាញឯកទេសឱ្យមកផ្សព្វផ្សាយអំពីបច្ចេកទេសដាំដំណាំ ការធ្វើស្រែចម្ការ ការចិញ្ចឹមសត្វ ជាលក្ខណៈគ្រួសារដល់ប្រជាជននៅតាមភូមិ។ អ៊ំប្រុស យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការងារអប់រំ។ គាត់តែងណែនាំប្រជាជន ឱ្យនាំកូនមានអាយុ៦ឆ្នាំទៅចុះឈ្មោះចូលរៀន។ គាត់ដឹកនាំប្រជាជនឱ្យចូលរួមក្នុងការងារភូមិឃុំមានសុវត្ថិភាព។ លោកអ៊ំ ហ៊ឹម ផន ជាមនុស្សឆ្នើម ដែលប្រជាជននៅក្នុងឃុំគោរព និងកោតសរសើរគ្រប់ៗគ្នា។


www.elibraryofcambodia.org

នៅក្នុងភូមិលោកអ៊ឹ ហ៊ឹម ថន មានទំនាក់ទំនងល្អជាមួយអ្នកជិតខាងជានិច្ច។ គាត់ជាមនុស្សសុភាពទន់ភ្លន់ស្លូតត្រង់ សុចរិតស្រឡាញ់យុត្តិធម៌ មិនរើសអើងជាតិសាសន៍ ឬសាសនាឡើយ។ គាត់តែងជួយទុក្ខធុរៈ យកអាសាអ្នកជិតខាង។ អ្នករស់នៅជិតខាង ស្រឡាញ់រាប់អានគាត់ណាស់។

នៅផ្ទះ គាត់ជាមនុស្សឧស្សាហ៍ណាស់។ គាត់ដាំដំណាំ ចិញ្ចឹមសត្វសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ហេតុនេះហើយទើបគ្រួសារគាត់មិនចំណាយថវិកាច្រើន សម្រាប់ទិញបន្លែ និងម្ហូបអាហារទេ។ នៅក្នុងផ្ទះគាត់រៀបចំទុកដាក់វត្ថុប្រើប្រាស់យ៉ាងមានសណ្ដាប់ធ្នាប់។ រៀងរាល់ថ្ងៃគាត់យកចិត្តទុកដាក់អប់រំទូន្មានកូនចៅ ឱ្យខិតខំរៀនសូត្រ ថែរក្សាសុខភាព និងគោរពច្បាប់ជាដើម។ ទោះជាយ៉ាងណា គាត់ក៏នៅតែមានកំហុសឆ្គងខ្លះៗដែរ។ ពេលខឹងគាត់ពោលពាក្យតំរោះតំរើយដាក់កូនចៅម្ដងម្កាលដែរ។ ទោះជាយ៉ាងនេះក៏ដោយ គាត់ជាមនុស្សមានគុណសម្បត្តិល្អច្រើន សមាជិកគ្រួសារគាត់ គោរព ស្រឡាញ់គាត់ណាស់។ កូនចៅទាំងអស់ស្ដាប់តាមដំបូន្មានគាត់ជានិច្ច។

លោកអ៊ឹ ហ៊ឹម ថន ជាមនុស្សល្អគួរឱ្យចូលចិត្តគោរព ស្រឡាញ់រាប់អាន។ គាត់ជាមនុស្សគំរូនៅក្នុងសហគមន៍ដែលខ្ញុំរស់នៅ។ រូបខ្ញុំផ្ទាល់ក៏ដូចជាប្រជាជនទាំងអស់ដែរ គោរពស្រឡាញ់គាត់ណាស់។



www.elibraryofcambodia.org

វិញ្ញាសាទី ២

# តែងសេចក្តី
# បែបពិពណ៌នាអំពីសត្វ

## ក.ការសិក្សាអត្ថបទតែងសេចក្តីគំរូ

| | |
|---|---|
| *ប្រធាន* ៖ | គ្រួសារអ្នកចិញ្ចឹមសត្វជាច្រើន។ ចូរអ្នកពណ៌នាអំពីសត្វអ្វីមួយ ដែលអ្នកពេញចិត្តជាងគេឱ្យបានក្បោះក្បាយ។ |

### សេចក្តីអធិប្បាយ

គ្រួសារខ្ញុំជាកសិករប្រកបរបរធ្វើស្រែចម្ការ ដាំដំណាំ និងចិញ្ចឹមសត្វ។ ក្នុងចំណោមសត្វទាំងអស់ ខ្ញុំពេញចិត្តគោឈ្មោលមួយនឹមជាងគេ។

គោមួយនឹមនេះ មួយឈ្មោះអាឡោត និងមួយទៀតឈ្មោះអាចម្យ៉ា។



វាទាំងពីរនេះ មានមាឌធំស្រឡះ និងមានរូបរាងស្រដៀងនឹងគោឧសភរាជដែលគេទឹមក្នុងពិធីច្រត់ព្រះនង្គ័លដែរ។ គោនេះ មានរោមក្រាស់ទន់រលោង។ វាមានក្បាលត្រមែង ស្នែងប្រក់នាគមានចុងស្រួចកធំក្រាស់ ត្រចៀកធំស្រួច។ ដងខ្លួនធាត់ម្ញូល ខ្នងរាបដូចក្តារ ជើងមាំៗកន្ទុយវែងធ្លាក់ផុតកំភួនជើង។


www.elibraryofcambodia.org

អាត្នោត និងអាចម្ប៉ាស្លូតណាស់។ វាពុំដែលដេញជល់ ឬបុះអ្នកណាឡើយ។ គោខ្ញុំស្គាល់ម្ចាស់ណាស់ ពេលឃើញម្ចាស់ វាតាមមើលហាក់ចង់សួរនាំពីរឿងអ្វីមួយ។ ពេលខ្លះ វាសម្លឹងមុខខ្ញុំ ស្រែកម៉ូៗផង គ្រវីក្បាលដាក់ខ្ញុំផង។ ជួនកាលវាជញ្ជ្រំជើងទំនងដូចជាចង់ឱ្យខ្ញុំនាំវា ទៅស៊ីស្មៅអីចឹង។

សព្វថ្ងៃ គ្រួសារខ្ញុំធ្វើស្រែចម្ការពឹងពាក់ទាំងស្រុងលើកម្លាំងអាត្នោត និងអាចម្ប៉ា។ វាមានកម្លាំងខ្លាំងដូចដំរី។ នៅរដូវវស្សា ឪពុកខ្ញុំឱ្យវាអូសនង្គ័ល រនាស់ដើម្បីធ្វើស្រែ។ ក្រៅពីនេះ វាអូសរទេះដឹកកណ្តាប់កាត់ទឹកកាត់ភក់ ហាក់គ្មាននឿយហត់បន្តិចឡើយ។ នៅរដូវប្រាំង ឪពុកខ្ញុំទឹមវាដើម្បីភ្ជួររាស់ដីចម្ការដាំដំណាំ។ លើសពីនេះ គ្រួសារខ្ញុំទឹមវាដឹកអុស ដឹកដី ដឹកស្រូវអង្ករ និងគ្រឿងប្រើប្រាស់ផ្សេងៗទៀត។

គោខ្ញុំដេកក្នុងក្រោល រាល់ព្រឹកខ្ញុំក្រោកពីព្រលឹមបញ្ចេញវាពីក្រោលយកទៅចងក្រោមដើមឈើ។ មុនពេលទៅសាលារៀន ខ្ញុំយកវាទៅចងនៅឯវាលឱ្យស៊ីស្មៅ។ ខ្ញុំពុំដែលលែងគោចោលទេ ព្រោះខ្លាចបាត់ ឬទៅស៊ីដំណាំគេ។ ជាពិសេស ម៉ាក់ខ្ញុំបារម្ភខ្លាចវាដើរ ឆ្លងផ្លូវដែលបង្កគ្រោះថ្នាក់ចរាចរណ៍ដល់អ្នកដទៃ។ ពេលទំនេរពីការងារ ខ្ញុំជិះលើខ្នងនាំវាទៅស៊ីស្មៅនៅឯវាល។ ខ្ញុំមិនធុញទ្រាន់នឹងការមើលថែវាទេ ព្រោះខ្ញុំបានជិះលើខ្នងវា អានសៀវភៅ និងច្រៀងលេងយ៉ាងសប្បាយ។ អាត្នោត និងអាចម្ប៉ាស៊ីស្មៅក៏ច្រើន ផឹកទឹកក៏ច្រើន។ ពេលល្ងាច ខ្ញុំយកវាទៅលាងទឹកសម្អាតខ្លួនប្រាណវាយ៉ាងស្អាត។ ពេលព្រលប់ ខ្ញុំបញ្ចូលវាក្នុងក្រោល និងបំពក់ភ្លើងដើម្បីកុំឱ្យមូសខាំ។ រៀងរាល់ឆ្នាំ ឪពុកខ្ញុំតែងយកវាទៅចាក់ថ្នាំបង្ការជំងឺឆ្លងគ្រប់ប្រភេទ។ ដូច្នេះវាមិនងាយឈឺឡើយ។


www.elibraryofcambodia.org

ការចិញ្ចឹមគោ ផ្ដល់ប្រយោជន៍ច្រើនណាស់។ ក្រៅពីប្រើប្រាស់កម្លាំងសម្រាប់អូសទាញ វាផ្ដល់នូវលាមកយ៉ាងច្រើនទៀតផងជារៀងរាល់ថ្ងៃ។ រៀងរាល់ព្រឹក ខ្ញុំតែងក្រោកពីព្រលឹមកើបអាចម៍វាយកទៅដាក់ក្នុងរណ្ដៅធ្វើជាជី ព្រោះជីលាមកគោ ជាប្រភេទជីធម្មជាតិដ៏ល្អប្រសើរសម្រាប់ដាំដំណាំ។ ដំណាំដែលប្រើប្រាស់ជីធម្មជាតិ មិនធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ឡើយ។

អាត្នោត និងអាចម៉្យាបង្កការលំបាកដល់ខ្ញុំខ្លះៗដែរ។ ពេលឃ្លានខ្លាំង វាស្រែកខ្លាំងៗ ហើយទាញខ្សែស្ទើរដាច់កន្លះ។ ពេលខ្លះទៀត វាបុះដីម្នាក់ឯង ធ្វើឱ្យប្រឡាក់ពេញក្បាល។

ខ្ញុំពេញចិត្តនឹងគោទាំងពីរក្បាលនេះណាស់ ហើយចាត់ទុកវាជាសមាជិកក្នុងគ្រួសាររបស់ខ្ញុំដែរ។ សព្វថ្ងៃ ខ្ញុំយកចិត្តទុកដាក់ថែទាំវាជានិច្ច ព្រោះអាត្នោត និងអាចម៉្យាជួយការងារស្រែចម្ការគ្រួសារខ្ញុំបានគ្រប់រដូវ ។

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

### ១. សេចក្ដីផ្ដើម

បង្ហាញពីសត្វនោះដោយប្រាប់ ៖

- ឈ្មោះសត្វ ... ភេទ ...
  អាយុ
- ទីលំនៅ ...។

### ២. តួសេចក្ដី

- រូបរាង
  - មាន ៖ តូច ធំ ស្គម ធាត់ ...


www.elibraryofcambodia.org

- កម្ពស់ ៖ ទាប ខ្ពស់ ...
- សម្បុរ ៖ ស ខ្មៅ ក្រហម ត្នោត ...
- ខ្លួន ៖ ជើង ក ភ្នែក ច្រមុះ មាត់ ត្រចៀក ស្នែង រោម ...

• គុណសម្បត្តិ
  - ចរិតលក្ខណៈ ៖ ស្លូត ឧស្សាហ៍ ...
  - ការប្រើប្រាស់ ៖ ភ្ជួរ រាស់ អូសរទេះ ចាំផ្ទះ ...
  - ការថែទាំ ៖ លាងទឹក ឱ្យស៊ីស្មៅ ផឹកទឹក ចាក់ថ្នាំបង្ការ ...
  - ផលប្រយោជន៍

• គុណវិបត្តិ
  - វាស៊ីរើសស្មៅ ពេលវាដាច់ម្តងៗពិបាកចាប់ ...។

## ៣.សេចក្តីបញ្ចប់

• ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះសត្វនោះ ...។


www.elibraryofcambodia.org

## គ.ការអនុវត្ត

*ប្រធាន ៖* គ្រួសារអ្នកចិញ្ចឹមសត្វជាច្រើន។ ចូរអ្នកពណ៌នាអំពីសត្វអ្វីមួយ ដែលអ្នកពេញចិត្តជាងគេ តាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។

### សេចក្តីអធិប្បាយ



គ្រួសារខ្ញុំចិញ្ចឹមក្របីមួយនឹម។ ក្របីមួយឈ្មោះអាខ្លឹង និងមួយទៀតឈ្មោះអាក្លាម។ ក្របីទាំងពីរនេះមានរូបរាងស្រដៀងគ្នា។ ក្របីនេះមានសម្បុរខ្មៅរលោង រោមខ្លីៗ។ វាមានក្បាលធំ ស្នែងទាំងគូរបស់វាឱបជារង្វង់ និងមានចុងស្រួច កឡើងធំ ត្រចៀកបះ។ ដងខ្លួនធាត់ធំ ខ្នងរាបដូចក្តារ ជើងមាំៗ តែកន្ទុយតូចខ្លីមានរោមតិចៗ។


www.elibraryofcambodia.org

អាខ្វឹង និងអាក្តាមស្លូតណាស់។ វាពុំដែលរកជល់ ឬវែធអ្នកណាឡើយ។ ក្របីខ្ញុំស្គាល់ម្ចាស់ ពេលឃើញម្ចាស់ វាងើយសម្លឹងមើល ហាក់ចង់សួរនាំពីរឿងអ្វីមួយ។ ពេលខ្លះ វាសម្លឹងមុខខ្ញុំ ស្រែកផង គ្រវីក្បាលដាក់ខ្ញុំផង ជញ្ជ្រាំជើងទំនងជាចង់ឱ្យខ្ញុំជូនវាដើរលេង ឬចង់ទៅស៊ីស្មៅអីចឹង។

សព្វថ្ងៃគ្រួសារខ្ញុំធ្វើស្រែចម្ការពឹងពាក់លើកម្លាំងអាខ្វឹង និងអាក្តាម។ វាមានកម្លាំងខ្លាំង។ នៅរដូវវស្សា ឪពុកខ្ញុំទឹមវាឱ្យអូសនង្គ័ល រនាស់ដើម្បីធ្វើស្រែ។ ក្រៅពីនេះ វាអាចអូសរទេះ ដឹកកណ្តាប់កាត់ទឹក កាត់ភក់ហាក់គ្មាននឿយហត់បន្តិចឡើយ។ នៅរដូវប្រាំង ឪពុកខ្ញុំទឹមវា ភ្ជួររាស់ដីចម្ការដើម្បីដាំដំណាំ។ លើសពីនេះ គ្រួសារខ្ញុំទឹមវាដឹកអុស ដឹកដីដឹកស្រូវអង្ករ និងគ្រឿងប្រើប្រាស់ផ្សេងៗទៀត។

ក្របីខ្ញុំដេកក្នុងក្រោល វាល់ព្រឹកខ្ញុំក្រោកពីព្រលឹមបញ្ចេញវាពីក្រោលយកទៅចងក្រោមដើមឈើ។ មុនពេលទៅសាលារៀន ខ្ញុំយកវាទៅចងនៅឯវាលឱ្យស៊ីស្មៅ។ ខ្ញុំពុំដែលលែងក្របីចោលឱ្យដើរស៊ីស្មៅទេ ព្រោះខ្លាចបាត់ ឬខ្លាចវាទៅស៊ីដំណាំគេផ្តេសផ្តាស។ ពេលទំនេរពីការងារខ្ញុំជិះលើខ្នងនាំវាទៅស៊ីស្មៅនៅឯវាល។ ខ្ញុំមិនធុញទ្រាន់នឹងឃ្វាលវាទេ ព្រោះខ្ញុំបានជិះលើខ្នងវា អានសៀវភៅ និងច្រៀងលេងយ៉ាងសប្បាយ។ ពេលល្ងាច ខ្ញុំយកវាទៅលាងទឹកឱ្យស្អាត។

ការចិញ្ចឹមក្របី ផ្តល់ប្រយោជន៍ច្រើនណាស់។ ក្រៅពីប្រើប្រាស់សម្រាប់កម្លាំងអូសទាញ វាផ្តល់នូវលាមកយ៉ាងច្រើនទៀតផង។ ជីលាមកគោក្របី ជាប្រភេទជីធម្មជាតិដ៏ល្អប្រសើរសម្រាប់ដាំដំណាំ។

ខ្ញុំពេញចិត្តនឹងអាខ្វឹងនិងអាក្តាមណាស់។ វាប្រៀបដូចជាសមាជិកក្នុងគ្រួសាររបស់ខ្ញុំដែរ។ សព្វថ្ងៃ ខ្ញុំយកចិត្តទុកដាក់ថែទាំវាជានិច្ច ព្រោះគ្រួសារខ្ញុំអាចធ្វើស្រែចម្ការបានគ្រប់រដូវដោយសារវា។



www.elibraryofcambodia.org

វិញ្ញាសាទី ៣

# តែងសេចក្ដី
# បែបពិពណ៌នាអំពីរុក្ខជាតិ

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

*ប្រធាន* ៖ នៅក្នុងសហគមន៍ប្អូនមានរុក្ខជាតិជាច្រើន។ ចូរអ្នកពណ៌នាអំពីរុក្ខជាតិអ្វីមួយឱ្យបានក្បោះក្បាយ។

### សេចក្ដីអធិប្បាយ



ប្រទេសកម្ពុជាយើង សម្បូរដើមត្នោតណាស់។ ដើមត្នោតជាអត្តសញ្ញាណជាតិខ្មែរ។ ដើមត្នោត ជារុក្ខជាតិកេរដំណែលរបស់គ្រួសារខ្មែរនីមួយៗ។ នៅជនបទស្ទើរតែគ្រប់គ្រួសារ សុទ្ធតែមានកេរមរតកដើមត្នោត។ គ្រួសារខ្មែរនិយមប្រើប្រាស់ដើមត្នោតណាស់។ ដើមត្នោត ដុះរាយប៉ាយស្ទើរពាសពេញទឹកដីនៃមាតុភូមិយើង។ ត្នោតមានប្រភេទផ្សេងៗគ្នាដូចជា ត្នោតទ្រាំង ត្នោតអាចម៍សេះ និងត្នោតដែលមានដើមខ្ពស់ៗគេហៅថាត្នោតលៃ។


www.elibraryofcambodia.org

កាលពីថ្ងៃអាទិត្យមុន ឪពុកខ្ញុំបាននាំខ្ញុំទៅទីវាលស្ពិតនៅក្រោយផ្ទះ ដើម្បីកាប់ស្លឹកត្នោតយកមកប្រើប្រាស់។ នៅទីនោះ មានដើមត្នោតជាច្រើន។

មើលពីចម្ងាយ ដើមត្នោតដុះព្រូងព្រាងពាសពេញទីវាល។ ដើមត្នោតមានរាងមូលខ្ពស់ត្រដែត ហាក់ដូចជាឆត្រកំពុងតម្លោះទុកនៅលើអាកាស។ ពេលចូលទៅជិត ដើមត្នោតមានរាងមូល ទ្រសំណុំស្លឹកមួយកញ្ចុំធំ។ ត្នោតគ្មានឫសកែវទេ គឺមានតែឫសតូចៗចាក់ស្រេះគ្នាទ្រទ្រង់ដើមយ៉ាងរឹងមាំមិនឱ្យរលំដួល។ តួដើមត្នោតមានពណ៌ប្រផេះគគ្រើមៈគន្លាក់តិចៗ ដែលជាស្នាមតាវចាស់របេះជ្រុះរហូត តាំងពីដើមវានៅតូច។ នៅផ្នែកខាងចុង មានតាវទ្រទប់ធាងបែកសាខាប្រកបដោយស្លឹកពណ៌បៃតងចាស់។ តាមចន្លោះធាងមានផ្កា និងផ្លែ។

ដើមត្នោតជារុក្ខជាតិមួយប្រភេទ ដែលមានអាយុវែងហើយងាយក្នុងការដាំដុះ។ គ្រួសារខ្មែរតាំងពីដូនតាបុរាណកាលមកនិយមដាំដើមត្នោតតាមភ្លឺស្រែ ទីទួល ភូមិចាស់ៗ តាមរបងផ្ទះជាដើម។ ដើមត្នោតខ្លះទៀត ដុះដោយសារផ្លែវាទុំជ្រុះ ឬដោយសារគេបោះគ្រាប់ទុំចោល។ ត្នោតជារុក្ខជាតិដែលមិនលំបាកក្នុងការថែទាំទេ ដោយគ្រាន់តែការ ឬកាប់តាវចាស់ចេញពីដើមឱ្យស្រឡះតែប៉ុណ្ណោះ។

ដើមត្នោតមានប្រយោជន៍ច្រើនយ៉ាង។ នៅតូចគេកាប់តាវរស់ យកមកដំហើយបូតយកជក់។ គេអាចយកជក់ទៅវេញជាកន្ទុះខ្សែ។ ខ្សែជក់មានគុណភាពល្អជាងខ្សែជ័រ។ ពេលត្នោតចាស់ មានផ្កា គេគាបផ្កាវាក្រងយកទឹកមករម្ងាស់បានជាស្ករ ដែលមានរសជាតិផ្អែមឈ្ងុយឆ្ងាញ់។ ផ្លែត្នោតនៅខ្ចី គេកាប់យកគ្រាប់ខ្ចី មកបរិភោគយ៉ាងឆ្ងាញ់ពិសា។ ពេលខ្លះប្រជាពលរដ្ឋយើង កាប់ផ្លែត្នោតយកមកលក់បានប្រាក់សម្រាប់ផ្គត់ផ្គង់


www.elibraryofcambodia.org

គ្រួសារ។ ផ្លែត្នោតទុំ តែងរបេះធ្លាក់ជ្រុះមកដីដោយឯកឯង។ ខ្មែរយើងនិយមយកផ្លែត្នោតទុំទៅធ្វើចាហួយ និងនំផ្សេងៗសម្រាប់បរិភោគ។ ពេលគ្រាប់ត្នោតទុំមានកំពីង គេពុះវាយកកំពីងមកធ្វើជាចំណីយ៉ាងពាប់ប្រសើរ។ ពោះ ធាងត្នោតអាចធ្វើជាខ្សែចំណង។ គេកាប់ស្លឹកត្នោត មកដេរជាកណ្ដូបសម្រាប់ប្រក់ដំបូលផ្ទះ រោង និងលំនៅស្ថាន។ ដើមវា គេអាចពុះច្រៀកយកមកធ្វើជាគ្រឿងសំណង់ និងធ្វើទូកបានទៀតផង។ បច្ចុប្បន្នសិប្បកម្មកែច្នៃសម្ភារៈមួយចំនួនបានយកដើមត្នោតមកធ្វើជាវត្ថុប្រើប្រាស់ និងវត្ថុតាំងលម្អផ្សេងៗដែលជាទីពេញនិយមសម្រាប់ភ្ញៀវទេសចរជាតិ និងបរទេស។

ខ្មែរយើងពេញចិត្តនឹងដើមត្នោតណាស់ ព្រោះវាជាសម្បត្តិតាំងពីដូនតាមក និងជាអត្តសញ្ញាណជាតិខ្មែរយើង។ ដូច្នេះ ប្រជាជនខ្មែរគ្រប់រូបមិនត្រូវកាប់បំផ្លាញដើមត្នោតនោះទេ។ យើងត្រូវថែរក្សា និងដាំដើមត្នោតបន្ថែមឱ្យបានច្រើន។ យើងគួរដាំត្នោតនៅកន្លែងដីទំនេរ ឬវាល ឬលើទួលឆ្ងាយពីស្រែ ឆ្ងាយពីផ្ទះ ព្រោះធាង និងផ្លែទុំអាចជ្រុះមកនាំឱ្យប៉ះពាល់ដំណាំស្រូវ ផ្ទះសម្បែង ឬដំណាំផ្សេងៗ។

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

### ១. សេចក្ដីផ្ដើម

- ទិដ្ឋភាពទូទៅ
- ពេលវេលាដែលអ្នកទៅទីនោះ
- ទីកន្លែងដែលរុក្ខជាតិនោះដុះ
- ឈ្មោះរុក្ខជាតិ ។


www.elibraryofcambodia.org

## ២. តួសេចក្ដី

- ទិដ្ឋភាពមើលពីចម្ងាយ
- ទិដ្ឋភាពពេលចូលទៅដល់
- រូបលក្ខណៈ
  - រូបរាង
  - ពណ៌
  - ដើម
  - មែកធាង
  - ស្លឹក
  - ផ្លែ ...
- ការដាំដុះ
- ការថែទាំ
- ផលប្រយោជន៍។

## ៣. សេចក្ដីបញ្ចប់

- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះរុក្ខជាតិនោះ។

# គ. ការអនុវត្ត

| | |
|---|---|
| *ប្រធាន ៖* | នៅក្នុងសហគមន៍ប្អូនមានរុក្ខជាតិជាច្រើន។ ចូរអ្នកពណ៌នាអំពីរុក្ខជាតិអ្វីមួយតាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។ |



www.elibraryofcambodia.org

វិញ្ញាសាទី ៤

# តែងសេចក្ដី បែបពិពណ៌នាអំពីវត្ថុ

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

*ប្រធាន* ៖ នៅផ្ទះអ្នកមានវត្ថុប្រើប្រាស់ជាច្រើន។ ចូរអ្នកពណ៌នាពីវត្ថុអ្វីមួយ ដែលអ្នកពេញចិត្តជាងគេឱ្យបានក្បោះក្បាយ។

### សេចក្ដីអធិប្បាយ




www.elibraryofcambodia.org

បច្ចុប្បន្ន សម្ភារៈប្រើប្រាស់ផ្សេងៗ មានការអភិវឌ្ឍកាន់តែទំនើបទាន់សម័យ ជាពិសេសគ្រឿងអេឡិចត្រូនិក។ គេបង្កើតសម្ភារៈទាំងនោះដើម្បីឆ្លើយតបតាមតម្រូវការរបស់មនុស្ស។ ជាពិសេសទូរស័ព្ទដៃត្រូវបានអភិវឌ្ឍកាន់តែទំនើបដែរ។ នៅតាមទីផ្សារមានទូរស័ព្ទដៃទំនើបៗជាច្រើន ។ សព្វថ្ងៃ មិនថាមនុស្សចាស់ ឬយុវជនទេ ពួកគេនិយមប្រើប្រាស់ទូរស័ព្ទដៃទំនើបៗ។ ឪពុកខ្ញុំក៏មានទូរស័ព្ទដៃទំនើបមួយគ្រឿងដែរ ។

ទូរស័ព្ទនេះ មានរាងបួនជ្រុងទ្រវែងដូចចតុកោណកែង។ ពីខាងក្រៅលម្អដោយស៊ុមពណ៌មាស ដាំកម្ទេចត្បូងភ្លឺផ្លេកៗគួរឱ្យចាប់ចិត្ត។ នៅលើផ្ទៃខាងមុខ មានរូបភាពម៉ោងនិង ថ្ងៃ ខែ ឆ្នាំ សម្រាប់មើល។ ឪពុកឱ្យខ្ញុំប្រើប្រាស់ទូរស័ព្ទនេះជារៀងរាល់ថ្ងៃ។ ពេលគេហៅចូលម្តងៗ វាមានសំឡេងពេទ័យហ៊ាងពីរោះ តែពេលខ្លះ ខ្ញុំមិនឮសំឡេងទេ ព្រោះឪពុកខ្ញុំដាក់សំឡេងញ័រ ដើម្បីកុំឱ្យរំខានអ្នកដទៃ ។ ទូរស័ព្ទនេះ មានកម្មវិធីជាច្រើន ដូចជាត្រីវិស័យសម្រាប់ចង្អុលបង្ហាញទិស ផែនទីបង្ហាញតំបន់និងពិភពលោក កម្មវិធីអក្សរខ្មែរ ម៉ាស៊ីនថតរូប ឬវីដេអូ។ ជាឯកសារមានវចនានុក្រមភាសាខ្មែរ ភាសាអង់គ្លេស វចនានុក្រមអង់គ្លេស-ខ្មែរ និងវចនានុក្រមខ្មែរ-អង់គ្លេស សម្រាប់ប្រើក្នុងការសិក្សា។ ឪពុកខ្ញុំប្រើ ទូរស័ព្ទនេះ ដោយភ្ជាប់ជាមួយប្រព័ន្ធអ៊ិនធឺណិត។ តាមរយៈប្រព័ន្ធ អ៊ិនធឺណិតនេះ យើងអាច ប្រើប្រាស់អ៊ីមែល ហ្វេសបុក អាន និងស្តាប់ព័ត៌មាន មើលទូរទស្សន៍ ស្វែងរកឯកសារ និងរូបភាពផ្សេងៗជាដើម។ ក្រៅពីនេះ ក៏មានកម្មវិធី កំសាន្តមួយចំនួន។

ការប្រើប្រាស់ទូរស័ព្ទ ផ្តល់អត្ថប្រយោជន៍ជាច្រើន ក្នុងការធ្វើទំនាក់ទំនងគ្នាបានយ៉ាងឆាប់រហ័សទាំងក្នុង និងក្រៅប្រទេស។ វាអាចបញ្ជូនឯកសារ សារផ្សេងៗ ផ្តល់ព័ត៌មានរហ័សទាន់ចិត្ត។ ក្រៅពីនេះ វាអាចជួយ


www.elibraryofcambodia.org

សម្រួលដល់ការសិក្សារបស់យើងទៀតផង។ ប៉ុន្តែការប្រើប្រាស់ទូរស័ព្ទក្នុងផ្លូវអវិជ្ជមាននឹងនាំគ្រោះថ្នាក់ដល់ខ្លួន និងសង្គមជាតិ។

## ខ.ការសិក្សាគម្រោងតែងសេចក្តី

### ១.សេចក្តីផ្តើម

- ឈ្មោះ ៖ វត្ថុអ្វី ...
- ទីតាំង ៖ នៅឯណា ...។

### ២.តួសេចក្តី

- រូបរាង មាន ៖ តូច ធំ វែង ខ្លី ...
- ការតុបតែងលម្អ ...
- ការប្រើប្រាស់ ៖ តើវត្ថុនោះសម្រាប់ធ្វើអ្វី ...
- ផលប្រយោជន៍ ...
- ការយកចិត្តទុកដាក់ និងការថែទាំ ...។

### ៣.សេចក្តីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះវត្ថុនោះ ...។

## គ.ការអនុវត្ត

| | |
|---|---|
| *ប្រធាន ៖* | នៅផ្ទះអ្នកមានសម្ភារៈប្រើប្រាស់ជាច្រើន តែអ្នកពេញចិត្តសម្ភារៈមួយជាងគេ។ ចូរអ្នកពណ៌នាពីវត្ថុនោះឱ្យបានគ្រោះក្រាយ។ |


www.elibraryofcambodia.org

វិញ្ញាសាទី ៥

# តែងសេចក្តី
# ពិពណ៌នាអំពីទីកន្លែង

## ក.ការសិក្សាអត្ថបទតែងសេចក្តីគំរូ

> *ប្រធាន* ៖ ចូរអ្នកពណ៌នាពីទីកន្លែងសំខាន់ណាមួយដែលប្អូនធ្លាប់ស្គាល់ឱ្យបានក្បោះក្បាយ។

### សេចក្តីអធិប្បាយ

កាលពីចុងសប្តាហ៍មុន ខ្ញុំនិងមិត្តរួមថ្នាក់បានទៅធ្វើទស្សនកិច្ចសិក្សានៅសារមន្ទីរជាតិដោយមានលោកគ្រូជាអ្នកដឹកនាំ។ សារមន្ទីរជាតិស្ថិតនៅខាងជើងជាប់ព្រះបរមរាជវាំងរាជធានីភ្នំពេញ។ អគារនេះ សង់អំពីថ្មជាប់ផ្ទាល់ដី មានដំបូលជាថ្នាក់ៗ ប្រក់ក្បឿង និងមានដំបូលកណ្តាលខ្ពស់ស្រួច។ មើលចំពីខាងមុខ យើងឃើញហោជាងប្រកបដោយក្បាច់



រចនាយ៉ាងល្អវិចិត្រ មានរាងជាព្រះសង្ហារនៅផ្នែកខាងលើ។ លោកគ្រូប្រាប់ថា សារមន្ទីរជាតិនេះបានស្ថាបនាឡើងតាំងពីឆ្នាំ១៩១៨ ក្នុងរាជ្យព្រះករុណាព្រះស៊ីសុវត្ថិ។ ទិដ្ឋភាពខាង ក្រៅធ្វើឱ្យខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ពិសេសជញ្ជាំងមានពណ៌ក្រហមខុសប្លែកពីសំណង់ដទៃទៀត។

ពេលចូលដល់ខាងក្នុង យើងខ្ញុំរំភើបចិត្តក្រៃលែងចំពោះវត្ថុបុរាណ


www.elibraryofcambodia.org

ដំច្រើនស្អេកស្កះ ដែលគេដាក់តម្រៀបតាំងជូនភ្ញៀវទស្សនា និងធ្វើការសិក្សាស្រាវជ្រាវ។ នៅទីនោះមានភ្ញៀវទស្សនាមិនតិចទេ តែមានសភាពស្ងប់ស្ងាត់ ពីព្រោះម្នាក់ៗសុទ្ធតែផ្ចង់អារម្មណ៍ទៅលើគ្រឿងចម្លាក់ដ៏ប្រណីត និងកត់ត្រា ឬផ្ទៀងស្តាប់ការអធិប្បាយរបស់មគ្គុទ្ទេសក៍។ នៅអគារទទឹងថ្ងៃផ្នែកខាងមុខមានរូបចម្លាក់ដ៏មានតម្លៃ ដែលសាងឡើងអំពីលោហធាតុផ្សេងៗមាន លង្ហិន សំរឹទ្ធ ស្ពាន់ ប្រាក់ជាដើម។ វត្ថុចម្លាក់ខ្លះបានសាងឡើងតាំងពី ៣០០ ឆ្នាំមុនគ្រិស្តសករាជ។ លុះមើលចប់ផ្នែកខាងមុខ លោកគ្រូបាននាំយើងទៅមើលអគារបីទៀតនៅខាងក្រោយ។ នៅទីនោះគេតម្កល់វត្ថុ និងរូបចម្លាក់ធ្វើពីថ្មភក់ និងថ្មផ្សេងទៀត ដែលសាងឡើងនៅសតវត្សទី៤ មកដល់សតវត្សទី១៩។ លោកគ្រូមានប្រសាសន៍ថា នៅទីនេះមានរូបចម្លាក់ទាំងអស់ជាង៤០០០រូប។ ការធ្វើទស្សនកិច្ចនៅថ្ងៃនោះ មានសារៈសំខាន់ណាស់។ រូបចម្លាក់ពីថ្ម និងលោហធាតុសុទ្ធតែស្នាដៃដែលជាព្រលឹង និងដួងវិញ្ញាណនៃបុព្វបុរសខ្មែរបន្សល់ទុក និងបាននិយាយប្រាប់យើងខ្ញុំអំពីប្រវត្តិសាស្ត្រ និងសម័យកាលដ៏រុងរឿងរបស់ជាតិយើង។ តាមរយៈការស្វែងយល់ ចង់ដឹង ចង់ឃើញវត្ថុចម្លាក់ខ្មែរអំពីសំណាក់ភ្ញៀវទេសចរបរទេស និងអ្នកសិក្សាស្រាវជ្រាវ បានធ្វើឱ្យយើងខ្ញុំដែលជាកុលបុត្រ កុលធីតាខ្មែរ រំភើបចិត្ត និងមានមោទនភាពចំពោះជាតិខ្លួនយ៉ាងក្រៃលែង។

ខ្ញុំពេញចិត្តនឹងសារមន្ទីរជាតិណាស់ ព្រោះជាបេតិកភណ្ឌរបស់យើង។

## ខ.ការសិក្សាគម្រោងតែងសេចក្តី

### ១.សេចក្តីផ្តើម

- ពេលវេលា ( ទៅទីនោះ ... )
- ទីកន្លែង ( ឈ្មោះទីកន្លែង ... ទីកន្លែងនោះស្ថិតនៅ ភូមិ ... ឃុំ ... ស្រុក ... ខេត្ត ... )



www.elibraryofcambodia.org

### ២.តួសេចក្ដី

- ទិដ្ឋភាពខាងក្រៅ ៖
  - ទិដ្ឋភាពមើលពីចម្ងាយ ( ទីតាំងនោះមានទ្រង់ទ្រាយដូចម្ដេច ? ប្រៀបដូចអ្វី ? ... )
  - ទិដ្ឋភាពពេលចូលទៅដល់ (ទីតាំងនោះមានទ្រង់ទ្រាយដូចម្ដេច ? ឃើញអ្វីខ្លះនៅទីនោះ ... )
- ទិដ្ឋភាពខាងក្នុង ៖
  - រូបរាង ឬទ្រង់ទ្រាយ ហេដ្ឋារចនាសម្ព័ន្ធខាងក្នុង (មានរូបរាងទ្រង់ទ្រាយដូចម្ដេច? ... )
  - វត្ថុ ឬសម្ភារៈ ( មានវត្ថុ ឬសម្ភារៈអ្វីខ្លះនៅទីនោះ ? ... )
  - សកម្មភាពអ្នកធ្វើការ ឬ អ្នករស់នៅទីនោះ ...
  - ទឹកចិត្តអ្នកធ្វើការ ឬ អ្នករស់នៅទីនោះ ...
  - សកម្មភាពអ្នកទៅទស្សនាទីនោះ ...
- សារៈសំខាន់ និងផលប្រយោជន៍ ៖
  - ទីនោះមានសារៈសំខាន់ និងផលប្រយោជន៍ដូចម្ដេច ? ...។

### ៣.សេចក្ដីបញ្ចប់

- វាយតម្លៃទីកន្លែងនោះ ...
- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះទីកន្លែងនោះ។

## គ.ការអនុវត្ត

*ប្រធាន ៖* ចូរអ្នកពណ៌នាពីទីកន្លែងសំខាន់ណាមួយនៅក្នុងសហគមន៍អ្នក ឬទីកន្លែងដែលអ្នកធ្លាប់ស្គាល់តាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។


www.elibraryofcambodia.org

វិញ្ញាសាទី ៦

# តែងសេចក្ដី
# បែបពិពណ៌នាអំពីទេសភាព

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

| |
|---|
| *ប្រធាន ៖* ចូរអ្នកពណ៌នាពីទេសភាពកន្លែងណាមួយដែលអ្នកធ្លាប់ស្គាល់ឱ្យបានក្បោះក្បាយ។ |

### សេចក្ដីអធិប្បាយ

រដូវប្រាំងបានកន្លងផុតទៅ រដូវវស្សាក៏ឈានមកដល់។ មេឃធ្លាប់តែស្រឡះ ព្រះទិនករធ្លាប់តែបញ្ចេញកាំរស្មីក្ដៅចែងចាំង មកលើភពផែនដី ប្រែជាស្រអាប់ដោយជុំពពកខ្មៅប្រផេះ។ ដីបែកក្រហែងប្រែជាមានទឹកដក់ជោកជាំ។ ព្រះភិរុណបង្អុរយ៉ាងញឹកញាប់ស្រោចស្រពមកលើព្រះធរណី ធ្វើឱ្យរុក្ខជាតិទាំងពួងល្ងតលាស់ស្រស់



បំព្រង។ វេលារសៀលនាថ្ងៃអាទិត្យមួយ ខ្ញុំបានទៅដើរកម្សាន្តនៅតាមវាលស្រែ។

គយគន់ពីចម្ងាយ វាលស្រែពណ៌ខៀវស្រងាត់លាតសន្ធឹងល្វឹងល្វើយជាប់ជើងមេឃ។ នៅឰដ៏វេហា(វេហាស៍) ហ៊ុមព័ទ្ធទៅដោយផ្ទាំងពពក មីរដេរដាស ពាសពេញ ហើយសោត់សៀនស្លៅ។


www.elibraryofcambodia.org

នៅតាមវាលស្រែ ដែលមានភ្លឺទ្វាត់ខ្វែងជារាងក្រឡាចក្រត្រង្គមានទឹកពព្រាំ។ ក្នុងស្រែសន្ទូងកំពុងបែកគុម្ពលូតលាស់ស្រស់បំព្រង។ វេលារសៀលត្រជាក់ ព្រះពាយបក់រំភើយៗ អង្រួនដើមស្រូវឱ្យលាស់យោកយោលប្រៀបដូចសរសៃរលកទឹកប្រជេញគ្នាយ៉ាងរន្ថើន។ បក្សាបក្សីមានកុក ក្រសារ នោលជាដើមកំពុងរកចំណី។ ខ្លះទៀតកំពុងដេញប្រចឹកគ្នាសម្រែកលាន់ឮទ្រហឹងអឺងកង។ នៅលើអាកាសមានបក្សាបក្សីខ្លះកំពុងហើរទាំងហ្វូងៗសំដៅទៅរកទ្រនំ។ កួនព្រាត់ កង្កែបអាចម៍គោ ស្រែកបណ្តាក់គ្នាហាក់ដូចជាកំពុងច្រៀងលេងសប្បាយនឹងទឹកភ្លៀង។ កសិករជូតក្បាលក្រមានាំគ្នាបោចស្នាក្នុងស្រែ ខ្លះកំពុងទប់ភ្លឺស្រែ ខ្លះកំពុងព្រាចដី។ កសិករខ្លះកំពុងនេសាទដោយចងសន្ទូច ដាក់បង្កៃ និងខ្លះទៀតកំពុងស្ពាយទ្រូ លបទៅរកកន្លែងដាក់។ អ្នកខ្លះធ្វើការបណ្ដើរ ស្រែកច្រៀងបណ្ដើរ ដើម្បីបំបាត់ភាពនឿយហត់។ សំឡេងកសិករលាយឡំជាមួយនឹងសំឡេងសត្វចម្រុះឮ ប្រៀបដូចជាតូរ្យតន្ត្រីមួយវង់ កំពុងប្រគំយ៉ាងពីរោះរងំ។

គ្រានោះ ផ្ទៃមេឃប្រែជាស្រកានាគពណ៌លឿងទុំបញ្ជាក់ថា ជិតដល់ពេលវេលាដែលព្រះអាទិត្យនឹងចាកចេញពីភពផែនដីយើងនេះ ទៅកាន់ភពដទៃផ្សេងទៀត។ ខ្យល់បរិសុទ្ធបក់ត្រសៀកៗធ្វើឱ្យយើងដកដង្ហើមបានស្រួល និងមានផាសុកភាពក្រៃលែង។ គុណ្យភាពនៅក្នុងបរិស្ថានបានធ្វើឱ្យជីវិតមនុស្សមានក្ដីសុខក្សេមក្សាន្តតាមបែបធម្មជាតិ។ ដូច្នេះ យើងត្រូវថែទាំបរិស្ថាននេះឱ្យល្អជានិច្ច។យើងទាំងអស់គ្នាមិនត្រូវធ្វើឱ្យបរិស្ថានកខ្វក់ឡើយ។


www.elibraryofcambodia.org

ខ្ញុំពេញចិត្តនឹងទេសភាពវាលស្រែនេះណាស់។ ពេលមានអារម្មណ៍អផ្សុកខ្ញុំតែងតែនឹកចង់ទៅកម្សាន្តនៅទីនោះជានិច្ច។

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

### ១.សេចក្ដីផ្ដើម

- ពេលវេលា (ទៅទីកន្លែងនោះ ...)
- ឈ្មោះទីកន្លែង (ទីនោះជាកន្លែងអ្វី ... )

### ២.តួសេចក្ដី

- ទិដ្ឋភាពទូទៅមើលពីចម្ងាយ
- សណ្ឋានទីកន្លែង ( មានលក្ខណៈ ទ្រង់ទ្រាយដូចម្ដេច? ... )
- ធម្មជាតិ (ខ្យល់ ពន្លឺ មេឃ ពពក ពណ៌ ...ដោយធ្វើការប្រៀបធៀប)
- សកម្មភាពនិងសូរសំឡេង (មនុស្ស សត្វ វត្ថុ រុក្ខជាតិ ... ដោយធ្វើការប្រៀបធៀប)

### ៣.សេចក្ដីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះទេសភាពទីកន្លែងនោះ ។

## គ.ការអនុវត្ត

*ប្រធាន* ៖ ចូរអ្នកពណ៌នាពីទេសភាពទីកន្លែងណាមួយនៅក្នុងសហគមន៍អ្នក ឬទីកន្លែងដែលអ្នកធ្លាប់ស្គាល់តាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។


www.elibraryofcambodia.org

វិញ្ញាសាទី ៧

# តែងសេចក្ដី
# បែបពិពណ៌នាអំពីធាតុភូតធម្មជាតិ

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

*ប្រធាន* ៖ រៀងរាល់ឆ្នាំ ក្នុងប្រទេសកម្ពុជាយើងតែងជួបប្រទះនូវគ្រោះធម្មជាតិខ្លះៗ។ ចូរអ្នកពណ៌នាពីធាតុភូតធម្មជាតិអ្វីមួយ ឱ្យបានក្បោះក្បាយ។

### សេចក្ដីអធិប្បាយ

ដើមរដូវវស្សានេះ តែងកើតមានខ្យល់ព្យុះជារឿយៗ។ កាលពីវេលារសៀលថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ មានខ្យល់ព្យុះដ៏ធំមួយបានបោកបក់យ៉ាងខ្លាំងមកលើស្រុកមេសាង ខេត្តព្រៃវែង។



មុនពេលកើតហេតុ ផ្ទាំងពពកធំៗរសាត់មកផ្តុំគ្នាយ៉ាងមីរដេរដាស គ្របដណ្ដប់លើភូមិសាស្ត្រនៃស្រុកមេសាង។ មេឃចាប់ផ្ដើមងងឹត ខ្យល់បក់បោកយ៉ាងខ្លាំង។ សូរសន្ធឹកខ្យល់លាន់ឮគ្រឹកៗ ពពកប្រែជាខ្មៅខ្មួលខ្មាញ់ទម្លាក់កន្ទុយនាគនៅចំពីលើភូមិអ្នកស្រុក។ នេះជាសញ្ញាខ្យល់ព្យុះកួចដែលនឹងកើតមានយ៉ាងរហ័សបំផុត។ អ្នកស្រុកដែលឃើញទិដ្ឋភាពនេះ ភ័យព្រួយយ៉ាងពន្លឹមា អ្នកខ្លះឆ្លេឆ្លា នាំកូនចៅរត់សំដៅទៅ



www.elibraryofcambodia.org

គេហដ្ឋាន។ អ្នកខ្លះម្ញីម្នាយកគោ ក្របី ជ្រូក មាន់ ទា ទៅរកទីជម្រកមានសុវត្ថិភាព។ សន្ទឹកឱ្យល់លាន់កញ្ជ្រើកធរណី មួយរំពេចនោះ ខ្យល់ព្យុះបានបោកបក់មកដល់។ ដើមឈើតូចធំយោលយោកទន់ពុងសំយុងសម្លុបចុះស្ទើរដល់ដី។ រុក្ខជាតិខ្លះដែលគ្មានឫសកែវរឹងមាំបានដួលរលំរណ្ដោករណែលបន្តបន្ទាប់គ្នា។ ផ្ទះរបស់អ្នកស្រុកខ្លះរង្គើរញ្ជួយតាំងពីជើងសសរហូតដល់ដំបូល។ សត្វចតុប្បាទ សត្វស្លាបក្រាបចុះដើម្បីការពារខ្លួន។ មនុស្សម្នារកទីកន្លែងតត់មត់អង្គុយឱបគ្នា ភ័យរន្ធត់ ញ័រខ្លួនទទ្រើក។ សន្ទុះឱ្យល់កាន់តែបង្កើន កម្លាំងខ្លាំងឡើងៗ។ លំនៅស្ថានតូចៗ យ៉ឹងតាមខ្យល់។ លំនៅស្ថានធំៗខ្លះបាក់ស្រុត ខ្លះសណ្ដោកធ្លាក់ចុះពីលើជើងតាង និងខ្លះទៀតដួលរលំរាបដល់ដី។ សត្វខ្លះត្រូវខ្យល់ក្លួចយ៉ឹង ខ្លះត្រូវរបួស ខ្លះស្លាប់ដោយដើមឈើ និងផ្ទះរលំសង្កត់។ អ្នកស្រុកខ្លះភ័យស្រែកឆោឡោរកគេជួយ។ អ្នកខ្លះស្រែកទ្រហោយំ ដោយការខូចខាតទ្រព្យសម្បត្តិ និងការឈឺចាប់ដោយសាររបួស។

ប្រមាណជិតកន្លះម៉ោងក្រោយមក ព្យុះសង្ឃរាបានថយឥទ្ធិពលរបស់ខ្លួនបន្តិចម្ដងៗរហូតដល់ស្ងប់ស្ងាត់។ ក្រោយពេលកើតហេតុ ព្យុះនេះបានបន្សល់ទុកនូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរ សាលារៀន មន្ទីរពេទ្យ លំនៅស្ថានខ្លះសណ្ដោកចេញដួលរលំបាក់បែករាប់ជាងមួយរយខ្នង។ ក្នុងគ្រាជួបគ្រោះអាសន្ននេះ អ្នកភូមិទាំងអស់រួមគ្នាជួយរុះរើផ្ទះបាក់បែក ដើម្បីរៀបចំសង់ឡើងវិញ។ អ្នកខ្លះធ្វើរោងស្នាក់នៅបណ្ដោះអាសន្ន។ អ្នកខ្លះទៀត ជួយដឹកជញ្ជូនអ្នករបួសទៅមន្ទីរពេទ្យ។ អាជ្ញាធរមូលដ្ឋានបានចាត់ចែងកម្លាំងចុះជួយប្រជាជនរងគ្រោះយ៉ាងសស្រោកសស្រាំ។

ព័ត៌មានអំពីគ្រោះមហន្តរាយដោយព្យុះសង្ឃរា ត្រូវបានផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៍ ហើយបានដឹងគ្រប់ៗគ្នា។


www.elibraryofcambodia.org

ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីបញ្ហាខ្យល់ព្យុះ ព្រោះជាបាតុភូតធម្មជាតិបង្កគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់មនុស្ស សត្វ រុក្ខជាតិដែលយើងពិបាកនឹងរកវិធីទប់ស្កាត់ណាស់ ប៉ុន្តែយើងអាចរកកន្លែងការពារខ្លួនបានមុនពេលដែលបាតុភូតនេះមកដល់។ ខ្យល់ព្យុះបានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចទៀតផង។

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

### ១.សេចក្ដីផ្ដើម

- ពេលវេលា
- ទីកន្លែង
- ឈ្មោះបាតុភូតធម្មជាតិ

### ២.តួសេចក្ដី

- មុនពេលកើតហេតុ
  - ទិដ្ឋភាពទូទៅនៃធម្មជាតិ
  - សញ្ញានៃបាតុភូតធម្មជាតិ
  - សកម្មភាពមនុស្សមុនពេលបាតុភូតធម្មជាតិមកដល់
- ពេលកើតហេតុ
  - ទិដ្ឋភាពក្នុងពេលចាប់ផ្ដើមបាតុភូតធម្មជាតិ
  - សកម្មភាពមនុស្ស សត្វ ពេលបាតុភូតធម្មជាតិផ្ដើមមកដល់
  - ទិដ្ឋភាពពេលបាតុភូតធម្មជាតិកំពុងកើតឡើង
  - សកម្មភាពមនុស្ស សត្វពេលបាតុភូតធម្មជាតិកំពុងកើតឡើង
  - ទិដ្ឋភាពចុងបញ្ចប់នៃបាតុភូតធម្មជាតិ
  - សកម្មភាពមនុស្សនៅចុងបញ្ចប់នៃបាតុភូតធម្មជាតិ


www.elibraryofcambodia.org

- ក្រោយពេលកើតហេតុ
  - ទិដ្ឋភាពនៃការខូចខាត
  - សកម្មភាពក្រោយពេលកើតហេតុ ។

## ៣.សេចក្ដីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញពីចំណាប់អារម្មណ៍ចំពោះបាតុភូតធម្មជាតិ ។

## ង.ការអនុវត្ត

| | |
|---|---|
| *ប្រធាន ៖* | រៀងរាល់ឆ្នាំក្នុងប្រទេសកម្ពុជាយើងតែងជួបប្រទះនូវគ្រោះធម្មជាតិខ្លះៗ។ ចូរអ្នកពណ៌នាពីបាតុភូតធម្មជាតិអ្វីមួយដែលបានកើតឡើង តាមគម្រោងខាងលើឱ្យបានគ្រោះក្សាយ។ |



www.elibraryofcambodia.org

វិញ្ញាសាទី ៨

# តែងសេចក្ដី
# បែបពិពណ៌នាអំពីឧបទ្ទវហេតុ

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

| | |
|---|---|
| *ប្រធាន* ៖ | នៅក្នុងសហគមន៍អ្នកតែងជួបប្រទះនូវឧបទ្ទវហេតុផ្សេងៗជារឿយៗ។ ចូរអ្នកពណ៌នាពីឧបទ្ទវហេតុអ្វីមួយឱ្យបានក្បោះក្បាយ។ |

### សេចក្ដីអធិប្បាយ

កាលពីថ្ងៃសុក្រ ត្រូវនឹងថ្ងៃ១៥កើតពេញបូណ៌មី ខែចេត្រ ជាថ្ងៃឧបោសថសីល នៅផ្ទះលោកយាយ សួន សំ ស្ថិតក្នុងភូមិ "គ" មានគ្រោះអគ្គិភ័យមួយបានកើតឡើង។



ថ្ងៃនោះ លោកយាយសួន សំបានអញ្ជើញទៅវត្ត ដោយយកចង្ហាន់ និងគ្រឿងសក្ការៈមួយចំនួនទៅប្រគេន ព្រះសង្ឃនៅវត្តមួយ ដែលនៅមិនឆ្ងាយពីភូមិប៉ុន្មានទេ។ ពេល ប្រគេនចង្ហាន់លោករួចរាល់ហើយ គាត់និងចាស់ទុំនៅក្នុងភូមិអង្គុយជជែកគ្នាពីនេះ ពីនោះទម្រាំព្រះសង្ឃឆាន់រួចនឹងបានត្រឡប់មកផ្ទះវិញ។ ប្រមាណជាម៉ោងដប់មួយកន្លះថ្ងៃត្រង់ ស្រាប់


www.elibraryofcambodia.org

តែមានមនុស្សម្នាផ្អើលឈូឆរ  រត់សំដៅទៅភូមិដោយស្រែកប្រាប់គ្នាថា មានភ្លើងឆេះផ្ទះ។

នៅឯគេហដ្ឋានរបស់លោកយាយ សួន សំ វិញកំពុងមានផ្សែងនិងអណ្តាតភ្លើងហុយផ្តោលចេញពីដំបូល។  ខណៈនោះមានខ្យល់បក់មកតិចៗ  ដូចជានាំភ្លើងឱ្យឆេះខ្លាំងឡើងៗ។  អ្នកភូមិទាំងចាស់ទាំងក្មេងផ្អើលឈូឆរ រត់ប្រសេចប្រសាច ស្រែកបង្អូកហៅគ្នីគ្នាមកជួយពន្លត់ភ្លើង អ្នកខ្លះស្រវាបានធុង អ្នកខ្លះកាន់ធុង នាំគ្នារត់ប្រញាប់ទៅរកដងទឹក។ មនុស្សម្នា កកកុញនៅខាងមុខកន្លែងភ្លើងឆេះ។ ប្រុសៗដែលនៅក្នុងវ័យពេញកម្លាំងនាំគ្នាផាក់ទម្លាយទ្វារស្នុះចូលក្នុងផ្ទះ ដើម្បីជញ្ជូនយកសម្ភារៈចេញ។ អ្នកខ្លះស្រវាបានខោអាវ អ្នកខ្លះយកហិប អ្នកខ្លះសែងទូ និងអ្នកខ្លះទៀតជញ្ជូនចានឆ្នាំង ចេញពីក្នុងផ្ទះមករក្សាខាងក្រៅ។

ខ្យល់បក់កាន់តែខ្លាំង  អណ្តាតភ្លើងកាន់តែខ្ពស់ឡើងៗ  មើលទៅប្រៀបដូចជាភ្នំភ្លើងកំពុងឆេះយ៉ាងសន្ធោសន្ធៅ។ ភ្លើងកំពុងពេញក្រមុំបញ្ចេញអណ្តាតភ្លើងក្រហមឆ្អៅ  ផ្កាភ្លើង  និងផ្សែងខ្មៅហុយខ្មួលខ្មាញ់ទៅលើអាកាសវេហាស៍។   អ្នកស្រុកហាក់ដូចជាអស់សមត្ថភាពក្នុងការពន្លត់ភ្លើងនេះហើយ។ ភ្លើងកំពុងឆេះពេញទំហឹង ចំហាយក្តៅភាយៗមិនអាចអ្នកណាទៅជិតបានឡើយ។ មនុស្សម្នាទាំងឡាយ កំពុងឈរមើលត្រៀបត្រា។  ម្ចាស់ផ្ទះកំពុងស្រែកទ្រហោយំ  ដោយក្តីស្តាយស្រណោះទ្រព្យសម្បត្តិកេរដំណែល  តាំងពីដូនតាមក។  ដោយមិនដឹងថាត្រូវធ្វើដូចម្តេច  អ្នកស្រុកបានត្រឹមតែជួយសោកស្តាយស្រណោះ  និងនិយាយលួងលោមលោកយាយ សួន សំតែប៉ុណ្ណោះ។ ប៉ុន្តែសំណាងល្អភ្លើងមិនបានឆេះរាលដាលដល់ផ្ទះអ្នកផ្សេងឡើយ  ពីព្រោះផ្ទះលោកយាយ  សួន សំនៅឃ្លាតឆ្ងាយពីគេ។


www.elibraryofcambodia.org

មួយម៉ោងក្រោយមក អណ្ដាតភ្លើងបានថមថយឥទ្ធិពលកំណាចរបស់វាបន្តិចម្ដងៗ។ ឯផ្ទះក៏ស្រុតរលំបាក់ អណ្ដាតភ្លើងក៏រលត់ហើយនៅសល់តែរងើកភ្លើងក្រហមឆ្អៅ។ មនុស្សម្នានាំគ្នាជះទឹកពន្លត់រងើកភ្លើង អ្នកខ្លះខំរើឆ្កឹះគកាយរកមើលក្រែងមានរបស់នៅសេសសល់។

គ្រោះអគ្គិភ័យមិនត្រឹមតែបំផ្លិចបំផ្លាញទ្រព្យសម្បត្តិយ៉ាងធ្ងន់ធ្ងរ តែអាចឆក់យកជីវិតមនុស្ស សត្វ តែក្នុងមួយពព្រិចភ្នែកប៉ុណ្ណោះ។ ដូចចាស់បុរាណបានពោលទុកមកថា ៖ " ស្ងួតស្លាប់ចា កុំឱ្យស្លាប់មេ ស្ងួតលិចទូកកណ្ដាលទន្លេ កុំឱ្យភ្លើងឆេះផ្ទះ " ។ ស្ថានភាពបែបនេះ អ្នកណាក៏មិនអាចទប់អារម្មណ៍បានដែរ គឺត្រូវតែទ្រហោយំ ទួញសោកសោកសង្រេង ឈឺចាប់ កើតទុក្ខ និងមានអ្នកខ្លះរហូតដល់ចង់សម្លាប់ខ្លួនឯងទៀតផង។

ខ្ញុំមានអារម្មណ៍រន្ធត់ក្រៃលែង និងសូមចូលរួមចំណែកសោកស្ដាយជាពន់ពេក ជាមួយក្រុមគ្រួសារជនរងគ្រោះ។ ដូច្នេះ ដើម្បីការពារកុំឱ្យហេតុការណ៍ភ្លើងឆេះផ្ទះកើតឡើង យើងត្រូវមានការប្រុងប្រយ័ត្នចំពោះភ្លើងជានិច្ចដូចជាភ្លើងចង្ក្រាន ភ្លើងចង្កៀង ភ្លើងទៀន ធូប ភ្លើងដុតសំរាមជាដើម។

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

### ១. សេចក្ដីផ្ដើម

- ពេលវេលា
- ទីកន្លែង
- ឈ្មោះឧបទ្ទវហេតុ ។


www.elibraryofcambodia.org

## ២.តួសេចក្ដី

- មុនពេលកើតហេតុ
  - ទិដ្ឋភាពទូទៅ
  - សកម្មភាពមុនពេលកើតឧបទ្ទវហេតុ
- ពេលកើតហេតុ
  - ទិដ្ឋភាពពេលឧបទ្ទវហេតុចាប់ផ្ដើមកើតឡើង
  - សកម្មភាពមនុស្សពេលឧបទ្ទវហេតុចាប់ផ្ដើមកើតឡើង
  - ទិដ្ឋភាពពេលឧបទ្ទវហេតុកំពុងកើតឡើង
  - សកម្មភាពមនុស្សពេលឧបទ្ទវហេតុកំពុងកើតឡើង
  - ទិដ្ឋភាពចុងបញ្ចប់នៃឧបទ្ទវហេតុ
  - សកម្មភាពអ្នកស្រុកនៅចុងបញ្ចប់នៃឧបទ្ទវហេតុ
- ក្រោយពេលកើតហេតុ
  - ទិដ្ឋភាពនៃការខូចខាត
  - សកម្មភាពអ្នកស្រុកក្រោយពេលកើតហេតុ
  - សកម្មភាពអាជ្ញាធរមូលដ្ឋាន ឬអង្គការមនុស្សធម៌ផ្សេងៗ ។

## ៣.សេចក្ដីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញពីចំណាប់អារម្មណ៍ចំពោះឧបទ្ទវហេតុ។

## ឥ.ការអនុវត្ត

*ប្រធាន ៖* នៅក្នុងសហគមន៍អ្នកតែងជួបប្រទះនូវឧបទ្ទវហេតុផ្សេងៗជារឿយៗ។ ចូរអ្នកពណ៌នាពីឧបទ្ទវហេតុអ្វីមួយដែលបានកើតឡើងតាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។


www.elibraryofcambodia.org

វិញ្ញាសាទី ៩

# តែងសេចក្ដី
# បែបពិពណ៌នាអំពីពិធីផ្សេងៗ

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

*ប្រធាន ៖* នៅក្នុងសហគមន៍អ្នកតែងរៀបចំព្រារព្ធធ្វើពិធីបុណ្យផ្សេងៗ។ ចូរអ្នកពណ៌នាពីពិធីបុណ្យអ្វីមួយឱ្យបានក្បោះក្បាយ។

### សេចក្ដីអធិប្បាយ

ពិធីបុណ្យនានាក្នុងសង្គមខ្មែរភាគច្រើនគឺជាលំនាំដែលធ្វើឡើងតាមទំនៀមទម្លាប់ ប្រពៃណីមានតាំងពីបុរាណកាលមក។ បច្ចុប្បន្ននេះមានពិធីបុណ្យមួយដែលប្រជាជនខ្មែរ គ្រប់ស្រទាប់វណ្ណៈតែងតែធ្វើ ទោះបីអ្នកមាន អ្នកក្រក្ដី គឺបុណ្យខួបគ្រប់ប្រាំពីរថ្ងៃ។ជាក់ស្ដែង កាលពីថ្ងៃសៅរ៍ទី២២ ខែធ្នូ ឆ្នាំ២០១២ ត្រូវនឹង០៩ កើត ខែមិគសិរ ឆ្នាំរោង ចត្វាស័ក ព.ស ២៥៥៦ នៅផ្ទះអំប្រុសខ្ញុំមានរៀបចំពិធីបុណ្យខួបគម្រប់ ៧ថ្ងៃ ដើម្បីឧទ្ទិសកុសល ជូនដល់វិញ្ញាណក្ខន្ធឧបាសិកា សួន ហ៊ាង ដែលបានទទួលអនិច្ចកម្មទៅ ក្នុងជន្មាយុ ៨៥ឆ្នាំ ដោយជរាពាធ។ ពិធីបុណ្យនេះផ្ដើមឡើង ចាប់ពីពេលរសៀល ហើយឆ្លងចូលទៅព្រឹកថ្ងៃស្អែកទៀត នៅព្រឹកនៃថ្ងៃចាប់ផ្ដើមពិធី បងប្អូនញាតិសន្ដាន សាច់សាលោហិតមកជួយរៀបចំផ្ទះ សង់រោង បោសសម្អាត និងតុបតែងកន្លែងរៀបចំពិធីយ៉ាងស្អាត។


www.elibraryofcambodia.org

វេលារសៀល ជាពេលប្រារព្ធពិធីបុណ្យ។ ប្រមាណជាម៉ោងបីរសៀល ភ្ញៀវទៅចូលបច្ច័យបុណ្យជាហូរហែ បន្តបន្ទាប់គ្នាមិនដាច់។ លោកតាអាចារ្យកំពុងមមាញឹកក្នុងការឱ្យពរជ័យដល់ភ្ញៀវ ដែលបានអញ្ជើញមកចូលបច្ច័យបុណ្យ។ អ្នកផ្តើមបុណ្យឈររាក់ទាក់អញ្ជើញភ្ញៀវទាំងអស់ឱ្យចូលអង្គុយក្នុងរោងបុណ្យ ដើម្បីពិសាភោជនាហារ។ ក្រោយពីពិសាភោជនាហាររួច ភ្ញៀវខ្លះបានត្រឡប់ទៅលំនៅស្ថានវិញ ចំណែកភ្ញៀវខ្លះទៀតបន្ត រង់ចាំចូលរួមពិធីសូត្រមន្តចម្រើន ព្រះបរិត្ត និងស្តាប់ធម៌ទេសនា។ វេលាព្រលប់ ព្រះសង្ឃនិមន្តមកដល់ គេចាប់ផ្តើមធ្វើពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងសម្តែងធម្មទេសនា។ លុះវេលាយប់បន្តិច មានការសម្តែងសិល្បៈជូនបងប្អូនញាតិមិត្ត ដែលអញ្ជើញចូលរួមក្នុងពិធីបុណ្យទាំងអស់ កម្សាន្តរហូតដល់យប់ជ្រៅ។

ព្រឹកឡើងជាថ្ងៃបង្ហើយបុណ្យ គេរៀបចំចង្ហាន់ និងទេយ្យទានវេរប្រគេនព្រះសង្ឃធ្វើពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់វិញ្ញាណក្ខន្ធអ្នកស្លាប់។ គ្រប់គ្នាមានទឹកមុខរីករាយ ដោយមានជំនឿថា ព្រលឹងអ្នកស្លាប់ទៅពិតជាបានទទួលកុសលបុណ្យពីការឧទ្ទិសបញ្ជូនទៅដល់គាត់។

នៅចុងបញ្ចប់នៃពិធីបុណ្យ បងប្អូន ញាតិសន្តាន មិត្តភក្តិទាំងអស់បានវិលត្រឡប់ទៅវិញ។ ម្ចាស់ដើមបុណ្យបានថ្លែងអំណរគុណដល់ភ្ញៀវទាំងអស់ដែលបានអញ្ជើញមកចូលរួម។ ពិធីនេះ ប្រព្រឹត្តទៅយ៉ាងអធឹកអធមក្រៃលែង។

ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ដែលបានចូលរួមក្នុងពិធីនេះ ព្រោះវាធ្វើឱ្យខ្ញុំបានយល់ដឹងពីគន្លងទំនៀមទម្លាប់ប្រពៃណីខ្មែរយើងតាំងពីបុរាណកាលមក។


www.elibraryofcambodia.org

## ខ.ការសិក្សាគម្រោងតែងសេចក្តី

### ១. សេចក្តីផ្តើម

- ពិធីបុណ្យជាទំនៀមទម្លាប់ ប្រពៃណីខ្មែរ
- ពេលវេលា
- ទីកន្លែង
- ឈ្មោះពិធីបុណ្យ
- គោលបំណងនៃពិធីបុណ្យ ។

### ២. តួសេចក្តី

- មុនប្រារព្ធពិធីបុណ្យ
  - ការអញ្ជើញភ្ញៀវ
  - រៀបចំបោសសម្អាតផ្ទះ
  - រៀបចំតុបតែងផ្ទះ
  - ការសង់រោង
  - ត្រៀមរៀបចំម្ហូបចំណី គ្រឿងសក្ការបូជា។
- ពេលប្រារព្ធពិធីបុណ្យ

  រសៀលនិងយប់ថ្ងៃទី១
  - ការជួបជុំគ្នា
  - ការទទួលភ្ញៀវ
  - ការចូលបុណ្យ
  - ការពិសាភោជនាហារ
  - ការសូត្រមន្តចម្រើនព្រះបរិត្ត
  - ការសម្តែងធម្មទេសនា
  - ការសម្តែងសិល្បៈ ឬ សកម្មភាពកម្សាន្តផ្សេងៗ។


www.elibraryofcambodia.org

ព្រឹកថ្ងៃទី២

- ការវេរចង្ហាន់ប្រគេនព្រះសង្ឃ
- ការបង្សុកូលឧទ្ទិសកុសល

• ក្រោយពេលព្រារព្ធពិធីបុណ្យ

- ការថ្លែងអំណរគុណចំពោះអ្នកបានចូលរួម
- ការប្រមូលបំទៅវិញរបស់គៀរ
- ការរុះរោង
- ការរៀបចំផ្សេងៗ។

៣.សេចក្តីបញ្ចប់

• បង្ហាញពីចំណាប់អារម្មណ៍ និងមនោសញ្ចេតនារបស់អ្នកតែងចំពោះពិធីបុណ្យនេះ។

## ឝ.ការអនុវត្ត

> *ប្រធាន ៖* នៅក្នុងសហគមន៍អ្នកតែងរៀបចំប្រារព្ធធ្វើពិធីបុណ្យផ្សេងៗ។ ចូរអ្នកពណ៌នាពីពិធីបុណ្យអ្វីមួយតាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។


www.elibraryofcambodia.org

វិញ្ញាសាទី ១០

# តែងសេចក្ដី
# បែបពិពណ៌នាអំពីសកម្មភាព

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

*ប្រធាន ៖* នៅតាមសាលារៀននានាក្នុងសហគមន៍របស់អ្នក តែងរៀបចំការប្រកួតកីឡាជារៀងរាល់ឆ្នាំ។ ចូរអ្នកពណ៌នាពីសកម្មភាពប្រកួតកីឡាណាមួយឱ្យបានក្បោះក្បាយ។

### សេចក្ដីអធិប្បាយ

រៀងរាល់ឆ្នាំ នៅស្រុកខ្ញុំតែងមានរៀបចំការប្រកួតកីឡាមិត្តភាពរវាងសាលារៀននីមួយៗ។ ការប្រកួតតែងផ្លាស់ប្ដូរទីកន្លែងរៀងរាល់ឆ្នាំ។ ឆ្នាំនេះកាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៤ នៅសាលារៀនខ្ញុំមានរៀបចំការប្រកួតកីឡាបាល់ទាត់ វគ្គផ្ដាច់ព្រ័ត្រ រវាងក្រុមឫទ្ធិសែន និងក្រុមព្រះរាម ដើម្បីដណ្ដើមជ័យលាភី និងជ្រើសរើសយកក្រុមឈ្នះលេខ១ ទៅប្រកួតបន្តទៀតនៅខេត្ត។




www.elibraryofcambodia.org

មុនពេលប្រកួតពីរទៅបីថ្ងៃ គេបានរៀបចំឈូសឆាយដី គូសភាសទីលានបាល់ទាត់ទៅតាមលក្ខណៈបច្ចេកទេស។ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក បានរៀបចំការប្រជុំដើម្បីបង្កើតគណៈកម្មការសម្រាប់ការប្រកួត។ ថ្ងៃប្រកួតចូលមកដល់ នារសៀលម៉ោង៣ មនុស្សម្នាយ៉ាងច្រើនកុះករជាកីឡាករផង និងអ្នកគាំទ្រផងមកពីសាលារៀននានាក្នុងស្រុកទាំងមូល។ កីឡាករក្រុមនីមួយៗបានកម្ដៅសាច់ដុំនៅតាមទីកន្លែងខុសៗគ្នា។ គ្រូបង្វឹកតាមក្រុមបានយកចិត្តទុកដាក់ពិនិត្យតាមដាន និងឱ្យដំបូន្មានបច្ចេកទេសដល់កីឡាករក្រុមខ្លួន។ បន្ទាប់មកគេបានប្រារព្ធធ្វើពិធីបើកតាមលំដាប់លំដោយក្រោមអធិបតីភាព ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ ចុងបញ្ចប់នៃពិធីនេះ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក បានប្រកាសបើកការប្រកួតចាប់ពីពេលនោះតទៅ។

ពេលប្រកួតឈានចូលមកដល់ កីឡាករទាំងពីរក្រុមបានដើរចូលក្នុងទីលានប្រកួត។ កីឡាករទាំងពីរក្រុមស្លៀកពាក់ឯកសណ្ឋានខុសប្លែកពីគ្នា។ បន្ទាប់ពីអាជ្ញាកណ្ដាលផ្លុំកញ្ចែចាប់ផ្ដើមការប្រកួត កីឡាករម្នាក់ៗរត់ចល័តទាត់បាល់ទៅតាមលក្ខណៈបច្ចេកទេសរបស់ខ្លួន។ ពួកគេ ម្នាក់រត់បណ្ដើរបាល់ ចែកបាល់ឱ្យគ្នាទៅវិញទៅមក ដើម្បីបញ្ឆោតគូប្រកួតរបស់ខ្លួន។ កីឡាករខំប្រឹងរត់ច្រវាត់ចុះឡើងៗក្នុងកីឡាដ្ឋាន ដើម្បីបណ្ដើរបាល់ និងដណ្ដើមបាល់។ យូរៗម្ដង គេឃើញគ្រូបង្វឹកស្នើផ្លាស់ប្ដូរកីឡាករ។ ការប្រកួតបានរយៈពេល២០នាទី ក្រុមឫទ្ធិសែនទាត់បញ្ចូលទីបានមួយគ្រាប់ ធ្វើឱ្យអ្នកទស្សនា និងអ្នកគាំទ្រស្រែកហ៊ោកញ្ជ្រៀវហើបខ្លួនឡើងពីទីអង្គុយដោយមិនដឹងខ្លួន ព្រមទាំងទះដៃស្រែកហ៊ោកញ្ជ្រៀវលាន់ឮទ្រហឹងអឹងកង។ ការប្រកួតកំពុងបន្តទៅកាន់តែស្វិតស្វាញ។ ក្រុម


www.elibraryofcambodia.org

ព្រះរាម ព្យាយាមទាត់បញ្ចូលទីក្រុមឬទ្ធិសែនវិញជាច្រើនលើកតែមិនបានសម្រេច។ ផ្ទុយទៅវិញ នៅនាទីទី៣៥ ក្រុមឫទ្ធិសែនមានជ័យទាត់បញ្ចូលទីបានមួយគ្រាប់ទៀត។ អ្នកទស្សនា និងអ្នកគាំទ្រទះដៃស្រែកហ៊ោកាន់តែខ្លាំងឡើង។ សំឡេងទះដៃ សម្រែកហ៊ោកញ្ជ្រៀវញ៉ាំងឱ្យពិធីប្រកួតកាន់តែអធឹកអធមក្រៃលែង។ រយៈពេល៤៥នាទីកន្លងផុតទៅ ជាកាលកំណត់វេលាចុងបញ្ចប់នៃការប្រកួតវគ្គទី១។ នេះជាពេលកីឡាករត្រូវសម្រាក ១៥នាទី។ ជាលទ្ធផលក្រុមឫទ្ធិសែនឈ្នះក្រុមព្រះរាម២គ្រាប់ទល់ នឹង០។ ក្រុមឫទ្ធិសែន និងអ្នកគាំទ្រក្រុមខ្លួនកំពុងមានទឹកមុខញញឹមញញែម ក្នុងក្តីសង្ឃឹមនឹងទទួលបានជ័យលាភីជាមិនខាន។

បន្ទាប់ពីឈប់សម្រាក អាជ្ញាកណ្តាលបានផ្លុំកញ្ចែចាប់ផ្តើមប្រកួតវគ្គទី២។ កីឡាករសម្រុកទាត់បាល់បញ្ចូលទីរៀងៗខ្លួន។ ក្នុងវគ្គនេះ កីឡាករក្រុមព្រះរាមបានផ្លាស់បច្ចេកទេសប្រកួត ដោយវាយលុកយ៉ាងខ្លាំងធ្វើឱ្យពួកគេមានប្រៀបយ៉ាងខ្លាំងលើកីឡាករក្រុមឫទ្ធិសែន។ កីឡាករក្រុមឫទ្ធិសែន បានប្រឹងប្រែងទប់ទល់អស់ពីសមត្ថភាព។ ប្រមាណជា២៥នាទីក្រោយមក កីឡាករក្រុមព្រះរាមធ្វើបានសម្រេចដោយទាត់បញ្ចូលទីបាន១គ្រាប់។ ការប្រកួតនៅតែបន្តយ៉ាងស្វិតស្វាញ រហូតដល់ទីបញ្ចប់។ ជាលទ្ធផលក្រុមឫទ្ធិសែនឈ្នះក្រុមព្រះរាម២គ្រាប់ ទល់នឹង១គ្រាប់។

ពេលបញ្ចប់ការប្រកួត គេបានរៀបចំធ្វើពិធីប្រកាសបិទការប្រកួតក្រោមអធិបតីភាពប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ បន្ទាប់ពីប្រកាសបិទការប្រកួតរួចមក ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក បានប្រគល់រង្វាន់ដល់ជ័យលាភីក្រុមឫទ្ធិសែនមានជ័យដែលទទួលជ័យជម្នះក្នុងការប្រកួត។ កីឡាករក្រុមឫទ្ធិសែន និងអ្នកគាំទ្រសប្បាយរីករាយនឹងលទ្ធផលនៃការប្រកួតនេះ។


www.elibraryofcambodia.org

ខ្ញុំមានអារម្មណ៍សប្បាយរីករាយនឹងការប្រកួតកីឡានេះណាស់ ព្រោះជាការបង្កើនចំណងមិត្តភាព សាមគ្គីភាព មានសហការល្អ និងជួយលើកកម្ពស់វិស័យកីឡាទៀតផង។ លើសពីនេះ ការលេងកីឡានាំឱ្យមានសុខភាពល្អ។ ដូច្នេះ សិស្សានុសិស្សទាំងឡាយ ត្រូវជៀសវាងឱ្យឆ្ងាយពីគ្រឿងញៀន ហើយនាំគ្នាលេងកីឡាឱ្យបានគ្រប់ៗគ្នា។

## ខ.ការសិក្សាគម្រោងតែងសេចក្តី

### ១.សេចក្តីផ្តើម

- ពណ៌នាទូទៅទាក់ទងនឹងការប្រកួតកីឡា
- ពេលវេលា
- ទីកន្លែង ។

### ២.តួសេចក្តី

- មុនពេលប្រកួត ៖
  - រៀបចំទីលានប្រកួត
  - រៀបចំទីកន្លែងគណៈកម្មការ
  - ពិធីប្រកាសបើកការប្រកួត។
- ពេលប្រកួត ៖
  - ការចាប់ផ្តើមប្រកួត
  - ការប្រើបច្ចេកទេសរបស់កីឡាករ
  - ការពិន័យកីឡាករ
  - ការផ្លាស់ប្តូរកីឡាករ
  - ការទាត់បញ្ចូលទី។


www.elibraryofcambodia.org

- ក្រោយពេលប្រកួត ៖
  - ពិធីប្រកាសលទ្ធផល និងបិទការប្រកួត
  - ការប្រគល់រង្វាន់ជូនជ័យលាភី។

### ៣.សេចក្ដីបញ្ចប់

- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នកចំពោះការប្រកួតកីឡា
- បង្ហាញពីសារប្រយោជន៍នៃការលេងកីឡា និងការប្រកួតកីឡា។

## គ.ការអនុវត្ត

*ប្រធាន ៖* នៅតាមសាលារៀននានាក្នុងសហគមន៍របស់អ្នក តែងរៀបចំការប្រកួតកីឡាជារៀងរាល់ឆ្នាំ។ ចូរអ្នកពណ៌នាពីសកម្មភាពប្រកួតកីឡាណាមួយតាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។


www.elibraryofcambodia.org

វិញ្ញាសាទី ១១

# តែងសេចក្ដី
# បែបពិពណ៌នាអំពីការនិទានរឿង

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

| |
|---|
| *ប្រធាន ៖* អ្នកធ្លាប់បាននិទានរឿងមួយឱ្យមិត្តភក្ដិរបស់អ្នកស្ដាប់។ ចូរអ្នកពណ៌នាអំពីការនិទានរឿងនោះឡើងវិញឱ្យបានក្បោះក្បាយ ។ |

### សេចក្ដីអធិប្បាយ

កាលពីថ្ងៃចន្ទសប្ដាហ៍មុន នៅពេលចេញលេង នៅក្នុងបន្ទប់បណ្ណាល័យ ខ្ញុំនិងមិត្តភក្ដិចំនួនបួនប្រាំនាក់ អង្គុយអានសៀវភៅ។ ពេលនោះមិត្តខ្ញុំ បានអានរឿងមួយឱ្យពួកគេស្ដាប់។



រឿងនោះ មានចំណងជើងថា រឿងស្វាន់ កណ្ដុរ អណ្ដើក និងក្ដែក។ ដំណើររឿងមានដូចតទៅ ៖

ស្វាន់ កណ្ដុរ អណ្ដើក និងក្ដែក បានចងមិត្តជាមួយគ្នា ហើយរស់ជាសហគមន៍ក្នុងទីឋានមួយដ៏ស្ងប់ស្ងាត់ឆ្ងាយពីភូមិឋានមនុស្សទាំងឡាយ។

ថ្ងៃមួយស្វាន់ដើរស្វែងរកអាហារតាមសម្បាជីវោ ស្រាប់តែមានផ្ទៃដីកំណាចមួយរបស់មនុស្សរែកស្មៅដេញហិតតាមដានជើងរបស់វា។ ឃើញដូច្នេះ ស្វាន់ភិតភ័យក៏បោលកាន់តែឆ្ងាយទៅៗ។


www.elibraryofcambodia.org

ថ្លែងពីកណ្ដុរពេលបាត់ស្ទាន់ឃ្មុំរ កំនិយាយទៅកាន់អ្នកដទៃទៀត៖ "ហេតុអ្វីបានជាថ្ងៃនេះ យើងសល់គ្នាតែបីនាក់? តើស្ទាន់គេបំភ្លេចពួកយើងមែនទេ?"។ ពេលនោះអណ្ដើកឧទានឡើង៖ "ឱ! ប្រសិនបើខ្ញុំមានស្លាបដូចក្អែក ខ្ញុំនឹងចេញទៅស្វែងយល់ យ៉ាងហោចណាស់ក៏ឱ្យដឹងថា តើមិត្តដំណើរស្រាលស្នើករបស់យើងមានជួបគ្រោះថ្នាក់អ្វី នៅទីណាដែរ ព្រោះថាបើយើងនិយាយពីទឹកចិត្តគ្មាននរណាអាចវិនិច្ឆ័យឱ្យបានប្រសើរជាងពេលនេះទេ"។

ក្អែកក៏ហើរចេញវឹងទៅ។ វាបានមើលពីចម្ងាយទៅឃើញស្ទាន់ជាប់អន្ទាក់កំពុងទទាក់ទើបម្រះ។ ក្អែកត្រឡប់មកប្រាប់គ្នីគ្នាភ្លាម ព្រោះបើទៅសួរនាំស្ទាន់ថា តើរឿងឧបទ្រពនេះ កើតឡើងពីពេលណា ដោយសារមូលហេតុអ្វី និងបែបណានោះ គឺនាំឱ្យខាតពេលវេលា។ ក្រោយពីបានស្ដាប់ក្អែក មិត្តទាំងបីក៏ពិភាក្សាគ្នារកមធ្យោបាយជួយស្ទាន់ជាប់អន្ទាក់ក្នុងព្រៃភ្នំ។ គ្រាន់តែប្រឹក្សាគ្នារួចភ្លាម ពួកគេចេញដំណើរទៅជួយមិត្តជាទីស្រឡាញ់ដែលធ្លាប់តែមានស្មារតីភក្ដីរបស់គេ គឺស្ទាន់ដ៏កម្សត់។ ក្អែក និងកណ្ដុរធ្វើដំណើរបានយ៉ាងឆាប់រហ័ស ដោយឡែកអណ្ដើកខំប្រឹងវារតើមៗទៅនឹងគេដែរ។ ពេលទៅដល់ ក្អែកជាសត្វហើរពាំទឹកមកស្រោចលើខ្សែអន្ទាក់ឱ្យទន់។ ចំណែកកណ្ដុរ និងអណ្ដើកមានភារកិច្ចខាំកកេរកាត់ខ្សែអន្ទាក់។ គ្រាន់តែអន្ទាក់ដាច់ភ្លាម ក៏ឮមាត់ព្រានមកដល់ល្មម សត្វទាំងអស់ភិតភ័យក៏រត់រកកន្លែងរៀងៗខ្លួន។ លុះព្រានព្រៃមកដល់ឃើញអន្ទាក់ដាច់កើតសេចក្ដីក្រេវក្រោធយ៉ាងខ្លាំង។ ព្រានដើរចុះ ដើរឡើងនៅជិតៗទីនោះ ក៏ប្រទះឃើញអណ្ដើកកំពុងវារតើមៗ ព្រានក៏រើសអណ្ដើកដាក់ក្នុងស្បោងយកទៅ។


www.elibraryofcambodia.org

អណ្ដើកក្លាយជាអ្នករងគ្រោះវិញម្ដង។ ស្មាន់ចេញពីកន្លែងពួនភ្លាម។ វាបង្ហាញខ្លួនឱ្យព្រានព្រៃឃើញដោយធ្វើជារបួសបាក់ជើង។ ព្រានព្រៃក្រឡេកឃើញ ក៏ស្ទុះដេញតាមភ្លាម ដោយបោះចោលអ្វីៗទាំងអស់ដែលខ្លួនយល់ថាទើសទែង។ បាននិកាស កណ្ដុរចាប់ផ្ដើមធ្វើការភ្លាមដោយកកេរកាត់ខ្សែចងមាត់ស្បោង ដើម្បីរំដោះមិត្តមួយទៀតដែលព្រានប្រុងយកទៅធ្វើម្ហូប។ ពេលកកេររួច ក្អែកធ្វើជាអ្នកនាំដំណឹងទៅប្រាប់ស្មាន់ដែលកំពុងបញ្ឆោតព្រានព្រៃ។ ស្មាន់ក្រោយពីបានដំណឹងហើយ ក៏ស្ទុះហោះពេញទំហឹងទៅរកអណ្ដើក រួចក៏ខាំពាំអណ្ដើកហោះចូលព្រៃបាត់ទៅ។

ក្នុងការធ្វើអន្តរាគមន៍នេះ ក្អែក កណ្ដុរ អណ្ដើក និងស្មាន់សុទ្ធតែមានតួនាទីយ៉ាងសំខាន់រៀងៗខ្លួន។ ដូច្នេះ តើនរណាសមនឹងទទួលបានរង្វាន់ ? បើតាមយោបល់ខ្ញុំគឺ បេះដូង។

ក្រោយពីនិទានចប់ មិត្តទាំងអស់មានចិត្តសប្បាយរីករាយក្រៃលែង ព្រោះបានស្ដាប់ដំណើររឿង ដែលបង្ហាញពីមិត្តល្អចេះជួយគ្នាក្នុងគ្រាមានអាសន្ន។ ដូច្នេះយើងគួរយកតម្រាប់តាមមិត្តភក្តិទាំងបួននៅក្នុងរឿងនេះ។

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

### ១. សេចក្ដីផ្ដើម

- ប្រាប់ពីពេលវេលា ៖ ពេលសម្រាកថ្ងៃចន្ទ ពេលចេញលេង វេលាម៉ោង ... ។
- ទីកន្លែង ៖ នៅសាលារៀន នៅផ្ទះ ...។


www.elibraryofcambodia.org

### ២. តួសេចក្ដី

- ប្រភេទរឿង ឈ្មោះរឿង
- ដំណើររឿងទាំងមូល ៖ តួអង្គ សកម្មភាព ការនិទានតាមបែបបុរសទី៣)
- សេចក្ដីបញ្ចប់រឿង ៖ តើរឿងនោះបញ្ចប់ដោយរបៀបណា ។

### ៣. សេចក្ដីបញ្ចប់

- សេចក្ដីរីករាយ របស់ប្អូននិងមិត្តភក្ដិដែលបានស្ដាប់
- យោបល់របស់ប្អូននិងអ្នកស្ដាប់ចំពោះអត្ថន័យរបស់រឿង ។

## ឥ. ភាពអនុវត្ត

| | |
|---|---|
| *ប្រធាន ៖* | អ្នកធ្លាប់បាននិទានរឿងមួយឱ្យមិត្តភក្ដិរបស់អ្នកស្ដាប់។ ចូរអ្នកនិទានរឿងនោះឡើងវិញតាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។ |


www.elibraryofcambodia.org

វិញ្ញាសាទី ១២

# តែងសេចក្ដី
# បែបពិពណ៌នាអំពីការសរសេរសំបុត្រ

## ក.ការសិក្សាអត្ថបទតែងសេចក្ដីគំរូ

*ប្រធាន* ៖ រៀងរាល់ថ្ងៃអ្នកតែងធ្វើទំនាក់ទំនងគ្នាតាមមធ្យោបាយផ្សេងៗ។ ចូរអ្នកសរសេរសំបុត្រផ្ញើទៅអ្នកណា ម្នាក់ដែលអ្នកធ្លាប់ស្គាល់ឱ្យបានក្បោះក្បាយ។

### សេចក្ដីអធិប្បាយ

*ព្រៃវែង ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៤*

*មកដល់សន្តិការិកា !*

*ពីមិត្តជាទិរន្ត៍*

*មេត្តា*


www.elibraryofcambodia.org

សន្តិការិកា ! រយៈពេលជាច្រើនខែមកហើយ ដែលខ្ញុំបានឃ្លាតឆ្ងាយពីមិត្ត។ ក្នុងរយៈពេលនេះ ខ្ញុំតែងតែនឹកមមៃមកដល់ពូកម៉ាកជានិច្ច។ រាត្រីនេះ ខ្ញុំគេងមិនលក់សោះទើបខ្ញុំខិតខំផ្ចង់អារម្មណ៍ រិះរកពាក្យពេចន៍មកសរសេរជាសំបុត្រនេះ។ ពូកម៉ាក ! តើឯងមាននឹករឭកមកដល់ខ្ញុំទេ ? តើឯងមានសេចក្ដីសុខដែរឬយ៉ាងណា ? បើឯងមានសេចក្ដីសុខខ្ញុំពិតជាត្រេកអររកអ្វីមកប្រៀបផ្ទឹមគ្មាន។ ចំណែកខ្ញុំវិញ នៅឯនេះមានសេចក្ដីសុខជាធម្មតាទេ ហើយតែងនឹកមកដល់ឯងជានិច្ច។ ខ្ញុំមិនអាចរកពាក្យអ្វីមកសរសេររៀបរាប់ ឱ្យត្រូវនឹងទំហំនៃការនឹករឭករបស់ខ្ញុំចំពោះឯងបានឡើយ។

សន្តិការិកា ! អនុស្សាវរីយ៍របស់យើងទាំងពីរ កំពុងជិតនៅជាប់នឹងដួងវិញ្ញាណខ្ញុំជានិច្ច។ យើងធ្លាប់អានសៀវភៅជាមួយគ្នា ធ្វើលំហាត់ជាមួយគ្នា។ យើងទៅណាមកណាពីរនាក់ជានិច្ច។ ឯងឆ្លាតណាស់ឆាប់ចេះ ឆាប់យល់ រហ័សចាំ ហើយឧស្សាហ៍ទៀតផង។ ខ្ញុំមិនដឹងថា ពូកម៉ាកនៅចាំរឿងរ៉ាវទាំងនេះដែរឬទេ ? អូ ! ខ្ញុំភ្លេចនិយាយប្រាប់ឯង សព្វថ្ងៃក្រៅពីរៀននៅសាលារដ្ឋ ខ្ញុំរៀនភាសាអង់គ្លេស និងកុំព្យូទ័របន្ថែមទៀត។ ឥឡូវខ្ញុំអាចប្រើអ៊ិនធឺណិតបានខ្លះៗហើយ។ ខ្ញុំជឿថា ឯងក៏ចេះប្រើប្រាស់វាដែរនៅពេលខាងមុខ ហើយឆាប់ចេះប្រើជាងខ្ញុំ ប្រសិនបើឯងបានរៀន។

យប់ជ្រៅណាស់ហើយ ខ្ញុំសូមបញ្ចប់អត្ថបទនេះចុះ។ តាមរយៈសំបុត្រដំណឹងនេះខ្ញុំសូមផ្ញើសេចក្ដីនឹករឭកដល់មិត្តភក្តិទាំងអស់ និងអ្នកភូមិយើងផង។ ចុងបញ្ចប់នេះ ខ្ញុំសុំឱ្យសន្តិការិកា និងក្រុមគ្រួសារបាន ជួបតែសេចក្ដីសុខគ្រប់ទិវារាត្រី។

*ពីមិត្តជានិរន្តរ៍*
*មេត្តា*


www.elibraryofcambodia.org

## ខ.ការសិក្សាគម្រោងតែងសេចក្ដី

ការសរសេរសំបុត្រជាការសំខាន់មួយ ដែលយើងត្រូវផ្ចិតផ្ចង់ដោយត្រូវប្រើពាក្យគួរសម មានសុជីវធម៌។ ដូច្នេះ ក្នុងការសរសេរសំបុត្រ ត្រូវយកចិត្តទុកដាក់ប្រិតប្រៀន ប្រើពាក្យងាយយល់ ច្បាស់លាស់ ត្រឹមត្រូវ មកសរសេរដោយសង្ខេបខ្លឹមសារ ឬសេចក្ដីសំបុត្រឱ្យខ្លីល្មមកុំឱ្យវែងហួសប្រមាណ ដើម្បីឱ្យអ្នកអានងាយយល់។

ការសរសេរសំបុត្រចែកចេញជាបីផ្នែកគឺក្បាលសំបុត្រ តួសំបុត្រ និងការបញ្ចប់សំបុត្រ ៖

### ១. ក្បាលសំបុត្រ

- ចុះឈ្មោះ ចុះទីកន្លែង ចុះកាលបរិច្ឆេទនៃការសរសេរ
- ការកាន្ទងសំបុត្រ។

### ២. តួសំបុត្រ

- រៀបរាប់ពីសុខទុក្ខអ្នកសរសេរ
- សួរសុខទុក្ខអ្នកដែលទទួលសំបុត្រ
- សរសេររៀបរាប់រឿងរ៉ាវផ្សេងៗមានដូចជា ដំណឹង ការសប្បាយ ទុក្ខព្រួយ ដំបូន្មានសេចក្ដីនឹករឭក សកម្មភាពផ្សេងៗ ...។

### ៣. ការបញ្ចប់សំបុត្រ

- ជូនពរ ( ត្រូវប្រើពាក្យឱ្យសមស្របតាមកាលៈទេសៈ )
- ជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សំបុត្រដូចជាពីកូនកម្សត់របស់ម៉ែ នឹកជានិរន្តរ៍
- ទីបញ្ចប់ត្រូវ ចុះហត្ថលេខា និងចុះឈ្មោះអ្នកសរសេរ ។


www.elibraryofcambodia.org

## គ.ការអនុវត្ត

*ប្រធាន ៖* រៀងរាល់ថ្ងៃអ្នកតែងធ្វើទំនាក់ទំនងគ្នាតាមមធ្យោបាយផ្សេងៗ។ ចូរអ្នកសរសេរសំបុត្រផ្ញើទៅអ្នកណាម្នាក់ដែលអ្នកធ្លាប់ស្គាល់តាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។





www.elibraryofcambodia.org

## យើងបម្រើសេវាកម្ម ៖

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

## WE SERVE :

- book and teaching-aid developme
- printing
- distribution to schools


គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ច)

PUBLISHING AND DISTRIBUTION HOUSE (PDH)

# បណ្ណាគារ គ.ប.ច

# PDH BOOKSHOP


## មានលក់ ៖

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

## SELLING :

textbooks , teacher's manuals , workbooks , supplementary reader teaching-aids and stationary !

9789995002183

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្ញៅ យ៉ាត់ណៃ, ខ្ញៅ សុផល, ខ្ញៅ វិសាល, ខ្ញៅ វាសុន, ខ្ញៅ ភាវាជា, ខ្ញៅ ចំរើន និង ខ្ញៅ ករី
បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលផលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ ឃឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ សៀង ស៊ីវ៉ាន់
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព «ក្សេសិទ្ធ» របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ញៅ ឃុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org